# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៧ ខែឧសភា លេខ៥

ព.ស.២៤៩៨ — គ.ស. ១៩៥៥

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ


— វិហារណកថា ................ ពុទ្ធសាសនបណ្ឌិត្យ ........ ៤០៣

— ឈ្មោះខ្លួនឯងប្រសើរបំផុត ........ លោក យូរ-អ៊ុន ....... ៤០៨

— វិវាទមូល .................. ព្រះឧបាលិវង្ស ម៉ុង-សែស .. ៤១២

— បញ្ញាសជាតក ភាគទី ៣ (តមក) .... បណ្ឌិតមហា ឈឹម-ស៊ុម .... ៤២៣


*ផ្នែកអក្សរសាស្ត្រ*


— កំឡាំងនៃសាមគ្គី ............ ព្រះមហា ម៉ៅ-ខាន់ ...... ៤៣៤

— រឿងសៅរសោយ (តមក) ........ ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ... ៤៤៣

— រឿងសាមកុក (តមក) .......... ឧកញ៉ា នូ-កន ......... ៤៥០

— ដំណឹងតាមខ្យល់ក្នុងកន្ទារៈ (តមក) ... លោក ផេង-ដ្រីវ ........ ៤៥៦

— រឿងបល្ល័ង្កទិព្យ (តមក) .......... លោក វ៉ាយ-ប៊ុក ........ ៤៦២


*កំណត់ទីដប្រវត្តិការណ៍*


— គមនប្បវត្តិ ................ ព្រះមហា ទូត-ទិម ..... ៤៦៩

— បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក) ក្រសួងធម្មការ .......... ៤៧៩


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជារ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

PARTIE RELIGIEUSE: Page


| | | |
|---|---|---|
| — Editorial . . . . . . . . . . . | *Institut Bouddhique . . . . .* | 403 |
| — La maitrise de soi . . . . . . | *M. YOU-OUN . . . . . . .* | 408 |
| — Vivadamula . . . . . . . . . . | *Vén. MENG-SES . . . . . .* | 412 |
| — Pannasajataka- vol.3 (suite) . | *M. CHHIM-SOUM . . . . .* | 423 |


PARTIE LITTERAIRE:


| | | |
|---|---|---|
| — L'union fait la force . . . . . . | *Vén. MAO-KHAN . . . . .* | 434 |
| — Le «SAU SOY» ou l'influence saturnienne (suite) . . . . . | *Vén. PEUNG-PAM . . . . .* | 443 |
| — Histoire de samkok (suite). . | *Oknha NOU-KAN . . . . . .* | 450 |
| — Le souffle du désert (suite) . . | *M. PHENG-CHRIV. . . . .* | 456 |
| — Les trente deux récits du Trône (suite) . . . . . . . . . | *M. RAY-BUC . . . . . . . .* | 462 |


NOTES ET CHRONIQUES:


| | | |
|---|---|---|
| — Examen de sortie de l'Ecole de Pali de Soctrang . . . . . . . | *M. TUOT-TIM . . . . . . . .* | 469 |
| — Nomination des nouveaux Chau Adhikars (suite) . . . . . . | *Ministère des Cultes . . .* | 479 |


Prix d'abonnement annuel (comprenant 12 numéros) 210$00

# វត្តបំណងនៃពុទ្ធសាសនា

ប្រទេសកម្ពុជា ជាប្រទេសដែលបានកាន់ព្រះពុទ្ធសាសនាជាច្រើនសតវត្សរ៍មកហើយ ទាំងច្បាប់រដ្ឋធម្មនុញ្ញសម្រាប់ប្រទេសទៀតក៏បានចាត់ទុកនូវពុទ្ធសាសនាថាជាសាសនាសម្រាប់រដ្ឋដែរ ។ ហេតុនេះ ពុទ្ធ-ជនទាំងឡាយ គួរយកចិត្តទុកដាក់ពិចារណារិះរកខុសត្រូវក្នុងពាក្យប្រៀនប្រដៅឲ្យរឿយ ៗ ដើម្បីនឹងទំនុកបំរុងព្រះពុទ្ធសាសនាឲ្យបានរុងរឿង កុំឲ្យសាបសូន្យទៅដោយវិធីណាឡើយ ។ គប្បីពិគ្រោះមើលតាមហេតុផលនឹងតាមបែបច្បាប់ដែលលោកអ្នកប្រាជ្ញចាស់បានសំដែងទុកមក អំពីមុន ៗ ឲ្យយល់ឃើញពិតប្រាកដ កុំបណ្តោយទុកឲ្យកើតទៅជាការវិនាស ព្រោះទិដ្ឋិមិនស្របគ្នានោះ គួរទុស្សាហ៍រិះរកមធ្យោបាយ ដើម្បីសេចក្តីចំរើនដល់ពុទ្ធសាសនាក្នុងកម្ពុជរដ្ឋទៅអនាគតកាលផង ។

ទិដ្ឋិ ប្រែថា ‹‹ដំណើរយល់ឃើញ, សេចក្តីប្រកាន់តាមការយល់›› ។ ដំណើរយល់ឃើញត្រូវតាមសភាវធម៌ ហៅថា សម្មាទិដ្ឋិ, ដំណើរយល់ឃើញខុសអំពីគោលធម្មជាតិ ឬសេចក្តីប្រកាន់តាមការយល់ឃើញដែលជាទំនាស់នឹងគោលនៃសេចក្តីពិត ហៅថា មិច្ឆាទិដ្ឋិ ។

ពីនេះសូមអស់លោក-អ្នកពិចារណាតាមខ្ញុំដូចតទៅនេះ ៖

ព្រះពុទ្ធសាសនា មិនមែនជាសាសនាប្រដៅមនុស្សឲ្យទន់ខ្សោយ ដែលមិនហ៊ានតស៊ូនឹងគេទេ ។ រឿងនេះ បើយើងពិចារណាមើលតាម

ប្រវត្តិរបស់ព្រះសម្ពុទ្ធជាម្ចាស់ហើយ ក៏ឃើញបានថា ព្រះអង្គមានព្រះជាតិជាក្សត្រក្នុងវង្សគោតមសក្យរាជ គង់រាជសម្បត្តិនៅក្នុងក្រុងកបិលពស្តុមហានគរ, ព្រះអង្គទ្រង់ជាកំពូលនៃអ្នកចំបាំងដែលធ្លាប់ប្រឡងមានថ្វីព្រះហស្តឈ្នះគេមកហើយ ទ្រង់មានព្រះកាយពលខ្លាំងពូកែ ទាំងមានកម្លាំងព្រះទ័យមិនខ្លាចសេចក្តីទុក្ខលំបាកក្នុងការលុកលៃព្រៃផ្សៃឡើយ តែទោះបីព្រះអង្គពូកែឈ្លាសវៃក្នុងការច្បាំងដូច្នោះក៏ដោយ ក៏ព្រះអង្គត្រឡប់មកប្រៀនប្រដៅមនុស្សឲ្យតាំងនៅក្នុងសេចក្តីស្ងប់ មិនឲ្យគំរាមកំញើញបៀតបៀនគ្នាទៅវិញ ។ ព្រះសាស្តាទ្រង់ជាមគ្គុទ្ទេសក៍ បង្ហាញផ្លូវឲ្យឃើញថា សីលធម៌ជារបស់មនុស្សមានរស្មីក្អែក គឺបញ្ញា មិនឲ្យធ្លាក់ខ្លួនទៅជាទាសៈនៃសេចក្តីអន្ទះសា ដោយអំណាចសេចក្តីលោភ សេចក្តីក្រោធ ឬសេចក្តីវង្វេងឡើយ ។ មួយទៀត, ព្រះអង្គទ្រង់ត្រាស់ថាអ្នកជាកំពូលចំបាំង មិនមែនសន្មតយកអ្នកច្បាំងឈ្នះមនុស្សដ៏ទៃរាប់ម៉ឺនរាប់សែននាក់នោះទេ គឺព្រះអង្គទ្រង់សរសើរអ្នកច្បាំងឈ្នះខ្លួនឯង ដោយមិនបណ្តោយខ្លួនឲ្យធ្លាក់ទៅជាទាសៈរបស់កិលេស ដែលដេកត្រាំនៅខាងក្នុងសន្តានចិត្ត ។

មួយវិញទៀត, ព្រះពុទ្ធសាសនា មិនមែនជាសាសនារបស់អ្នកបោកបញ្ឆោតមនុស្សដទៃឲ្យវង្វេងនៅក្រោមអំណាចរបស់ខ្លួនទេ ។ រឿងនេះបើពិចារណាមើលដោយល្អិតល្អន់ហើយ ក៏ឃើញបានថា ព្រះពុទ្ធជាម្ចាស់មិនដែលប្រៀនប្រដៅនរណា ឲ្យជាទាសៈរបស់នរណាទេ, តែងតែទ្រង់ប្រៀនប្រដៅជួយចម្លងមនុស្ស ឲ្យផុតចាកទាសភាពទាំង

ខាងផ្លូវកាយ ទាំងខាងផ្លូវចិត្តទូទៅគ្រប់មនុស្សដោយឥតរើសមុខ ។ ផ្លូវកាយ, ទ្រង់ប្រៀនប្រដៅមិនឲ្យពុទ្ធសាសនិកជនទិញទាសៈលក់ទាសៈ, មិនឲ្យកំហែងមនុស្សដែលទន់ខ្សោយជាងខ្លួន , ឲ្យមានមេត្តាករុណាអាណិតអាសូរដល់មនុស្សដែលក្រលំបាក, ទ្រង់ប្រដៅឲ្យចេះទីពឹងខ្លួនឯង មិនឲ្យវង្វេងទៅអង្វរករស្រែកសូមអំពីវត្ថុស័ក្តិសិទ្ធិ ដោយមិនបានធ្វើអ្វីឲ្យកើតផល, ឲ្យព្យាយាមធ្វើបរចិញ្ចឹមជីវិតក្នុងផ្លូវដែលត្រូវ មិនតែប៉ុណ្ណោះ ថែមទាំងទ្រង់ប្រៀនប្រដៅមិនឲ្យប្រកាន់វណ្ណៈទៀតផង គឺទ្រង់ប្រដៅឲ្យប្រកាន់ការប្រព្រឹត្តល្អជាគោល ។ អ្នកប្រតិបត្តិយ៉ាងនេះរមែងមិនជាទាសៈនរណា ទាំងមិនធ្វើនរណាឲ្យជាទាសៈ ។ ចំណែកផ្លូវចិត្ត, ទ្រង់ប្រដៅមិនឲ្យមនុស្សធ្វើជាទាសៈរបស់កិលេសទាំងប្រភេទលោភចង់បាន ទាំងប្រភេទក្រោធខឹង ទាំងប្រភេទវង្វេងងងឹតល្ងង់ ។ កាលបើដូច្នេះ គួរឃើញបានថាព្រះពុទ្ធសាសនាប្រៀនប្រដៅ ដើម្បីរំដោះទាសភាពដោយពិត ។, សូម្បីព្រះសាស្តាក៏ទ្រង់មិនមានបំណងឲ្យនរណាមួយ មកធ្វើសក្ការៈគោរពបូជាព្រះអង្គដែរ ដូចទ្រង់ប្រកាសជាឱឡារិកថា ការប្រព្រឹត្តព្រហ្មចារ្យមិនមែនដើម្បីលាភសក្ការៈនិងការសរសើរទេ, ក្រៅអំពីនេះទៅទៀតទ្រង់ប្រកាន់យកការប្រតិបត្តិត្រូវជាគោល គឺនរជនណាប្រតិបត្តិត្រូវ នរជននោះឈ្មោះថាបានបូជាព្រះអង្គដោយបូជាដ៏ខ្ពង់ខ្ពស់ ជាងការបូជាដោយទៀនធូបផ្កាឈើទៅទៀត ។ សូម្បីអ្នកកាន់ជាយសង្ឃាដីរបស់ព្រះអង្គ បើមិនបានប្រតិបត្តិឲ្យត្រឹមត្រូវទេ ក៏មិនឈ្មោះថានៅជិតព្រះអង្គដែរ ។ នេះឯងជាគ្រឿងបញ្ជាក់ឲ្យឃើញថា ព្រះបរមសាស្តាទ្រង់ប្រៀនប្រដៅដើម្បី

ប្រយោជន៍ដល់អ្នកប្រព្រឹត្តប្រតិបត្តិត្រូវយ៉ាងពិតប្រាកដ មិនមែនមានបំណងនឹងបោកបញ្ឆោតយកលាភសក្ការៈទេ, បើព្រះអង្គមានបំណងយ៉ាងនោះមែន ទ្រង់គង់នៅជាក្សត្រគ្រប់គ្រងលោកិយសម្បត្តិប្រសើរជាង ។

ព្រះសម្ពុទ្ធជាម្ចាស់ប្រដៅមនុស្សឲ្យប្រតិបត្តិល្អ យ៉ាងគ្រប់គ្រាន់ ហើយបើនឹងលើកតំកើងនរជនណា ក៏លើកតំកើងព្រោះសេចក្តីប្រព្រឹត្តិល្អរបស់នរជននោះ ឥតមានលើកតំកើងព្រោះទ្រព្យ ឬ ព្រោះវង្សត្រកូលឡើយ ។ ព្រោះហេតុនោះ នរណាដែលសំដែងខ្លួនថាជាអ្នកចេះដឹង មិនចំពោះតែផ្លូវលោក ឬ ផ្លូវធម៌ទេ បើវាចារបស់គេដែលបន្លឺចេញមកនោះប្រកបដោយសេចក្តីឫស្យា, អាឃាត, សេចក្តីក្រោធខឹងទោមនស្សតូចចិត្ត ជាវាចាដឹកនាំដើម្បីឲ្យបំផ្លាញចំពោះអ្នកដែលខ្លួនស្អប់ហើយ គប្បីជ្រាបចុះថា នយោបាយដូច្នោះជារបស់មនុស្សឆ្ងាយចាកព្រះពុទ្ធសាសនា ដូចមានរឿងតំណាលថា ៖

សម័យមួយ ព្រះសម្ពុទ្ធបានស្តេចទៅកាន់ដែនមគធៈ, វស្សការព្រាហ្មណ៍មហាមាត្យនៃដែននោះបានមកគាល់ព្រះអង្គ ហើយក្រាបបង្គំទូលអំពីសេចក្តីយល់ឃើញរបស់ខ្លួនថា "អ្នកក៏ដោយ ដែលខ្ញុំព្រះអង្គបានឃើញ បានឮ ឬបានដឹងមក, បើខ្ញុំព្រះអង្គនិយាយទៅតាមការដែលដឹង ដែលឃើញនោះហើយ ក៏មិនមានទោសទេ" ។ ព្រះសម្ពុទ្ធត្រាស់តបថា តថាគតមិនពោលថា វត្ថុដែលបានឃើញ បានឮ នឹងបានដឹងមកនោះជារបស់គួរនិយាយជានិច្ចទេ បើពាក្យឯណាដែលនិយាយទៅហើយ ជាហេតុឲ្យធម៌ចំណែកអាក្រក់ចំរើន ធម៌ចំណែកល្អសាបសូន្យ

ពាក្យនោះក៏មិនគួរនិយាយ; តែបើនិយាយទៅហើយ ជាហេតុឱ្យធម៌ចំណែកអាក្រក់សាបសូន្យ ធម៌ចំណែកល្អចំរើន ពាក្យនោះទើបគួរនិយាយ; តថាគតសរសើរចំពោះតែអ្នកដែលនិយាយសច្ចៈពិតៗ ព្រមទាំងត្រូវឱ្យស្គាល់កាលដែលគួរនិយាយផង ៗ មនុស្សដែលកើតមកហើយ តែងមានអណ្តាតកើតមកនៅក្នុងមាត់ផង ៗ មនុស្សពាលដែលពោលវាចាអាក្រក់ថោកទាប ឈ្មោះថាប្រើអណ្តាតនោះសម្លាប់ខ្លួនឯង ៗ នរណានឹងធ្វើការណាៗ ក៏ដោយ បើមានសេចក្តីលោភ សេចក្តីក្រោធ សេចក្តីវង្វេងជាឫសគល់ហើយ សេចក្តីអាក្រក់ដទៃៗ ដែលនៅមិនទាន់កើតឡើង ក៏នឹងកើតឡើង ដែលកើតហើយ ក៏រឹតតែចំរើនឡើង ៗ មនុស្សពាលកាលបើពោលពាក្យអាក្រក់ ក៏សំគាល់ថាខ្លួនឈ្នះ ៗ សេចក្តីអត់ធន់របស់មនុស្សអ្នកដឹងទាន់ ទើបជាជ័យជំនះដ៏ពិតប្រាកដ ៗ អ្នកក្រោធតបមនុស្សដែលក្រោធ រមែងទាបថោកក្រៃលែងជាងមនុស្សដែលក្រោធមុននោះទៅទៀត ៗ មនុស្សដែលមិនក្រោធតបចំពោះអ្នកដែលក្រោធ ឈ្មោះថាជាអ្នកឈ្នះសង្គ្រាមដែលកម្រនឹងឈ្នះបាន ៗ

ពុទ្ធមាមកជនទាំងឡាយ ចូរពិចារណាមើលចុះ ព្រះធម៌ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ គឺប្រដៅឱ្យពួកយើងស្រឡាញ់សន្តិភាព គឺឱ្យធ្វើការណាៗ ដោយប្រាសចាកសេចក្តីលោភ ក្រោធ វង្វេងជាត្រីមុខ ៗ ក្នុងទីបំផុត ព្រះអង្គទ្រង់ប្រដៅពួកយើងឱ្យឈ្នះសង្គ្រាមដែលកម្រនឹងឈ្នះបាន គឺឱ្យហាត់ពត់ចិត្តមិនក្រោធខឹងចំពោះមនុស្សទូទៅ ៗ

ពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

# ឈ្នះខ្លួនឯងប្រសើរបំផុត

ឃុនសុវិត្តិវេទី យូរ-អ៊ុន រៀបរៀង

---

តាមធម្មតា មនុស្សក្នុងលោក ដែលរួមគ្នានៅជាសង្គមតូចក្តី ធំក្តី តែងមានការវិវាទឈ្លោះទាស់ទែងគ្នា ដោយការដណ្តើមយកត្រូវ ឬយកឈ្នះតែរៀងខ្លួន ៗ ផលជម្លោះនេះ បើក្នុងសង្គមតូច ៗ បង្កើតទៅជាវាយដាល់កាប់សម្លាប់គ្នា ឬក្តីក្តាំប្តឹងផ្តល់ដល់រាជការ ឲ្យវិនិច្ឆ័យរកខុសរកត្រូវឲ្យ, បើក្នុងសង្គមធំ ៗ បង្កទៅជាចំបាំងតស៊ូដោយកម្លាំងអាវុធ ជាហេតុធ្វើឲ្យជាតិប្រទេសវិនាសអន្តរាយ ៗ ផលចុងបំផុតនៃជម្លោះ គឺអ្នកដែលកម្លាំងខ្សោយ ក៏ចាញ់, អ្នកដែលមានកម្លាំងខ្លាំង ក៏ឈ្នះ ៗ បណ្តាការឈ្នះនឹងការចាញ់ ក្នុងការតស៊ូដោយកម្លាំងនេះ, ការឈ្នះ គេរាប់ថាប្រសើរបំផុត ព្រោះអាចរកអំណាចចេញទៅតាមឥទ្ធិពលរបស់ខ្លួនបាន ៗ តែចំបាំងនេះទុកជាជាចំបាំងខាងក្រៅ, ជ័យជំនះនៃចំបាំងខាងក្រៅនេះ អ្នកប្រាជ្ញទាំងឡាយមានព្រះសម្ពុទ្ធជាដើមមិនសរសើរសោះឡើយ ព្រោះអ្នកដែលឈ្នះហើយ ជួនកាលត្រឡប់ទៅជាចាញ់វិញ ដោយហេតុអ្នកឈ្នះតែងទទួលពៀរ, អ្នកចាញ់តែងដេករករឿងនឹងសងសឹកវិញ ៗ

ក្នុងខ្លួនមនុស្សយើង មានសង្គមពីរ ដែលតែងប្រឆាំងគ្នា គឺសង្គមចិត្តកុសល និងសង្គមចិត្តអកុសល ។ ចិត្តទាំង ២ ក្រុមនេះ តែងតែផ្លាស់ផ្លូវ ឈ្នះគ្នាទៅវិញទៅមក ។ បើចិត្តអកុសលច្បាំងឈ្នះចិត្តកុសល ក៏សង្កត់ផ្តាច់ចិត្តកុសលមិនឲ្យក្រោករួច ហើយដឹកនាំកាយឲ្យធ្វើអំពើពាលយង់ឃ្នងមានប្រការផ្សេងៗ, ដឹកនាំមាត់ឲ្យពោលពាក្យប្រកបដោយទោសច្រើនយ៉ាង ។ ផលក្នុងទីបំផុត ចិត្តអកុសលក៏ផ្តល់ឲ្យមនុស្សយើងទទួលវេទនាលំបាកតាមស្ថានការណ៍ដែលបានប្រព្រឹត្ត រឿងនេះ គួរឃើញដូចអ្នកលេងស្រី អ្នកផឹកស្រា អ្នកលេងល្បែងភ្នាល់ អ្នកប្រព្រឹត្តធ្វើចោរកម្មលួចប្លន់ ឆបោកយកទ្រព្យសម្បត្តិអ្នកដទៃជាដើម, ពួកជនអ្នកប្រព្រឹត្តអំពើពាលលាមកទាំងនេះ តែងវិនាសខ្លួន, វិនាសទ្រព្យសម្បត្តិ ។ នេះឯងមកអំពីចិត្តអកុសលគេបង្ក្រាបចិត្តកុសលៗ គ្មានកម្លាំងនឹងរើខ្លួនបាន ទើបធ្វើឲ្យគេធ្លាប់ខ្លួនចុះទៅក្នុងអំពើអាក្រក់ ឥតគក់ស្លុត ឥតខ្មាសអៀនខ្មាសទៀយ ។

ប្រសិនបើចិត្តកុសលច្បាំងឈ្នះចិត្តអកុសលវិញ ចិត្តកុសលក៏ដឹកនាំមនុស្សយើងឲ្យចូលចិត្តធ្វើតែអំពើល្អ និយាយតែពាក្យជាគុណប្រយោជន៍ដឹកនាំឲ្យរៀបរកពាក្យសុភាពៈរៀបសា ។ ពួកជនដែលមានចិត្តកុសលឈ្នះចិត្តអកុសលនោះ តែងទទួលផលជាសុខ, ចំណេកលាភ, យស និងសេចក្តីសរសើរ ក៏ចេះតែកើតមានជាលំដាប់ ដូចចូឡេកសាដកព្រាហ្មណ៍ដែលមានសំពត់ដណ្តប់តែមួយ ប្រើពីរនាក់ប្តីប្រពន្ធ ពេលមួយគាត់បានចូលទៅស្តាប់ធម៌ព្រះសម្ពុទ្ធ ក៏មានសទ្ធាចិត្ត (ចិត្តសទ្ធា) ចង់ថ្វាយសំពត់

ដណ្តប់នោះចំពោះព្រះអង្គតែសទ្ធាចិត្តនេះច្បាំងនឹងមច្ឆេរចិត្ត(ចិត្តកំណាញ់មិនចង់ថ្វាយវិញ) តាំងពីពេលបឋមយាមរហូតដល់បច្ឆិមយាមក៏មិនអាចយកជ័យបាន ៗ ក្នុងរយៈវេលាមួយកន្លែងនោះ ជួនកាលសទ្ធាចិត្តមានកម្លាំងសង្កត់មច្ឆេរចិត្ត, ជួនកាលមច្ឆេរចិត្តមានកម្លាំងសង្កត់សទ្ធាចិត្ត ៗ លុះដល់បច្ឆិមយាម ចូឡេកសាដកព្រាហ្មណ៍ ទើបដាច់ស្រេចក្នុងចិត្តឥតរើរុះថា ត្រូវតែថ្វាយសំពត់ដណ្តប់ ដល់ព្រះសម្ពុទ្ធ ខានពុំបាន ៗ ត្រង់នេះ ទុកជាសទ្ធាចិត្តច្បាំងឈ្នះមច្ឆេរចិត្ត ៗ ក្នុងកាលជាបន្ទាន់នេះ ចូឡេកសាដកព្រាហ្មណ៍បានទទួលសេចក្តីសរសើរ ព្រមទាំងបានទទួលសំពត់សាដក ៣២ គូ នឹងខ្ញុំប្រុសខ្ញុំស្រី គោក្របីសេះជាដើមអំពីព្រះបាទបសេនទិកោសល ៗ ការបានសេចក្តីសរសើរជាដើមនៃចូឡេកសាដកព្រាហ្មណ៍នេះ គឺជាផលដែលកើតអំពីចិត្តកុសលផ្តល់មកឲ្យ ៗ

ចំបាំងនៃចិត្តកុសលនឹងចិត្តអកុសលនេះ រាប់ថាជាចំបាំងខាងក្នុង ព្រោះកើតមានខាងក្នុងសន្តានមនុស្សយើងរាល់រូប ៗ បណ្តាជ័យជំនះខាងក្នុងនេះ ជ័យជំនះរបស់ចិត្តអកុសល បណ្ឌិតមិនរាប់ថាជាជំនះដ៏ប្រសើរទេ ព្រោះឲ្យផលជាទុក្ខដល់សត្វ, ជ័យជំនះរបស់ចិត្តកុសល ទើបរាប់ថាជាជំនះដ៏ប្រសើរ ព្រោះឲ្យផលជាសុខ តាមសមគួរដល់កម្លាំងកសាងមក ៗ

សេចក្តីនេះសមដូចពុទ្ធភាសិតថា អត្តា ហវេ ជិតំ សេយ្យោ ឈ្នះខ្លួនឯងប្រសើរ ៗ ពាក្យថាខ្លួនឯង សំដៅយកចិត្ត, ឈ្នះខ្លួនឯង គឺឈ្នះចិត្តឯង, សំដៅយកចិត្តកុសលឈ្នះចិត្តអកុសលនោះឯង ៗ

ចិត្តកុសលដែលមានកម្លាំងអាចឈ្នះចិត្តអកុសលបាន ដោយ

អាស្រ័យធម៌ ២ ប្រការគឺសញ្ញមៈ (ការរក្សា) និងទមៈ (ការបង្ខឹក) ។ សញ្ញមៈជាធម៌ទី ១ មានការៈខាងការសង្រួម រក្សា ប្រយ័ត្នឃ្លាំមើលអារម្មណ៍ដែលចូលមកកន្ទ្វារទាំង ៦ ឲ្យដឹងថាអារម្មណ៍នេះល្អឬមិនល្អ, កាលបើអារម្មណ៍ណាចូលមកហើយ នាំឲ្យកើតសោមនស្សឬទោមនស្ស ក៏ទប់ឃាត់ចិត្តមិនឲ្យសោមនស្ស មិនឲ្យទោមនស្ស ។ បន្ទាប់មកត្រូវមុខទមៈ ជាធម៌ទី ២ ដែលមានការៈខាងទូន្មានប្រៀនប្រដៅចិត្ត ឲ្យប្រព្រឹត្តទៅកន្លងផ្លូវមានសួស្តី ។ ទមៈ ធម៌នេះទុកជាទម័កចិត្ត សម្រាប់ប្រដៅចិត្តឲ្យដើរទៅកន្លងទីប្រកបដោយគុណ ។ កុសលចិត្ត កាលបើមានធម៌សញ្ញមៈ នឹង ទមៈនេះមកជាអាវុធហើយ ក៏អាចឈ្នះចិត្តអកុសលបានដោយងាយ ។ ដូច្នេះ យើងជាពុទ្ធសាសនិកជនមិនគប្បីប្រាំងនឹងជនដទៃទេ គប្បីប្រាំងតែនឹងខ្លួនឯង ព្រោះឈ្នះខ្លួនឯងប្រសើរបំផុត ៚

ឈ្នះអ្វីមិនប្រពៃស្មើនឹងឈ្នះចិត្ត
ដែលប្រព្រឹត្តធ្វើអំពើមិនសមសួន
បានហៅថាអស់គ្មានអាឡោះអាល័យសូន
អាចធ្វើខ្លួនមានសួស្តីជ័យជោគល្អ ។
ការចាញ់ចិត្តគឺបណ្តោយទៅតាមចង់
មិនគិតត្រង់អគ្គខុសត្រូវផ្លូវខ្លោស
តែងមានទុក្ខឃើញទាន់ហន់តាមជាន់ក
លុះតំណាទៅជាតិមុខទុក្ខអនន្ត ។

យូរ – អ៊ុន

# វិវាទមូល

ព្រះឧបាលិវង្ស មុំង-សេស
វត្តមហាមន្ត្រី ក្រុងភ្នំពេញ
រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង)

សូមនមស្សការ ចំពោះព្រះភគវន្តមុនី ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ( ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព ) ។

សូមសំដែងអំពីវិវាទមូល តាមទំនងដែលមានក្នុងខុទ្ទកវត្ថុវិភង្គ គម្ពីរវិភង្គ អភិធម្មបិដក ។

ធម៌ដែលជាឫសគល់ឬជាហេតុនាំឲ្យកើតសេចក្តីឈ្លោះ ហៅថា វិវាទមូល ។ វិវាទមូលនោះព្រះដ៏មានព្រះភាគ ទ្រង់សំដែងចែកចេញទៅជា ៦ ប្រការ គឺ:

១_ កោធោ សេចក្តីក្រោធ គឺសេចក្តីខឹងចងគំនុំគុំគួន ។

២_ មក្ខោ ការលុបបំបាត់គុណគេ ។

៣_ ឥស្សា សេចក្តីច្រណែនឈ្នានីសគេ ។

៤_ សាឋេយ្យំ ការប្រកាសគុណដែលមិនមានក្នុងខ្លួន គឺអួតអាងអំពើខិលខូច, អំពើឆបឆប, បោកប្រាស, អំពើដែលជាកិច្ចកលរបស់អ្នកលេង ។

៥– ប្បាបិប្ចតា សេចក្ដីប្រាថ្នាអាក្រក់ ។

៦– សន្ទិដ្ឋិបរាមាសិតា សេចក្ដីប្រកាន់មាំនូវទិដ្ឋិ គឺប្រកាន់តាមសេចក្ដីយល់ឃើញរបស់ខ្លួនថាជាការត្រូវការពិត សេចក្ដីយល់ឃើញរបស់អ្នកដទៃ សុទ្ធតែមិនត្រូវមិនពិត ។

## អធិប្បាយវិភាទមូល ៦ ប្រការ

កោធោ = សេចក្ដីក្រោធខឹង នេះ បានដល់ការអាក់អន់ចិត្ត តូចចិត្ត, ថ្នាំងថ្នាក់ចិត្ត កន្ទួលចិត្ត ។ សេចក្ដីក្រោធខឹងនេះមនុស្សជាបុថុជ្ជនតែងមានគ្រប់គ្នាជាធម្មតា ហេតុនោះបានជាមនុស្សជាបុថុជ្ជនច្រើនតែឈ្លោះទាស់ទែងគ្នា ។ សេចក្ដីក្រោធនេះបណ្ដាលមកអំពីការពាក្យគេជេរត្មះតិះដៀលឌឺដងបញ្ឈឺចិត្តខ្លះ បណ្ដាលមកអំពីការបៀតបៀនដោយកាយ មានវាយដំតប់ទះជាដើមរបស់អ្នកដទៃខ្លះ, បណ្ដាលមកអំពីការលេងល្បែងភ្នាល់ មានល្បែងបាស្កាល្បែងស៊ីសងជាដើមខ្លះ, បណ្ដាលមកអំពីគេយកទ្រព្យសម្បត្តិបំផ្លិចបំផ្លាញទ្រព្យសម្បត្តិខ្លះ, កាលបើកើតក្រោធថ្នាំងថ្នាក់អាក់អន់ចិត្តហើយ ក៏កើតទៅជាឈ្លោះទាស់ទែងរហូតដល់ទៅចងពៀរពេរ្យាបាទធ្វើគ្នាឲ្យវិនាសក៏មាន ។

មួយវិញទៀត សេចក្ដីក្រោធនេះជាឧបក្កិលេសគ្រឿងមន្ទិលសៅហ្មងចិត្ត ប្រៀបដូចជាវត្ថុមានធូលីដេះកកជាដើម ជាមន្ទិលសៅហ្មងដល់សំពត់សស្អាត, ក៏ឯចិត្តនោះប្រសិនបើសៅហ្មងដោយឧបក្កិលេសគឺសេចក្ដីក្រោធហើយ ក៏ជាហេតុឲ្យបានទុគ្គតិគត, ប្រសិនបើបរិសុទ្ធជ្រះស្អាត

ចាកឧបក្កិលេសគឺសេចក្តីក្រោធហើយក៏ជាហេតុឲ្យបានសុគតិភព, ដូចគ្នានឹងសំពត់ស្អាតឥតមានប្រឡាក់ដោយមន្ទិលផ្សេង ៗ មានធ្យូងផេះភក់ជាដើម រមែងជិតជាប់ដោយគ្រឿងជ្រលក់ទាំងពួង មានពណ៌ក្រហមលឿងខៀវជាដើម នាំឲ្យសម្រេចប្រយោជន៍ដល់អ្នកដែលត្រូវការដោយជ្រលក់សំពត់ ។

ជនជាសប្បុរស គួរគ្រប់សង្កត់សេចក្តីក្រោធឲ្យទន់ខ្សោយកុំឲ្យកៀរគ្នាពេក ដោយធម៌ខន្តីសេចក្តីអត់ធន់នឹងមេត្តាសេចក្តីរាប់អានស្រឡាញ់គ្នីគ្នា ក្រឡេកមើលគ្នាដោយបិយចក្ខុ និយាយរកគ្នាដោយបិយវាចា ដើម្បីកុំឲ្យមានវិវាទទាស់ទែងគ្នា ព្រោះការវិវាទនោះជាភេទមួយយ៉ាងធំកងសង្គមនៃមនុស្សលោក ។

ការគ្រប់សង្កត់បំបាត់សេចក្តីក្រោធនោះ មិនត្រឹមតែបាត់វិវាទប៉ុណ្ណោះទេ រមែងអាចផ្ចាញ់មនុស្សអ្នកក្រោធបានផង រមែងបានសុគតិភពគឺឋានសួគ៌ទេវលោក សមតាមបទព្រះបាលីថា អក្កោធេន ជិនេ កោធំ ប្រែថា "មនុស្សយើងអាចផ្ចាញ់មនុស្សអ្នកក្រោធបាន ដោយសេចក្តីមិនក្រោធតប" ។

សច្ចំ ភណេ ន កុជ្ឈេយ្យ ទជ្ជា អប្បស្មិំ យាចិតោ
ឯតេហិ តីហិ ឋានេហិ គច្ឆេ ទេវាន សន្តិកេ

ប្រែថា "មនុស្សយើងគួរនិយាយពាក្យពិតទៀងត្រង់ ១ មិនគួរក្រោធ ១ បើមានទេយ្យធម៌បន្តិចបន្តួច គួរឲ្យទានបន្តិចបន្តួចដល់ស្មូមកុំខាន ១, មនុស្ស

យើងអាចទៅនៅក្នុងសំណាក់ទេវតាបាន ដោយហេតុទាំង ៣ នេះ ហេតុណាមួយក៏បាន " ។

មក្ខោ = ការលប់បំបាត់គុណគេ នោះ សេចក្ដីប្រហែលគ្នានឹងអកតញ្ញូតាធម៌ គឺការមិនដឹងគុណរបស់អ្នកដែលគេធ្វើគុណលើខ្លួន ឬថាដឹងដែរតែធ្វើហាក់ដូចជាមិនដឹង បំបិទបំបាំងមិនឲ្យគេពល់គ្នា ដឹងថាអ្នកនោះគេមានគុណលើខ្លួន មានឧទាហរណ៍ដូចជាភិក្ខុមួយរូបរៀនសូត្រក្នុងសំណាក់អាចារ្យមួយរូប រៀនបានចេះដឹងគួរសមហើយក៏ទៅរៀនក្នុងសំណាក់អាចារ្យដទៃទៀត យូរ ៗ ទៅបានចេះដឹងច្រើនជាងអាចារ្យដើម មានលាភសក្ការៈនឹងសេចក្ដីសរសើរគ្រាន់បើជាងអាចារ្យដើម ក៏សំដែងអាការដូចជាមិនមែនសិស្សមិនមែនអាចារ្យ ធ្វើឫកស្មើ ៗ បន្ទុំមិនឲ្យអ្នកដទៃដឹងថាខ្លួនជាកូនសិស្ស ។ មានភិក្ខុខ្លះរៀនសូត្រអំពីអាចារ្យច្រើនរូប តែគោរពរាប់អានបូជាចំពោះតែអាចារ្យណាដែលមានបុណ្យសក្តិ មានមុខមាត់អំណាចវាសនាច្រើន ត្រង់អាចារ្យឯទៀតៗធ្វើហាក់ដូចជាមិនស្គាល់ ។ ភិក្ខុខ្លះទៀតឥតមានរៀននឹងគេសោះ ឃើញគេមានមុខមាត់យសស័ក្តិលាភសក្ការៈច្រើន ក៏ខំយកចិត្តទុកដាក់ផ្គាប់ផ្គុនគេដោយចង់បានផលប្រយោជន៍ក្នុងបច្ចុប្បន្ន ចោលគ្រូអាចារ្យរបស់ខ្លួនទទេ ឥតមានទឹកនាសោះ ។

ម្យ៉ាងទៀត ការលុបគុណសម្បត្តិ គឺសេចក្ដីល្អរបស់គេចេញ ក្ដីសកកាយសេចក្ដីអាក្រក់របស់គេឲ្យអណ្ដែតខ្ពស់ឡើង ក៏ហៅថា

មក្ខោ ការលុបគុណគេដែរ, ដូចក្នុងគ្រាពុទ្ធកាល មានភិក្ខុ ២ រូបឈ្មោះ ធម្មកថិក ១ វិនយធរ ១ កើតវិវាទបែកគ្នាទៅជា ២ ពួក ៗ ហេតុខាងដើម គឺធម្មកថិកបន្ទោបង់ឧច្ចារៈ ហើយជំរះឧច្ចារៈសល់ទឹកខ្វះក៏ទុកក្នុងភាជនៈ ដាក់ក្នុងបន្ទប់ទឹក ៗ វិនយធរចូលទៅក្រោយឃើញទឹកនៅសល់ ហើយចេញមកវិញប្រាប់ធម្មកថិកថា លោកទុកទឹកដែលសល់អំពីជំរះដូច្នោះ ខុសតាមទំនងវិនយបញ្ញត្តិហើយ ៗ ធម្មកថិកក៏ទទួលខុសគ្មានរឹងទទឹង ៗ ពេលក្រោយ វិនយធរនិយាយប្រាប់រឿងនោះដល់សិស្សរបស់ខ្លួន ៗ ពួកសិស្សវិនយធរក៏នាំគ្នាពោលទោសប្រាប់ពួកសទ្ធិវិហារិករបស់ធម្មកថិក ថា ឧបជ្ឈាយ៍របស់លោកត្រូវអាបត្តិ មិនស្គាល់អាបត្តិ ៗ

រឿងហេតុនោះមិនមែនជាធំដុំទេ តែបណ្តាលទៅជាធំបាន បែកពួកបែកបក្សជា ២ មកអំពីពួកវិនយធរគ្របលុបសេចក្តីល្អរបស់ធម្មកថិក ក៏សកកាយសេចក្តីខុសតែបន្តិច ឲ្យអណ្តែតខ្ពស់ឡើងប្រាប់គេពាល់គ្នា ដូច្នេះ ក៏ហៅថាលុបគុណសម្បត្តិរបស់គេឲ្យបាត់សូន្យទៅ ទាញយកសេចក្តីអាក្រក់របស់គេមកប្រកាសនាំឲ្យកើតវិវាទ ៗ

•

មក្ខោ ការលុបគុណគេនេះ ជាឧបក្កិលេសគ្រឿងសៅហ្មងដល់ចិត្តដូចជា (កោធោ) វិវាទមូលទី ១ នោះដែរ ព្រោះហេតុនោះ ជនជាសប្បុរសគួរលះបង់នូវអំពើលុបគុណគេចោលចេញ ត្រូវដឹងគុណគ្រូអាចារ្យមាតាបិតានិងអ្នកដែលគេបានសង្គ្រោះទំនុកបំរុងខ្លួន កុំភ្លេចឧបការៈគុណគេឡើយ ចំណែកគស្សជននីមួយ ៗ ត្រូវបើកចក្ខុក្រឡេកមើលឲ្យច្បាស់ ត្រូវផ្ចង់សោតៈស្តាប់ឲ្យជាក់ ត្រូវយកបញ្ញាពិចារណាមើល

ឲ្យសព្វគ្រប់ ឲ្យស្គាល់ច្បាស់ថាមនុស្សនេះមានគុណសម្បត្តិច្រើន មនុស្សនោះមានគុណសម្បត្តិតិច គួរសំរេចការទៅតាមហេតុកុំឲ្យភាន់ច្រឡំ ក្រែងនឹងធ្លាក់ទៅក្នុងតម្រាស៊ុកគ្រលុក ។

ឥស្សា = សេចក្ដីប្រណែនឈ្នានីសគេ, សេចក្ដីថា ការដែលបុគ្គល ឃើញគេមានលាភសក្ការៈ សេចក្ដីគោរពរាប់អានអំពីជនដទៃក៏ប្រណែនមិនចង់ឲ្យគេលើសខ្លួន ឬ មិនចង់ឲ្យគេស្មើនឹងខ្លួន ដោយលាភសក្ការៈ នឹងសេចក្ដីគោរពរាប់អានអំពីជនដទៃនោះ ដូច្នេះជាដើមហេតុនាំឲ្យកើតវិវាទទាស់ទែងគ្នាពេញបន្ទុក ដូចជាព្រះទេវទត្តឃើញគ្រហស្ថគោរពរាប់អានព្រះថេរៈទាំងឡាយ មានព្រះសារីបុត្តនឹងព្រះមោគ្គល្លានជាដើម ត្រង់ខ្លួនឯងគេមិនគោរពរាប់អាន ក៏កើតសេចក្ដីប្រណែនឈ្នានីសឡើង បែកក្នែកទៅតែឯងស្វែងរកពួករកបក្ខមិត្រភក្តិបង្កហេតុវិវាទបំបែកសង្ឃ ត្រូវទោសអនន្តរិយកម្មបានបាបធ្ងន់បំផុត ។

ឥស្សា សេចក្ដីប្រណែននេះ ជាឧបក្កិលេស គ្រឿងសៅហ្មងដល់ចិត្តដូចគ្នានឹង (កោធោ) វិវាទមូលទី ១ នោះដែរ ព្រោះហេតុនោះពួកសប្បុរសគួរបន្ទោបង់នូវសេចក្ដីប្រណែនចេញ គួរចំរើននូវមុទិតាព្រហ្មវិហារឲ្យដុះក្នុងសន្ដាន នឹងបានស្ងប់ស្ងាត់បាត់ប្រណែនគេ វិវាទក៏បាត់សូន្យដោយអំណាចបាត់សេចក្ដីប្រណែន ។ ឯមុទិតានោះ ប្រែថា "សេចក្ដីត្រេកអររីករាយនឹងសម្បត្តិរបស់អ្នកដទៃ" គឺឃើញអ្នកដទៃបរិបូណ៌ដោយយសសក្តិទ្រព្យធនលាភសក្ការៈ នឹងសេចក្ដីសរសើរក៏មានសេចក្ដីត្រេកអររីករាយ គ្មានប្រណែន ។

សាឋេយ្យំ=ការប្រកាសគុណដែលមិនមានក្នុងខ្លួន នោះ សេចក្តីថា ខ្លួនមិនមានសទ្ធា អួតខ្លួនថាមានសទ្ធា, ខ្លួនមិនមានសីលបរិសុទ្ធ អួតខ្លួនថាមានសីលបរិសុទ្ធ, ខ្លួនចេះដឹងតិច អួតខ្លួនថាចេះដឹងច្រើន ដូច្នេះជាដើម ។ ត្រង់ពាក្យថា "អំពើខិលខូច, ឆែបឆប, បោកប្រាស" សេចក្តីថា ការនិយាយមិនពិតមិនត្រឹមមិនទៀងត្រង់ ការឆែបឆបឲ្យបទ្យបឲ្យតែខាងបានស៊ី ត្រង់ខុសត្រូវមិនគិត ដូចត្រីឈ្មោះអានន្ទមច្ឆ: មានកន្ទុយជាត្រី មានក្បាលដូចពស់ កាលបើជួបនឹងពួកត្រី ក៏បង្ហាញកន្ទុយថាខ្ញុំត្រីដែរ កាលបើជួបនឹងពួកពស់ ក៏បង្ហាញក្បាលថាខ្ញុំពស់ដែរៗ ត្រង់ពាក្យថា "អំពើកិច្ចកលរបស់អ្នកលេង" នោះសេចក្តីថា ការប្រើឧបាយកលច្រើន មិនឲ្យអ្នកដទៃស្គាល់ប្រាកដថាខាងណាពោះ ខាងណាខ្នងជាដើម, ធ្វើអំពើខុសហើយចេះគេចខ្លួនដោះខ្លួនឲ្យរួចពីទោស ៗ

ព្រះអដ្ឋកថាចារ្យ លោកលើកយកព្រះគាថា ១ មកពន្យល់អំពីបទ-សាឋេយ្យនេះថា :

វាមេន សូករោ ហោតិ ទក្ខិណេន អជាមិកោ
សរេន ឯលកោ ហោតិ វិសាណេន ជរគ្គវោ ។

ប្រែថា យក្ខសូករ: (ខ្មោចជ្រូក) ១ គេមើលពីខាងឆ្វេងជាជ្រូក មើលពីខាងស្តាំជាពពែ ស្តាប់សំឡេងជាចៀម មើលទៅស្នែងជាគោចាស់ ៗ បណ្ឌិតគាប្បីដឹងសេចក្តីក្នុងបទសាឋេយ្យដូច្នេះឯង ៗ

មួយទៀត សាឋេយ្យនេះជាឧបក្កិលេសគ្រឿងសៅហ្មងចិត្តដូចគ្នា

ខឹង ( កោធោ ) វិវាទមូលទី ១ នោះដែរ ព្រោះហេតុនោះ ពួកសប្បុរសគួរទូន្មានខ្លួនឲ្យល្អ គួរកុំប្រព្រឹត្តធម៌សាថេយ្យនេះឲ្យសោះ ទើបនឹងអាចបានសេចក្តីសុខស្រួលល្អឥតមានវិវាទ ។

**បាបិច្ឆតា = សេចក្តីប្រាថ្នាអាក្រក់** នោះតាមពុទ្ធាធិប្បាយថា បុគ្គលខ្លះក្នុងលោកនេះមិនមានសទ្ធា ចង់ឲ្យគេដឹងថាខ្លួនមានសទ្ធា, មិនមានសីលបរិសុទ្ធ ចង់ឲ្យគេដឹងថាខ្លួនមានសីលបរិសុទ្ធ, ចេះដឹងតិច ចង់ឲ្យគេដឹងថាខ្លួនចេះដឹងច្រើន, ត្រេកអរនឹងពួកគណៈ ចង់ឲ្យគេដឹងថាខ្លួនត្រេកអរនឹងទីស្ងាត់, ជាអ្នកខ្ជិលច្រអូស ចង់ឲ្យគេដឹងថាខ្លួនមានព្យាយាម, មានស្មារតីវង្វេងភ្លេច ចង់ឲ្យគេដឹងថាខ្លួនមានស្មារតីខ្ជាប់ខ្ជួន, មិនមានសមាធិ ចង់ឲ្យគេដឹងថាខ្លួនមានសមាធិ, មិនមានបញ្ញា ចង់ឲ្យគេដឹងថាខ្លួនមានបញ្ញា, ចំណង់ដូច្នេះហៅថាសេចក្តីប្រាថ្នាអាក្រក់ ។

បាបិច្ឆតា សេចក្តីប្រាថ្នាអាក្រក់នេះ អាចបណ្តាលចេញទៅជាអំពើមិនសមគួរផ្សេងៗ ដោយកាយខ្លះដោយវាចាខ្លះ បណ្តាលជាវិវាទផ្សេងៗ ។ ព្រោះហេតុនោះ ពួកសប្បុរសគួរលះបង់សេចក្តីប្រាថ្នាអាក្រក់នេះចេញ គួរតាំងនៅក្នុងសេចក្តីសន្តោស សេចក្តីប្រាថ្នាតិច ជាការគាប់ប្រសើរក្នុងលោក នាំឲ្យបានសេចក្តីសុខស្រួល នាំឲ្យបាត់វិវាទផង ។

**សន្ទិដ្ឋិបរាមាសិតា = សេចក្តីប្រកាន់មាំនូវទិដ្ឋិ** គឺ ប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួនថា ជាការត្រូវការពិត នោះជាមន្ទិលដល់ពួកក្រុមជំនុំតាំងពួងក្នុងលោក តាំងអំពី ២ រូបឡើងទៅ នាំឲ្យ

សៅហ្មង ដល់កិច្ចការទាំងឡាយ របស់អ្នកដែលមានគ្នាច្រើន ៗ ព្រោះមនុស្សក្នុងលោកនេះ មានទិដ្ឋិសេចក្តីយល់ឃើញខុសគ្នាជាច្រើន ព្រោះហេតុនោះ សាធុជនមិនគួរប្រកាន់សេចក្តីយល់ឃើញរបស់ខ្លួនថាត្រូវ ប្រកាន់សេចក្តីយល់ឃើញរបស់អ្នកដទៃថាខុសពេកឡើយ បើប្រកាន់ណាស់ទៅ នឹងធ្លាក់ចុះក្នុងតម្រាខ្វាក់ស្លាបដំរីពុំខានឡើយ ដូចមានរឿងក្នុងសុត្តន្តបិដកខុទ្ទកនិកាយ គម្ពីរឧទាន ថា

សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅវត្តព្រះជេតពន ទៀបក្រុងសាវត្ថី ។ សម័យនោះឯងមានពួកនានាតិត្ថិយបរិព្វាជក គឺអ្នកបួសដែលមានលទ្ធិផ្សេងៗ នៅក្នុងនគរសាវត្ថី មានវិវាទទាស់ទែងគ្នាដោយហេតុប្រកាន់ធម៌តាមយោបល់ចូលចិត្តតែរៀងៗខ្លួន ខ្លះប្រកាន់ថាលោកទៀង ខ្លះថាលោកមិនទៀង ខ្លះថាលោកមានទីបំផុត ខ្លះថាលោកមិនមានទីបំផុត ខ្លះថាជីវិតនឹងសរីរៈជាមួយគ្នាមិនដទៃពីគ្នា ខ្លះថាជីវិតដទៃ សរីរៈដទៃ ជាដើម ៗ

នានាតិត្ថិយបរិព្វាជកទាំងនោះក៏ជជែកគ្នា ដណ្តើមយកត្រូវតែរៀងខ្លួន ហើយពោលពាក្យចាក់ដោតគ្នាទៅវិញទៅមក ៗ

គ្រានោះ មានភិក្ខុច្រើនអង្គនិមន្តចូលទៅយកបិណ្ឌបាត ក្នុងក្រុងសាវត្ថី បានជ្រាបដំណើរនោះ លុះត្រឡប់មកអំពីបិណ្ឌបាតធ្វើភត្តកិច្ចរួចហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ បានក្រាបបង្គំទូលដំណើរវិវាទ របស់ពួកនានាតិត្ថិយបរិព្វាជក តាំងអំពីដើមរហូតដល់ចប់ ៗ

ព្រះអង្គមានព្រះបន្ទូលថា បានជាពួកជនទាំងនោះ ទាស់ទែងគ្នា

មានសភាពដូច្នោះ ព្រោះសេចក្ដីល្ងង់ខ្លៅ មិនដឹងអត្ថមិនដឹងធម៌ពិតប្រាកដ ហើយព្រះអង្គសំដែងរឿងព្រេងក្នុងនគរសាវត្ថី ជាទីសណ្ដាប់ដល់ភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពីមុនមកមានព្រះរាជា ១ ព្រះអង្គ សោយរាជ្យក្នុងនគរសាវត្ថី ថ្ងៃមួយព្រះរាជានោះមានព្រះបន្ទូលត្រាស់បង្គាប់បុរសម្នាក់ ឲ្យជ្រើសរើសរកយកបុគ្គលខ្វាក់អំពីកំណើត ក្នុងក្រុងសាវត្ថីទាំងប៉ុន្មានឲ្យមកប្រជុំគ្នាក្នុងទី ១ បុរសនោះក៏ទទួលព្រះរាជ-ឱង្ការហើយ ក៏ចាត់ការប្រមូលអស់ពួកមនុស្សខ្វាក់អំពីកំណើតមកប្រជុំគ្នាតែក្នុងកន្លែង ១ ហើយយកសេចក្ដីក្រាបបង្គំទូលតាមដំណើរ ៗ ព្រះរាជាអង្គនោះមានព្រះរាជឱង្ការឲ្យយកដំរីមកឲ្យពួកជនខ្វាក់ទាំងនោះស្ទាបមើលតែពួកខ្លះឲ្យស្ទាបត្រង់ក្បាលដំរី ខ្លះឲ្យស្ទាបត្រចៀក ខ្លះឲ្យស្ទាបភ្លុក ខ្លះប្រមោយ ខ្លះខ្លួន ខ្លះជើង ខ្លះខ្នង ខ្លះកន្ទុយ ខ្លះឲ្យស្ទាបត្រង់ចុងកន្ទុយ ៗ

បុរសនោះក៏ចាត់ការឲ្យស្ទាបដំរីតាមព្រះរាជឱង្ការសព្វគ្រប់ ក៏ត្រឡប់មកក្រាបបង្គំទូលវិញ ៗ ព្រះរាជាក៏ទ្រង់ស្ដេចយាងទៅកាន់សំណាក់ពួកជនខ្វាក់ទាំងនោះ ហើយទ្រង់មានព្រះរាជឱង្ការថា នែអ្នកទាំងឡាយចូរនិយាយតាមពិតតាមមែន ដោយចំណាំរបស់ខ្លួន អ្នកពល់គ្នាធ្លាប់បានឃើញដំរីឬទេ? ដំរីតើដូចម្ដេច? ដូចអ្វីខ្លះ? ៗ ពួកជនងងឹតភ្នែកពីកំណើតទាំងនោះ ក៏ក្រាបបង្គំទូលតាមសញ្ញារបស់ខ្លួន គឺពួកអ្នកស្ទាបក្បាលដំរី ក្រាបបង្គំទូលថាដំរីដូចក្អមទឹក, ពួកអ្នកស្ទាបត្រចៀកថាដំរីដូចចង្អេរ, អ្នកស្ទាបភ្លុកថាដំរីដូចផាលនង្គ័ល, អ្នកស្ទាបប្រមោយថាដំរីដូចយាមនង្គ័ល, អ្នកស្ទាបខ្លួនថាដំរីដូចជាកស្រូវ, អ្នកស្ទាបជើងថា

ដំរីដូចសសរផ្ទះ, អ្នកស្ទាបខ្នងថាដំរីដូចត្បាល់, អ្នកស្ទាបកន្ទុយថាដំរីដូចអង្រែ, ពួកអ្នកស្ទាបចុងកន្ទុយដំរី យកសេចក្តីក្រាបបង្គំទូលថាដំរីដូចអំបោសសំពប់បោសសំរាម ។ ពួកជនខ្វាក់ទាំងនោះក៏តាំងប្រកែកគ្នា ជជែកគ្នាយ៉ាងម៉ឺងម៉ាត់ ដណ្តើមយកផ្លូវត្រូវផ្លូវពិតតែរៀងខ្លួនរហូតដល់ឈ្លោះគ្នាយ៉ាងធំ ទៅជាដាល់តប់គ្នា ទាត់ធាក់គ្នាពេញទំហឹង ។ សម័យនោះព្រះរាជាក៏ទ្រង់ព្រះសំរួលក្អាកក្អាយដោយអត់ទ្រាំពុំបាន ។

ម្នាលភិក្ខុទាំងឡាយ បរិព្វាជកទាំងនោះ គ្មានបញ្ញាចក្ខុងងឹត ងងល់វង្វេងអត្ថក៏មិនដឹង មិនមែនអត្ថក៏មិនដឹង, ធម៌ក៏មិនដឹង មិនមែនធម៌ក៏មិនដឹង ម្ល៉ោះហើយទៅជាឈ្លោះគ្នា ដណ្តើមយកត្រូវដោយសត្វខ្លួនដូចបុគ្គលខ្វាក់អំពីកំណើតទាំងនោះឯង ។

សន្ទិដ្ឋិបរាមាសិកា សេចក្តីប្រកាន់មាំនូវសេចក្តីយល់ឃើញរបស់ខ្លួនថាត្រូវជាពិត ថាការយល់ឃើញរបស់អ្នកដទៃ មិនត្រូវមិនពិតនេះក៏ជាហេតុឲ្យកើតវិវាទតាស់ទែងគ្នា ប្រហែលគ្នានឹងរឿងមនុស្សខ្វាក់ស្ទាបដំរីនោះឯង ។

ចំណែកធម៌វិន័យព្រះពុទ្ធសាសនា ជ្រាលជ្រៅពេកណាស់ ច្រើនក្រៃលែង មិនងាយនឹងចេះចាំចូលចិត្តសព្វគ្រប់ ពុទ្ធសាសនិកជនខ្លះប្រកាន់ថាខ្លួនត្រូវ គេខុស បណ្តាលឲ្យទៅជាវិវាទតាស់ទែងគ្នា នាំឲ្យជ្រោកជ្រាកព្រះពុទ្ធសាសនា ក៏ដូចគ្នានឹងមនុស្សខ្វាក់ស្ទាបដំរីនោះដែរ ។

អាត្មាភាពសំដែងមកក្នុងវិវាទមូល ៦ ប្រការមកនេះ ក៏សូមបញ្ចប់ទេសនាត្រឹមតែប៉ុណ្ណេះ ឯវំ ។

---

# បញ្ញាសជាតក

## ភាគទី ៣

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ
នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង
កាលដែលនៅភេទបព្វជិតពី ព.ស. ២៤៨៦ គ.ស. ១៩៤៣

(តមក)

---

## មហាសុរសេនជាតក ទី ១៤

លោកអាចារ្យ ម៉ៀវ-ឆន្ទ វត្តលង្កា
ប្រែពីបាលី

---

ឯកស្មឹ កិរ សមយេ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

កិរ ដូចបានឮរៀងៗមកថា ក្នុងកាលសម័យថ្ងៃមួយ សម្តេចព្រះភគវន្តាចារ្យសម្មាសម្ពុទ្ធ ទ្រង់គង់សម្រេចសម្រាន្តព្រះឥរិយាបថ ក្នុងវត្តជេតពនមហាវិហារ ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះព្រះដ៏មានសិរី ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយមកអាយ ។ ភិក្ខុទាំងនោះក៏ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាវិសេស ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងដូច្នេះថា

អតីតេ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ, ក្នុងកាលកពកន្តកំបាំងបាត់ស្ងាត់យូរណាស់ហើយ មានមហាក្សត្រាធិរាជមួយព្រះអង្គ ព្រះនាម-

មហាគត្ត សោយរាជសម្បត្តិក្នុងនគរនេះឯង ។ មានអគ្គមហេសី ១ ព្រះអង្គ ព្រះនាមចន្ទាទេវី ជាស្ត្រីប្រកបដោយលក្ខណធម៌ទាំង ៥ ប្រការគឺ បតុដ្ឋាយិនី ជាស្ត្រីក្រោកឡើងមុនព្រះរាជា ១, បច្ឆានិបាតិនី ជាស្ត្រីបរិភោគនឹងផ្ទុំក្រោយព្រះរាជា ១, និកសន្តិបតិសេវិនី ជាស្ត្រីរួមសំរាសជាមួយនឹងស្វាមី ឥតមានគំនិតអាក្រក់ ១, បិយវាទី ជាស្ត្រីមានសំរដីយតពីរោះ គួរឲ្យព្រះរាជាផ្ទៀងព្រះកាណ៌ចាំស្តាប់ ១, មនាបចារិនី ជាស្ត្រីចេះផ្គាប់ផ្គុនព្រះរាជស្វាមីមិនឲ្យខ្គងព្រះរាជហឫទ័យសោះ ១ ។ ព្រះនាងនោះជាទីស្រឡាញ់ពេញព្រះរាជហឫទ័យ នៃព្រះរាជាព្រះអង្គនោះយ៉ាងក្រៃលែង ។ ព្រះរាជាអង្គនោះ ទ្រង់មានព្រះរាជបុត្រា ៥០០ ព្រះអង្គ ចំរើនវ័យធំឡើងហើយ សុទ្ធតែជាបុរសមានរូបឆោមលោមពណ៌ល្អប្លែកៗ ។

គ្រានោះ ព្រះបរមពោធិសត្វ ទ្រង់ជាព្រះឥន្ទ្រាធិរាជគង់លើវេជយន្តប្រាសាទ ល្អស្អាងស្អាតនៅក្នុងវិមាន ១ ម៉ឺនយោជន៍ ហើយទ្រង់សោយទិព្វសម្បត្តិក្នុងពិភពតាវត្តិង្ស ទ្រង់ទតឃើញពួកមនុស្សកំសត់ទុគ៌តអនាថា ទើបទ្រង់ប្រុងប្រាដើម្បីសង្គ្រោះដល់សព្វសត្វ ទ្រង់ប្រមើលមើលបញ្ចវិលោកនៈទាំង ៥ ប្រការគឺ កាល ១ ប្រទេស ១ ទ្វីប ១ ត្រកូល ១ មាតា ១ ទើបស្តេចច្យុតិមកចាប់បដិសន្ធិក្នុងផ្ទៃនាងចន្ទាទេវីនោះឯង ។ លុះគ្រប់ខែ ១០ ព្រះនាងទ្រង់ប្រសូតព្រះរាជបុត្រ ល្អបំផុតដូចជាសុវណ្ណបតិមា ព្រោះហេតុនោះបានជាក្រមព្រះរាជវង្សទ្រង់ថ្វាយព្រះនាមថាសុវណ្ណកុមារ ។ លុះចំរើនវ័យវឌ្ឍនាការឡើងកាលណា មានព្រះឆោម

ល្អឆើតឆាយ មានព្រះកាយប្រកបដោយកម្លាំងច្រើន ចេះចប់សព្វវិជ្ជា ល្បីខ្ចរខ្ចាយដោយសិល្បធ្នូ ក្នុងគ្រាដែលមានព្រះជន្មគំរប់ ១៦ ព្រះវស្សា ។

ក្នុងឆ្នាំមួយ ព្រះរាជាជាបិតាទ្រង់ចាត់ឲ្យពួកពលសកលយោធាមកប្រជុំគ្នាត្រៀបត្រា ទើបទ្រង់ត្រាស់ចំពោះមហាសេនាបតីថា “ម្នាលព្រះស្គួនទាំងឡាយ, មហាសមុទ្រធំវែងឆ្ងាយល្វឹងល្វើយ មើលមិនឃើញកោះត្រើយ ពេញពាសដោយកែវសព្វប្រការ មានទំនងគួរឲ្យប្រាថ្នា យើងចង់យាត្រាទៅកំសាន្តឯមហាសមុទ្រនោះ យើងមុខជានឹងឃើញសេចក្តីអស្ចារ្យនៅនាសមុទ្រនោះមិនខាន ។” ទើបពួកសេនាយោធាក្រាបបង្គំទូលថា បពិត្រមហារាជ អំពីមុនមកយើងខ្ញុំទូលព្រះបង្គំទាំងឡាយក៏ពុំដែលបានឃើញមហាសមុទ្រនោះដែរ ។ លំដាប់នោះ ព្រះរាជាទ្រង់មានពួកពលសកលយោធាទាំង៤ក្រុមមានក្រុមសេនាទាហានជាដើម ចោមរោមជាបរិវារ ព្រមទាំងព្រះរាជបុត្រាមានសុវណ្ណកុមារជាប្រធាន ហែហមអមព្រះអង្គទៅតាមផ្លូវ ដែលដោតទង់ជាយទង់ជ្រងពាសពេញ; អាកាសវេហាស៍ ឮខ្ចរខ្ចាយដោយស័ព្ទភ្លេងតូរ្យតន្ត្រី អង្គប្រាំប្រការ, ទើបព្រះបរមរាជា ទ្រង់ស្តេចយាត្រាចេញទៅតាមបាចិនទិសជាមួយនឹងរាជកញ្ញាទាំងឡាយចំនួន ២ ម៉ឺនដូចជាដំណើរនៃព្រះឥន្ទ្រាធិរាជ ដែលស្តេចទៅកាន់នន្ទវនឧទ្យាន, ទ្រង់ស្តេចគគាតតាមហ្វូងហែ បែរព្រះភក្ត្រទតភូមិភាគប្រទេសនានាតាមមគ៌ាគួរឲ្យត្រេកអរ, នឹងសមុទ្រសាគរមានអង្គ ៤ ហើយមានព្រះរាជហឫទ័យពេញដោយបីតិ ទើបទ្រង់ត្រាស់បង្គាប់អាមាត្យទាំងឡាយថា នែអ្នកទាំងឡាយអើយ, ចូរបបួល

គ្នា លង់ក្នុងត្បូងត្រ្ទិ តាមសេចក្តីពេញចិត្តក្នុងទីនេះចុះ ។ ព្រះរាជានោះទ្រង់ក្រសាលក្នុងសមុទ្រអស់ប្រាំពីរថ្ងៃ ទ្រង់ក្រសាលល្បែងផ្សេងៗ នៅនាឆ្នេរមហាសមុទ្រ ដោយតេជានុភាពនៃព្រះមហាសត្វ សូម្បីសត្វសត្វពាឡយង់ឃ្នងមានក្រពើនឹងមក្ករជាដើម កំមិនហ៊ានបៀតបៀនអ្នកណាមួយឡើយ ។

ចំណែកខាងព្រះបរមពោធិសត្វ ទ្រង់ប្រាថ្នាដើម្បីសំដែងបុញ្ញានុភាពរបស់ព្រះអង្គ ទើបទ្រង់ព្រះចិន្តាថា កាលណាហ្ន៎! អាត្មាអញនឹងបានត្រេចទៅលើទឹកមហាសមុទ្រ ដូចជាត្រេចទៅលើផែនដីបាន ។ គ្រានោះពួកទេវតាដែលរក្សាសមុទ្រ កំនាំយកដំរីគជនូវរតន៍ មានរូបរាងសស្គុទ្ធ ប្រាកដជាដំរីមង្គល មកថ្វាយព្រះបរមពោធិសត្វ ក្នុងពេលដែលព្រះអាទិត្យរះឡើង ។ ព្រះបរមពោធិសត្វ កាលបានព្រះរាជយានដំឧត្តមហើយ កំមានព្រះរាជហឫទ័យរីករាយត្រេកអរ ទ្រង់ស្តេចទៅដោយព្រះរាជយានដំរីរតន៍ប្រពៃ ដូចស្តេចឡើងកាន់គជរតន៍. ក្នុងវេលាប្រកបដោយនក្ខត្តឫក្សល្អរុងរឿង ហាក់ដូចព្រះអាទិត្យពេញពន្លឺបិតនៅលើកំយុគន្ធរ ។ ឯពួកមហាជនបានឃើញហេតុអស្ចារ្យ ដែលមិនធ្លាប់កើតដូច្នោះហើយ ព្រឺរោមព្រឺស្បែក ក្រាបថ្វាយបង្គំព្រមៗគ្នា ។ ព្រះបរមពោធិសត្វ ស្តេចទ្រង់បរព្រះទីនាំងគជេន្ទ្រចូលក្នុងមហាសមុទ្រ ព្រមទាំងមហាជនពោមរោមហែហមជាបរិវារ ។ ឯដំរីគជសារនោះ បើមានមុខឆ្ពោះទៅត្រង់ណា, ទឹកសមុទ្រដែលសាមានប្រមាណ ៨៤ យោជន៍ក៏កំរើករំកើបបែកខ្ញែកជាពីរចំណែកដូចជាជញ្ជាំងផ្ទះ ។ ដោយបុញ្ញាតេជះ

ព្រះពោធិសត្វ មហាជនទាំងអស់គ្នាដែលដើរនៅកណ្ដាលសមុទ្រយ៉ាងនេះ ក៏ឥតមានត្រូវដំណក់ទឹកមួយគ្រាប់ឡើយ គួរឱ្យអស្ចារ្យ គួរឱ្យរីករាយពន់ពេកណាស់ ៗ សមុទ្ទកញ្ញាទាំងឡាយ បានឃើញពួកមហាជនមកកាន់មហាសមុទ្រដូច្នោះ ក៏រកយកយល់អិតគន្ធពិដោរ យកផ្កាកម្រងមកបង្ហាញព្រះបរមពោធិសត្វ ហើយទៅចាំស្កាត់ពាក់កណ្ដាលផ្លូវនោះ យកកែវមណីសត្តប្រការ មករចនាជាផ្កាចង្កោមមាស ៥ ពណ៌ ព្យួរនៅទីទាំងសងខាងនៃជញ្ជាំងទឹក ៗ ឯស្ដេចនាគកដ ព្រមទាំងស្រីបុំទាំងប៉ុន្មានមកះហមកេមជុំវិញ ៗ ពោធិសត្វ ទ្រង់សោយភោជនាហារដែលពួកសមុទ្ទកញ្ញា នឹងនាគកដកញ្ញារៀបចំថ្វាយទ្រង់សោយសម្បត្តិហាក់ដូចជាសម្បត្តិទិព្វគ្រប់ប្រការក្នុងមហាសមុទ្រនោះអស់ប៉ីថ្ងៃ ។

លំដាប់នោះ ព្រះវរពជមាតាបិតាទាំងឡាយ កាលដែលព្រះរាជបុត្រស្ដេចចេញទៅយូរពេក ទ្រង់បញ្ជូនអាមាត្យឱ្យទៅតាមថា នៃព្រះស្ដេចទាំងឡាយ, ចូរឯងទៅតាមយកកូនអញមកវិញ ៗ ឯពួកអាមាត្យសោត ក៏ទៅកាន់មហាមុទ្របានដូចជាផ្លូវមនុស្សដែរ ព្រោះតែគេជះព្រះបរមពោធិសត្វ, ទើបថ្វាយបង្គំទូលសព្វសេចក្ដី ៗ ព្រះពោធិសត្វទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទ្រង់ត្រាស់ថា "ល្អហើយៗអាមាត្យ" ៗ ទើបទ្រង់ត្រាស់ហៅពួកសមុទ្ទទេវតា នឹងពួកនាគកដមកថា នែអ្នកទាំងឡាយ យើងលាអ្នកទាំងឡាយហើយ, ព្រោះព្រះវរពជមាតាបិតាយើងនៅឆ្ពោះសមុទ្រឯណោះទ្រង់បញ្ជូនរាជសារមកដល់យើងៗ លំដាប់នោះ សមុទ្ទទេវតាទាំងឡាយ ក៏នាំគ្នាមកថ្លែងទុក្ខថា "នុ ហ្ន

មុខគួរឲ្យស្តាយជីវិតរបស់យើងទាំងឡាយ រស់នៅឥតផលសោះ ព្រោះបីបាច់ថែរក្សាអ្នកណា អ្នកនោះទៅចោលឥតស្រណោះ" ទើបថ្វាយរបស់ផ្សេង ៗ ដល់ព្រះបរមពោធិសត្វថា សូមព្រះអង្គឲ្យពួកអាមាត្យខ្ញុំកេរ៍ឃោសនាប្រាប់មហាជនថា អ្នកណាត្រូវការកែវមណី ចូរមកយកចុះកុំបង្អង់ ។ ពួកកងទ័ពទាំងអស់ឮដូច្នោះ ក៏ត្រេកអរសោទរជាពន្លឹក ហើយបររទេះសេះដំរីតត្រឹកជីកស្ទូចកែវមានខ្លឹមសារ ពេញការុងកន្ត្រោង ហើយថ្លែងគុណព្រះបរមពោធិសត្វទៀតថា ព្រះនាងចន្ទទេវីជាស្រីប្រកបដោយផល, ព្រះរាជាសោត ក៏ជាបុគ្គលប្រកបដោយផលដែរ, ដែនរបស់យើង ក៏ប្រកបដោយផលដែរ ។

ព្រះសុវណ្ណកុមារ បង្គាប់មនុស្ស ឲ្យយកកែវមានខ្លឹមសារសព្វគ្រប់ប្រការ ហើយទើបទ្រង់ស្តេចយាត្រាត្រឡប់ទៅជាមួយមហាជន ក្រាបថ្វាយបង្គំព្រះវរមាតាបិតាបូជាកែវមានខ្លឹមសារទាំងអស់ ទឹងគ្រឿងប្រដាប់ប្រដាទាំងឡាយ ។ គ្រានោះ ព្រះរាជានឹងព្រះនាងទេវីទ្រង់ទតឃើញកែវមានខ្លឹមសារដែលទ្រង់មិនធ្លាប់ឃើញអំពីដើម ក៏មានព្រះរាជហឫទ័យរីករាយ ចាប់បបោសអង្អែលព្រះសុវណ្ណកុមារ ផ្ទុកលើព្រះទ្រូង ទ្រង់ត្រាស់សរសើរបុណ្យសព្វគ្រប់ប្រការ ។

ព្រះរាជាទ្រង់ទទួលរតនវត្ថុទាំងនោះហើយ ទ្រង់បញ្ជូនព្រះសុវណ្ណ-កុមារឲ្យឡើងដំរីមង្គលមានសំបុរសសុទ្ធ មានពួកពលសកលយោធាទាំង ៤ ក្រុម ហែហមអមព្រះអង្គទៅមុខ, ទើបព្រះអង្គទ្រង់ស្តេចទៅតាមក្រោយ, កាលទ្រង់ទតឃើញសិរីសម្បត្តិរបស់ព្រះសុវណ្ណកុមារហើយ

កំពេញព្រះរាជហឫទ័យពន់ពេកណាស់ ។ គ្រានោះ ពួកទេវតាយករតនៈសួយសារអាករអំពីឋានតាវតឹង្ស មកបំពេញកន្ទុងមានជង្រុកជាដើម ឲ្យពេញឥតខ្វះកន្ទះអ្វីឡើយ ទើបនាំគ្នាត្រឡប់ទៅវិញ ។ នគរនោះ ដែលមានដំរីគេជន្ទួនរន្ទួតជសារ កំហាក់ដូចជានគរព្រះសហស្សន័យឥន្ទ្រាធិរាជ ដែលអាចសម្រេចកិច្ចគ្រប់យ៉ាង ដោយសារសំណាងតេជានុភាពព្រះបរមពោធិសត្វ ។

សួរថាចុះហេតុអ្វី បានជាព្រះបរមពោធិសត្វ បានរតនៈសួយសារអាករគ្រប់យ៉ាងអំពីសមុទ្រដូច្នេះ ។ ឆ្លើយថា ក្នុងកាលកន្លងទៅហើយព្រះបរមពោធិសត្វ កើតជាបុត្រសេដ្ឋីនៅក្នុងក្រុងពារាណសី មានរូបឆោមល្អ មានចិត្តក្រៀវក្លាប្រាជ្ញាវៃតែឲ្យទាន ។ ថ្ងៃមួយមានអគ្គសាវ័កព្រះពុទ្ធវិបស្សី ១ អង្គ កំពុងត្រេចទៅបិណ្ឌបាត ។ បុត្រសេដ្ឋីនោះក្រឡេកឃើញឥរិយាបថលោកស្រគត់ស្រគំរម្យទម្យល្អគួរឲ្យជ្រះថ្លា កំយកបាតមកបំពេញដោយភោជនាហារ ទើបជូនទឹកស្មោទកទូលថា បពិត្រព្រះករុណាដ៏ចំរើន, សូមព្រះករុណាទទួលភត្តជានិច្ចក្នុងផ្ទះខ្ញុំកុំខាន ។ ព្រះថេរៈកំទទួលប្រេជ្ញាហើយកំនិមន្តចេញទៅ ។ តមកថ្ងៃមួយ ព្រះថេរៈធ្វើអនុមោទនាក្នុងវេលារូបភត្តកិច្ចដោយបទគាថាថា:

ន កោធញ្ញូ បញ្ញវេរំ គរុភាវំ ករោន្តិ យេ
តេ តិវិធញ្ញូ សម្បត្តិំ លភន្តិ ពុទ្ធសេវិតន្តិ ។

ជនទាំងឡាយឯណា មិនធ្វើនូវសេចក្តីក្រោធផង, នូវ
វេរទាំង ៥ ផង, នូវសំដីធ្ងន់ផង, ជនទាំងឡាយនោះ

រមែងបានសម្បត្តិ ៣ ប្រការ ដែលព្រះពុទ្ធជាសាស្តាទ្រង់សេពហើយ ។

បុត្រសេដ្ឋីបានស្តាប់ដូច្នោះហើយ ក៏មានបីតិផ្សព្វផ្សាយពេញសព្វាង្គកាយ ទើបថ្វាយបង្គំទូលថា ល្អហើយៗ ព្រះគុណម្ចាស់, ខ្ញុំសូមយកលោកម្ចាស់ជាទីពឹងស្មើជីវិត, ចាប់តាំងពីថ្ងៃនេះតទៅ សូមលោកម្ចាស់ជាអាចារ្យប្រដៅធម៌អាថ៌ដល់ខ្ញុំព្រះករុណា ជានិច្ចកុំឲ្យខានឡើយ ។ ព្រះថេរក៏ទេសនានិច្ចធម៌ឲ្យស្តាប់ ។ សេដ្ឋីបុត្រក៏ប្រព្រឹត្តតាមឱវាទព្រះថេរតរៀងទៅ ។

កាលនោះ មានពួកឈ្មួញសំពៅទាំង ៥០០ បើកក្តោងចេញពីនគរនោះ សំដៅទៅសីហឡទ្វីប ដើម្បីជួញប្រែ ក៏ដំណាលសរសើរសិរីសម្បត្តិព្រះសុវណ្ណកុមារ នឹងដំរីគជសារតែពល់ៗមាត់ ។ អ្នកសីហឡទ្វីប ក៏នាំសេចក្តីនោះទៅក្រាបបង្គំទូលព្រះបាទកេជសុរាជ ។ ព្រះរាជាអង្គនោះ បានទ្រង់ព្រះសវនាការពុំដំណឹងនោះហើយ ទ្រង់ព្រះពិរោធក្រេវក្រោធមហិមា ទើបត្រាស់ហៅពួកឈ្មួញនាវាមកសួរ ។ ពួកឈ្មួញក្រាបបង្គំទូលថា ៈ " បពិត្រព្រះរាជសម្ភារ, ព្រះរាជបុត្ររបស់ព្រះរាជា ជាម្ចាស់ខ្ញុំព្រះអង្គទាំងឡាយព្រះនាមព្រះសុវណ្ណកុមារ មានឫទ្ធិច្រើនចំរើនមានអានុភាពធំ អាចញាំញីនូវសេនាស្តេចដទៃបាន សូម្បីទុកជាមហាក្សត្រទាំង ១០១ ក៏មិនហ៊ានឈមព្រះភក្ត្រទៅរកព្រះអង្គដែរ បពិត្រព្រះរាជសម្ភារ ព្រះរាជបុត្រមានអានុភាពធំយ៉ាងនេះៗ ព្រះរាជានោះលុះទ្រង់ព្រះសណ្តាប់ពាក្យពាណិជហើយ ក៏រឹតតែទ្រង់ព្រះពិរោធដូចជា

នាគកជ ដែលគេប្រហារគន្ធយដោយដំបងដែក ទើបត្រាស់ហៅយោធាទាំង ៤ នាក់ ដែលក្លៀវក្លា អាចសម្រេចកិច្ចសព្វប្រការបាន មកបង្គាប់ថា ចូរព្រះស្តេងទៅនគរពារាណសី ជាមួយនឹងពួកពាណិជទាំងនេះ ហើយប្រាប់ស្តេចមហាកត្តកជថា ព្រះបាទកដេសុរាជ នៅសីហឡទ្វីបមានអានុភាពច្រើន គេជះច្រើន ពលច្រើន ពួកស្តេចដទៃតែងបូជាទាំងដីរសោតក៏មានកំឡាំងក្លៀវក្លា ឥតមានអ្នកណាស្មើឡើយ ហេតុដូច្នោះ ចូរព្រះអង្គនាំយកដីរសសុទ្ធ ដែលប្រកបដោយលក្ខណៈគ្រប់ប្រការទៅ ថ្វាយព្រះរាជាជាម្ចាស់យើងនោះ, បើមិនដូច្នោះទេ មុខជាព្រះរាជានោះនឹងធ្វើនគរពារាណសី ឲ្យខ្ទេចខ្ទីដល់ទូរសេចក្តីទុក្ខលំបាកមិនខាន ៗ ពួកយោធាទាំង ៤ នាក់នោះ ក៏ទទួលព្រះរាជឱង្ការ ចេញទៅដល់នគរពារាណសី ជាមួយនឹងពួកឈ្មួញ ទូលព្រះបាទមហាកត្តកជសព្វសេចក្តី ៗ ព្រះបាទមហាកត្តកជព្រះចៅក្រុងពារាណសី ក៏ភិតភ័យតក់ស្លុតមហិមា ម្ល៉ោះត្រាស់ហៅពួកសេនាបតី ឧបរាជ បុរោហិត ព្រះរាជបុត្រាមកប្រាប់ថា ស្តេចកដេសុរាជ មានពលច្រើន មានអានុភាពច្រើនឲ្យយោធាមកហៅខ្ញុំទៅ, តើដំណើរនេះជាគួរទៅឬមិនគួរ? ចូរអ្នកពល់គ្នាពិចារណាហើយប្រាប់ខ្ញុំឲ្យឆាប់ៗ ៗ ពួកសេវកាមាត្យទាំងនោះ គ្រាន់តែឮដូច្នោះ ក៏ភិតភ័យភាំងស្មារតីនៅស្ងៀមតែរៀងខ្លួន ៗ ចំណែកខាងព្រះសុវណ្ណកុមារ ឮថាព្រះវរបិតាមានទុក្ខព្រួយព្រះរាជហឫទ័យដូច្នោះ ក៏ក្រាបបង្គំទូលថា បពិត្រព្រះវរបិតា, សូមទ្រង់កុំបារម្ភឡើយ, សូមទ្រង់គង់ជាសុខចុះ ធានាលើខ្ញុំព្រះអង្គ នឹងទៅនាំស្តេចកដេសុរាជព្រម

ទាំងពួកពលសកលយោធាឲ្យមកក្រាបថ្វាយបង្គំព្រះបាទព្រះអង្គបាន ។ ទើបព្រះរាជបិតាត្រាស់តបទៅវិញថា ហៃកូនពុំងា, កូនឯងក្មេងណាស់ ស្តេចកេដសុរាជនោះ មានអានុភាពខ្លាំងតេជះច្រើន. ដែនរបស់គេសោត គឺធំណាស់ផង, យោធាទាហានគេសោត ក៏ក្លៀវក្លាណាស់, បាឯងអាចទៅនាំស្តេចនោះមកដូចម្តេចបាន ។ ព្រះសុវណ្ណកុមារ ក្រាបបង្គំទូលថា បពិត្រព្រះវរបិតា. សូមទ្រង់កុំមានព្រះរាជទុក្ខរដូច្នោះឡើយ! បើទុកជាស្តេចកេដសុរាជ មានពួកពលសកលយោធាក្លៀវក្លាដល់ម្ល៉េះក៏ដោយ, ក៏គង់ខ្ញុំព្រះអង្គគ្រប់សង្កត់ដោយតេជះបានដែរ ។ ឯពួករាជ-អាមាត្យ បានស្តាប់ព្រះបន្ទូលព្រះសុវណ្ណកុមារដូច្នោះហើយ ក៏មានបីតិផ្សព្វផ្សាយពេញទាំងសរីរកាយ ថ្វាយសព្ទសាធុការពរដល់ព្រះរាជ-កុមារថា សាធុ សាធុ បើព្រះអង្គទ្រង់ស្តេចទៅហើយ មុខជាបានសម្រេចការតាមប្រាថ្នាពុំខាន ។ ឯព្រះមហាក្សត្រក៏មានព្រះបន្ទូលយ៉ាងនេះថា ត្រូវហើយកូន គួរបាទៅចុះ ។ ក្នុងខណៈនោះឯង ព្រះមហា-ក្សត្រ ក៏ទ្រង់បាត់ឲ្យយកគ្រឿងកកុធភណ្ឌទាំង ៥ គឺ ស្វេតច្ឆត្រ, ព្រះចាមរ, មកុដ, ព្រះខ័ន, ព្រះសុវណ្ណបាទុកា ហើយទ្រង់អភិសេកព្រះរាជកុមារ ។ ព្រាហ្មណ៍បុរោហិត បណ្ឌិត ករ អង្គុយជិតជុំវិញ យកក្អមមាសដាក់ទឹកពេញៗ ដំកល់ទុកត្រៀបត្រា. បញ្ឈរដើមអំពៅ ដើមចេកដោតទង់ជ័យទង់ជ្រុងគ្រប់ទិសទាំងប្រាំបី ទើបព្រះចក្រិទ្រង់ធ្វើគំនរកែវដែលមានរស្មីក្នុងកណ្តាលដំណាក់មាស មានទុភាសក្តីអស្ចារ្យ, ទើបឲ្យព្រះសុវណ្ណកុមារ ទ្រង់គ្រឿងកកុធភណ្ឌទាំង៥គង់ក្នុង

ដំណាក់មាសនោះ, ពួកជនចាស់ៗក្នុងនគរនោះ ថ្វាយស័ព្ទសាធុការ
អភិសេកព្រះសុវណ្ណកុមារឱ្យសោយរាជ្យឡើង ។ ព្រះរាជកុមារ លុះ
បានរាជាភិសេកហើយ មានពួកចតុរង្គសេនាហែហមដង្ហែព្រះអង្គ
ចេញទៅ ក្នុងវេលាប្រកបដោយនក្ខត្តឫក្សល្អ ។ ក្បួនទ័ពព្រះរាជាគួរ
ឱ្យសំបើមអស្ចារ្យ គ្រឿបគ្រាដោយស្វេតច្ឆត្រក្ងស់ក្ងំអភិរម្យ ទង់ជ័យ
សំពោងព្រោងព្រាត ដូចជាផ្កាយលើអាកាស ។ គ្រាដែលព្រះរាជា
ចេញចាកព្រះនគរទៅនោះ ក្នុងពេលប្រកបដោយនក្ខត្តឫក្សជាំជ័យមង្គល
មានជំនះ ៧ ជាន់ មានពួកពលសកលយោធាហែពីខាងមុខ ទ្រង់គង់
លើខ្នងព្រះទីនាំងគជេន្ទ្រជាមង្គលមានសម្បុរសសុទ្ធ ជាព្រះរាជពាហនៈ
ដ៏ប្រសើរ អាចញាំញីនូវពួកសត្រូវបច្ចាមិត្តក្នុងមណ្ឌលសីហឡទ្វីប
បាន ជាដំរីមានអវយវៈធំ ដែលគេតាក់តែងវិចិត្រដោយគ្រឿងប្រាក់
មាសខ្សែរយទឹងកែវមណី មានពួកបណ្ដាជនបើកបាំងដោយក្ងស់ទឹង
ស្វេតច្ឆត្រជុំរុងរឿង មានពួកសេនាយោធាទាហានតម្រៀបជាជួរជាជាន់
ដោយពួកដោយកង ដៃកាន់ដំបង កាន់ដាវ កាន់ព្រះខ័ន កាន់លំពែង
ស្នែងគ្រប់ មានតូរ្យតន្ត្រី ត្រែ ស័ង្ខ រគាំង គោរ បន្លឺឡើងទ្រហឹងអឹងអាប់
តាន់តាប់ដោយទង់ដែលវិចិត្រដោយរូបផ្សេងៗ ព្ទសូរស័ព្ទសំឡេងពួក
ព្រាហ្មណ៍ព្រឹទ្ធបុរោហិតកវីស្រែកថ្វាយពរជ័យ ព្រះចក្រីទ្រង់មានពួក
សេនាយោធាហែហមជាបរិវារ ទ្រង់ធ្វើព្រះរាជគមនាការចេញចាកក្រុង
ភាពណសីក្រុងរាជធានីឆ្ពោះសំដៅទៅទីសីហឡទ្វីប ។

(មានត)

# ផ្នែកអក្សរសាស្ត្រ

## កម្លាំងនៃសាមគ្គី

និទានសុភាសិតរឿងតបួកសូករៈ

ព្រះមហា ម៉ៅ-ខាន់ ក្រុមជំនុំព្រះត្រៃបិដក រៀបរៀង

---

សាមគ្គី គឺសេចក្តីព្រមព្រៀងនៃជនអ្នកនៅរួបរួមគ្នាជាពួកជាសង្គម ដោយជឿស្តាប់បង្គាប់បញ្ញាទឹងទាំង របស់អ្នកដែលជាប្រធាន ស្រុះចិត្តគ្នាដើរតាមក្រោយដោយសេចក្តីគោរព ជាកម្លាំងអាចប្រកាសនូវគារវៈរឹងប៉ឹង មាំមួន នៃពួកសង្គម ឲ្យជាទីកោតខ្លាចដល់ពួកសត្រូវនានា អាចការពារភយន្តរាយដ៏កំណាច នឹងបង្រាបឲ្យបាក់បបដោយរៀបរយ ញុាំងសេចក្តីសុខក្សេមក្សាន្ត រុងរឿងឲ្យកើតមានឡើង ដូចរឿងតបួកសូករៈ ដែលនឹងនាំមកពណ៌នាទុកជាទស្សនៈតទៅនេះ ៖

ក្នុងអតីតកាល មានជាងឈើម្នាក់ តាំងគ្រឹះបិកហានៅស្រុកមួយក្បែរទ្វារក្រុងពារាណសី ។ ថ្ងៃមួយជាងឈើនោះចូលទៅកាន់ព្រៃដើម្បីរកឈើមកធ្វើការរបស់ខ្លួន បានឃើញកូនជ្រូកមួយតូចធ្លាក់ទៅក្នុងអណ្តូង ក៏ចាប់យកមកចិញ្ចឹមទុក ឲ្យឈ្មោះតបួកសូករៈ ។ តបួកសូករៈនោះ បានធ្វើការជួយកម្លាំងជាងឈើជាច្រើន គឺជួយព្រមៀលឈើដោយច្រមុះ ជួយលាតខ្សែបន្ទាត់ដែលម្ចាស់បង្គ្រង់ច្រមុះ ពាំកាំបិត ពន្លាក ពូថៅ ញញួរទៅឲ្យ លុះជ្រូកនោះធំឡើងក៏មានកម្លាំងច្រើន មានខ្លួនធាត់ធំ ៗ ជាងឈើបានតាំងមេត្តាចិត្តអាណិតស្រឡាញ់ទុកស្មើកូនរបស់ខ្លួន ខាង

ក្រោយមកគិតថា បើទុកជ្រូកនេះឲ្យនៅក្នុងទីនេះតទៅ មុខជាមានអ្នកណាមកបៀតបៀន ទើបនាំទៅលែងក្នុងព្រៃ ។ តច្ចកសូករៈគិតថា អាត្មាអញមិនអាចនៅក្នុងព្រៃតែម្នាក់ឯងបានទេ ត្រូវតែស្វែងរកញាតិមិត្រមករួបរួមគ្នា តាំងជាឡាក់ហានទៅទើបបាន គិតហើយក៏ត្រាច់ដើរស្វែងរកទៅតាមព្រៃញាតស្បាត កាលបានប្រទះហ្វូងជ្រូកជាច្រើនក៏មានសេចក្ដីត្រេកអរ ទើបពោលថា យើងត្រាច់ដើរស្វែងរកពួកញាតិឯណាតាមព្រៃភ្នំគ្រប់ទាំងឡាយ ឥឡូវនេះយើងបានជួបប្រទះពួកញាតិទាំងនោះហើយ មើមឈើ ផ្លែឈើក៏មានច្រើន ព្រៃភ្នំនឹងទឹកស្ទឹងក៏គួរជាទីរីករាយអាចនឹងបានសុខសម្រាន្តជាប្រាកដ យើងនឹងនៅជាមួយញាតិទាំងឡាយក្នុងទីនេះ ហើយនឹងមិនខ្វល់ខ្វាយ មិនរង្កៀស មិនសោយសោក មិនគិតខ្លាចអ្វីតទៅ ។

ជ្រូកទាំងឡាយ បានឮពាក្យតច្ចកៈហើយ ទើបពោលថា ម្នាលតច្ចកៈ; អ្នកចូរទៅរកទីជ្រកពួនដទៃវិញទៅ ព្រោះទីនេះសត្រូវរបស់ពួកយើងមាន វាធ្លាប់មកសម្លាប់កូនជ្រូកក្នុងទីនេះស៊ីជានិច្ច ។

តច្ចកសូករៈសួរថា នរណាហ្ន៎ ជាសត្រូវពួកយើងក្នុងទីនេះ? នរណាមកញាំញីកំចាត់ពួកញាតិអ្នកព្រមព្រៀងគ្នា ដែលគេកំចាត់បានដោយក្រ? អ្នកចូរប្រាប់សេចក្ដីដែលយើងសួរនេះមកចុះ ។

ជ្រូកទាំងឡាយឆ្លើយថា ម្នាលតច្ចកៈ មានស្ដេចខ្លាមួយក្រឡាពាក់បន្ទំ ជាសត្វមានកម្លាំង មានចង្កូមជាអាវុធ វាធ្លាប់មកសម្លាប់ជ្រូកក្នុងទីនេះស៊ីជានិច្ច ។

តច្ចកសូករៈពោលថា ទោះបីពួកយើងមិនមានចង្កូមតូចមាំមួន ក៏គង់មានកម្លាំងកាយបរិបូណ៌ដែរ បើប្រសិនជាស្រុះចិត្តគ្នាទាំងអស់ហើយ ក៏អាចនឹងចាប់សត្វមានចង្កូមមានកម្លាំងមួយឲ្យនៅក្នុងអំណាចបាន ។

ជ្រូកទាំងឡាយពោលថា ម្នាលតច្ចកៈ អ្នកពោលពាក្យចាប់ចិត្តចាប់ថ្លើមសប្បាយត្រៀក (អើពួកយើងសុខចិត្តស៊ូ) ក្នុងពេលច្បាំង បើអ្នកណារត់គេច ពួកយើងនឹងនាំគ្នាសម្លាប់អ្នកនោះចោលក្នុងខាងក្រោយៗ

តច្ចកសូករៈទូន្មានជ្រូកទាំងឡាយ ឲ្យសាមគ្គីរួមគ្នាជាចិត្តមួយ ហើយទើបសួរថា ខ្មាំងមកពេលណា? ។ ជ្រូកទាំងឡាយប្រាប់ថា ថ្ងៃនេះវាមកចាប់យកជ្រូកមួយតាំងពីព្រឹកទៅហើយ ព្រឹកស្អែកទើបវាមកទៀត ។ តច្ចកសូករៈជាសត្វឈ្លាសក្នុងការច្បាំង កំណត់ដឹងទីជ័យភូមិថា នៅទីនេះមិនអាចនឹងយកជ័យជំនះបានទេ ព្រោះហេតុនោះ ទើបគាត់ដើរជ្រើសរើសរកភូមិប្រទេសបានមួយកន្លែង ឲ្យជ្រូកទាំងឡាយរកអាហារស៊ីឲ្យឆ្អែតក្នុងវេលារាត្រី ហើយនិយាយពន្យល់ថា ធម្មតាក្បួនចម្បាំងមាន ៣ គឺៈ សកដព្យូហៈ (ក្បួនទ័ពរទេះ) ១ ចក្រព្យូហៈ (ក្បួនទ័ពកង់) ១ និង បទុមព្យូហៈ (ក្បួនទ័ពស្រទាប់ផ្កាឈូក) ១ រួចហើយទើបតាំងក្បួនបទុមព្យូហៈ តាំងពីពេលព្រឹក គឺរៀបដាក់ហ្វូងជ្រូកទុកជាជាន់ៗ ដូចត្របកឈូក ឲ្យកូនជ្រូកដែលនៅបៅនៅត្រង់កណ្ដាល, ឲ្យមេជ្រូកទាំងនោះនៅព័ទ្ធជុំវិញ ហើយចាត់ឲ្យជ្រូកញីដែលមានអាយុយ៉ាងកណ្ដាលៗ ព័ទ្ធហ៊ុមមួយជាន់ទៀត, ត្រង់ចន្លោះៗ ជ្រូកញីទាំងនោះ ចាត់ឲ្យកូនជ្រូកដែលលែងបៅដោះ និងជ្រូកស្ទាវៗ មានចង្កូមតូចជ្រូកនៅ

តាមចន្លោះៗទៀត, ក្នុងចន្លោះជ្រូកបង្កមតូចៗ មានជ្រូកបង្កមធំៗ នៅប្រចាំការពារ, ក្នុងចន្លោះជ្រូកបង្កមធំៗ មានជ្រូកចាស់ជ្រូកនៅជារយៈៗទៀត ហើយដាក់ជ្រូកដែលមានកម្លាំងទុកក្នុងទីផ្សេងៗជាពួកៗ មួយពួក ១០ ខ្លះ ២០ ខ្លះ ៣០ ខ្លះ ហើយឲ្យនាំគ្នាជីករណ្តៅសម្រាប់លាក់ខ្លួន, មួយរណ្តៅ ជីកជារបាំងមានសណ្ឋានដូចជាបង្អួរ មួយរណ្តៅទៀត ក្នុងចន្លោះរណ្តៅទាំងពីរនេះ ឲ្យធ្វើរូបស្រដៀងតាំងដែលខ្លួនជ្រូកអាស្រ័យស្រេចហើយ ក៏នាំជ្រូកអ្នកច្បាំងដែលខ្លាំងពូកែទាំងឡាយត្រាច់ដើរដាស់ទឹកចិត្តជ្រូកទាំងឡាយដែលចាត់ទុកក្នុងទីផ្សេងៗ ៗ កាលតបូកៈសូករៈចាត់ត្រៀមការច្បាំងយ៉ាងនេះ ក៏ល្មមពេលព្រះអាទិត្យបញ្ចេញរស្មីរះឡើងមក ៗ

លំដាប់នោះ ព្យគ្ឃរាជក៏ចេញចាកអាស្រមនៃជដិលៈកោង មកឈរនៅនាចន្លោះភ្នំ ជ្រូកទាំងឡាយប្រាប់ដល់តបូកៈថា លោកជំទើន គូវេររបស់ពួកយើងមកហើយ ៗ តបូកៈទើបប្រាប់ថា អ្នកទាំងឡាយកុំខ្លាចឡើយ បើខ្លាធំនោះធ្វើអាការយ៉ាងណា អ្នកទាំងឡាយគប្បីធ្វើយ៉ាងនោះ សំដែងឲ្យដឹងថាជាប្រតិបក្សរបស់វា ៗ ខណៈនោះ ខ្លាធំរលាស់កាយបន្ទន់ខ្លួនចុះបន្តិច ហើយបន្ទោបស្សាវៈ ៗ ចំណែកពួកជ្រូកក៏ធ្វើត្រាប់ដូច្នោះ ៗ ខ្លាធំក្រឡេកឃើញជ្រូកទាំងឡាយ ហើយក៏បន្លឺសំឡេងគំរាម ៗ ចំណែកពួកជ្រូកក៏បន្លឺសំឡេងតាមខ្លាដែរ ៗ ខ្លាធំសំឡឹងឃើញកិរិយារបស់ពួកជ្រូកដូច្នោះ ទើបគិតថា ‹‹ជ្រូកទាំងនេះមិនដូចពីថ្ងៃមុនៗសោះ ថ្ងៃនេះគង់ជាសត្រូវចំពោះអញជាប្រាកដ

បានជាវាំនាំគ្នាឈរនៅជាពួក ឃើញថាមាននាយកមកជួយចាត់ការ ថ្ងៃនេះអាត្មាអញមិនគួរចូលទៅជិតជ្រូកទាំងនេះទេ" គិតហើយក៏ខ្លាចនូវសេចក្ដីមរណៈ ទើបត្រឡប់ទៅកាន់សំណាក់នៃជដិលកោងវិញ ។

លំដាប់នោះ ជដិលកោងឃើញខ្លាធំមកដៃទទេ ក៏ពោលថា ម្នាលព្យគ្ឃរាជ អ្នកក្លាហាន ថ្ងៃនេះប្រហែលជាអ្នកលះវៀរបាណាតិបាត អ្នកឲ្យអភ័យដល់សត្វទាំងឡាយស្មោះហើយឬ៖ ឬចង្កូមនឹងក្រចករបស់អ្នកមិនមានទៅហើយ អ្នកចូលទៅដល់កណ្ដាលហ្វូងជ្រូកហើយ ម្ដេចក៏ត្រឡប់មកសញ្ជប់សញ្ជឹងស្ងប់សៅគួរឲ្យអាសូរដូច្នេះ ។

ខ្លាធំពោលតបថា មិនមែនចង្កូមនឹងក្រចករបស់ខ្ញុំករុណាមិនមាននោះទេ ទាំងកម្លាំងកាយក៏មានបរិបូណ៌ព្រម ប៉ុន្តែខ្ញុំករុណាក្រឡេកឃើញពួកជ្រូកព្រមដោយញាតិប្រជុំនៅក្នុងទីជាមួយគ្នា ព្រោះហេតុនោះបានជាខ្ញុំករុណាមកសញ្ជប់សញ្ជឹងស្ងប់សៅ តែម្នាក់ឯងនៅក្នុងព្រៃ, តាមដែលធ្លាប់បានដឹងឃើញមកពីមុន ។ ជ្រូកទាំងនេះគ្រាន់តែក្រឡេកឃើញខ្ញុំករុណា ក៏ធ្លាក់ទឹកមុខនាំគ្នាបោលខ្ចាត់ខ្ចាយទៅក្នុងទិសតូច-ធំ រកទីជ្រកអាស្រ័យ ប្លែកអីថ្ងៃនេះវាព្រមព្រៀងមូលត្រកូលជាពួកឈរនៅក្នុងទីដែលខ្ញុំករុណាមិនងាយនឹងញាំញីវាបាន វាមាននាយកបង្គាប់ការព្រមព្រៀងគ្នាជាពួកក្រុម គង់នឹងបៀតបៀនខ្ញុំករុណាជាប្រាកដ បានជាខ្ញុំករុណាមិនប្រាថ្នាជ្រូកទាំងនោះ ។

ជដិលកោងស្ដាប់ដូច្នោះ កាលនឹងធ្វើឲ្យខ្លាធំកើតឧស្សាហ៍ ទើបពោលថា ព្រះឥន្ទ្រតែមួយអង្គប៉ុណ្ណោះ អាចឈ្នះពួកអសុរដ៏ច្រើនបាន

អជ្ឈប្បាតកសត្វ ( សត្វគេស៊ីធាប ) ត្រឹមតែមួយប៉ុណ្ណោះក៏អាចញាំញី សម្លាប់សត្វស្លាបទាំងហ្វូងបាន, ខ្លាធំតែមួយទៅដល់កណ្ដាលហ្វូងម្រឹគក៏អាចសម្លាប់ម្រឹគដែលធ្លាញ់ៗ បាន ព្រោះកម្លាំងរបស់ខ្លា យ៉ាងហ្នឹងឯង ។

ខ្លាធំពោលបញ្ជាក់ថា អ្នកដែលមានញាតិព្រមព្រៀងមូលត្រកូលគ្នា ព្រះឥន្ទ្រមិនអាចធ្វើឲ្យនៅក្នុងអំណាចបានឡើយ អជ្ឈប្បាតកសត្វក៏ធ្វើឲ្យនៅក្នុងអំណាចពុំបាន ទោះបីខ្លាធំដែលជាអធិបតីនៃពួកម្រឹគ ក៏ធ្វើឲ្យនៅក្នុងអំណាចមិនបាន ខ្លាធំមិនអាចធ្វើសត្វដែលមានញាតិព្រមព្រៀងមូលត្រកូលគ្នាឲ្យនៅក្នុងអំណាចបានឡើយ ។

ជដិលគោង កាលញុះញង់បញ្ជោរឲ្យខ្លាកើតឧស្សាហ៍ទៀត ទើបពោលថា បក្សីតូចទាំងឡាយមានឈ្មោះថាកុក្កិល ជាបក្សីត្រាច់ហើរទៅជាហ្វូង រមែងរីករាយសប្បាយចិត្ត ហើរទៅក្នុងអាកាស សញ្ចរកអាហារជាក្រុមៗ កាលហ្វូងបក្សីទាំងនោះនៅមូលគ្នាជាពួក បើមានបក្សីណាមួយម្នាក់ចេញទៅក្រៅហ្វូង ខណៈនោះអជ្ឈប្បាតកសត្វ រមែងឆាបយកបក្សីនោះ, យ៉ាងនេះជាផ្លូវឧបាយរបស់ពួកខ្លាធំ ។ កាលជដិលគោងពោលដូច្នេះហើយ ទើបញុះញង់បញ្ជោរជាឧបាយដាស់ចិត្តទៅថា ម្នាលព្យគ្ឃរាជ អ្នកមិនទាន់ដឹងកម្លាំងកំហែងរបស់អ្នកឯងទេ កុំក្រែងខ្លាចឡើយ ចូរគ្រោមដោយសាម្ញង ហើយស្ទុះដម្រង់ទៅតែប៉ុណ្ណោះ ពួកជ្រូកក៏នឹងនៅរួមគ្នាមិនបាន នឹងត្រូវខ្ចាត់ខ្ចាយជាប្រាកដ ។

ខ្លាធំជាសត្វមានចង្កូមនឹងក្រចក ត្រូវជដិលលោភសំឡឹងចំពោះអាមិស ញុះញង់បញ្ជោរឲ្យកើតសេចក្ដីអង់អាច ក៏ស្ទុះសំដៅទៅក្នុង

ហ្វូងជ្រូកដែលមានចង្កូមដូចគ្នា ដោយគិតសំគាល់ថាខ្លួនធ្វើបានដូចពីមុនៗ មក ។

ជ្រូកទាំងឡាយបានឃើញទើបប្រាប់ដល់តច្ឆកៈថា លោកនាយ ! អាចោរចង្រៃមកទៀតហើយ ។ តច្ឆកសូករៈលួងលោមថា "អ្នកទាំងឡាយកុំខ្លាចឡើយ" ថាហើយក៏ក្រោកឡើងឈរលើតាំងត្រង់ចន្លោះរណ្ដៅទាំងពីរនោះ ចំណែកខ្លាធំក៏សំដែងកម្លាំងបោលសំដៅដាក់តច្ឆកសូករៈៗ ក៏ត្រឡប់ក្រោយលោតចុះក្នុងរណ្ដៅខាងមុខ ។ ខ្លាធំស្ទុះទៅដោយរហ័សក្រៃ តែមិនទាន់ ក៏ជ្រុលទៅធ្លាក់រណ្ដៅដែលមានសណ្ឋានដូចបង្អើរ ស្រញូខ្លួនមូលខ្ទិដូចបាច់ស្មៅ ។ តច្ឆកសូករៈក៏ស្ទុះលោតផ្លោះឡើងអំពីរណ្ដៅដោយរហ័សបន្ទាន់ចុនចាក់ដោយចង្កូម ត្រង់ចន្លោះភ្លៅក្រោយ ខ្វេះកកាយទាញសរសៃពោះឲ្យរហែកធ្លុះធ្លាយរហូតដល់បេះដូង មាត់ខាំសាច់ខ្លាត្រវែងចោលទៅលើមាត់រណ្ដៅ ហើយស្រែកប្រាប់ឲ្យជ្រូកទាំងឡាយមកស៊ីសាច់ខ្លា ។ ជ្រូកទាំងឡាយនាំគ្នាមកស៊ីហើយពោលថា លោកនាយ ! លោកចាប់បានតែខ្លាធំមួយប៉ុណ្ណោះទេ នៅមានខ្លាកំណាចមួយទៀតដែលលោកមិនទាន់ចាប់បាន ខ្លាកំណាចនោះជានាយករបស់ហ្វូងខ្លា ។ តច្ឆកសូករៈទើបសួរថា នាយកខ្លានោះគឺអ្នកណា ? ។ ជ្រូកទាំងឡាយប្រាប់ថា គឺជដិលកោងម្នាក់ ធ្លាប់ស៊ីសាច់ដែលខ្លារកមកបានជានិច្ចកាល ។

តច្ឆកសូករៈ ព្រមដោយជ្រូកទាំងឡាយ លើកគ្នាទៅកាន់អាស្រមនៃជដិលកោង ដោយប្រញាប់ ។

ចំណែកជដិលកោងនោះ ឃើញខ្លាបាត់យូរ ក៏ឈរទន្ទឹងមើលផ្លូវ ស្រាប់តែឃើញជ្រូកបោលព្រមកច្រើន ក៏ភ្ញាក់ចិត្តគិតថា ប្រហែលជាជ្រូកទាំងនេះសម្លាប់ខ្លាបាន ហើយតាមមកសម្លាប់អញទៀត ទើបស្ទុះម៉ឺម៉ាឡើងទៅលើដើមល្វាមួយដើម ។ តច្ឆកសូករៈក៏បង្គាប់ឲ្យជ្រូកស្ទាវៗឲ្យឈូសកកាយត្រង់គល់ល្វា ឲ្យជ្រូកញីទាំងឡាយទៅពាំនាំទឹកមកស្រោច ឲ្យជ្រូកដែលមានខ្នាយធំទាំងឡាយ ខាំកកេរឫសជុំវិញដើមដរាបសល់នៅតែឫសកែវមួយប៉ុណ្ណោះ ។ តច្ឆកសូករៈ ស្រែកប្រាប់ឲ្យជ្រូកទាំងឡាយថយចេញទៅ ហើយខ្លួនឯងក៏លុតជង្គង់ចុះយកខ្នាយគាស់គល់ឈើដោយកម្លាំងដ៏ពូកែ ឫសកែវក៏ដាច់ថ្លុល ដើមល្វាក៏រលំដួលចុះមក ។ គ្រាន់តែជដិលកោងធ្លាក់ដល់ដីភ្លាម ហ្វូងជ្រូកក៏ដណ្តើមគ្នាខាំកកេរស៊ីសាច់ជាអាហារ ។

ខណៈនោះ ទេវតាដែលស្ថិតនៅក្នុងដងព្រៃ បានឃើញហេតុការណ៍ដ៏អស្ចារ្យដូចពណ៌នាមកនេះ ទើបពោលថា ការដែលមានញាតិជុំរុំគ្នាគង់ញ៉ាំងប្រយោជន៍ឲ្យសម្រេច ទោះបីដើមឈើដែលដុះនៅក្នុងព្រៃក៏ដូចគ្នា ជ្រូកទាំងឡាយព្រមព្រៀងព្រួតដៃគ្នាសម្លាប់ខ្លាធំ ក្នុងច្រកផ្លូវតែមួយបាន ។

ជ្រូកទាំងឡាយ លុះសម្លាប់ខ្លាធំ និងជដិលកោងទាំងពីរនាក់បានហើយ ក៏មានសេចក្តីសប្បាយរីករាយចិត្ត នាំគ្នាបន្ទឺសំឡេងលាន់ឮគឹកកង លុះបានបង្ក្រាបសត្រូវស្ងប់រៀបរយហើយ ទើបប្រឹក្សាគ្នា អភិសេកតច្ឆក-

សូករៈ ឲ្យជានាយកនាំគ្នាត្រាច់ដើរស្វែងរកទឹកសម្រាប់ស្រោចស្រោះព្រំ ប្រទះឃើញស័ង្ខសម្រាប់ដាក់ទឹករបស់ជដិលកោនក្នុងបណ្ណសាលា ក៏យកទៅដាក់ទឹកឲ្យពេញ ធ្វើទក្ខិណាព័ត៌ អភិសេកស្រោចតច្ចកសូករៈត្រង់គល់ឈើល្វានោះឯង ហើយទើបស្រោចទឹកអភិសេកជ្រូកញីមួយឲ្យជាអគ្គមហេសីនៃស្ដេចតច្ចកសូករៈ ។

វិធីអភិសេក ទើបនិយមប្រើអង្គុយលើតាំងធ្វើពីឈើល្វា និងស្រោចទឹកដោយស័ង្ខទក្ខិណាព័ត៌ជាប្រពៃណីមកតាំងអំពីកាលនោះឯង ។

ចប់រឿងតច្ចកសូករៈ

## គុណនៃសាមគ្គី

សាមគ្គីការព្រមកាយវាចាចិត្ត បើសណ្ឋិតមានក្នុងបក្សគណៈណា
បក្សក្រុមនោះនឹងរុងរឿងថាវរា មានជីវ៉ារស់ក្នុងលោកបានអង្វែង ។
បើពលរដ្ឋប្រាកដមានសាមគ្គី យ៉ាងពេញទីរដ្ឋនឹងមានជោគគួរស្ញែង
ជនបរទេសសឹងកោតខ្លាចគោរពឯង មិនហ៊ានក្លែងគិតតតាំងជាសត្រូវ ។
ច្នេះគួរយើងខមរៈអ្នកស្នេហ៍ជាតិ ជួយក្រុមញាតិជាតិផងយើងឲ្យដើរផ្លូវ
ត្រូវធម៌នេះឲ្យពាសពេញប្រទេសទៅ ឲ្យមាននៅក្នុងសន្ដានគ្រប់ខ្មែរអើយ !

យូរ-អ៊ិន

# រឿងសៅរ៍សោយ

(សិរិសោរជាតក)

## ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមគម្រាយសាស្ត្រាស្លឹករឹត

(តមក)

---

ហើយឲ្យចេញទៅនៅ ដំណាក់ក្រៅកំផែងនោះណា
សុទត្តរ័តនកញ្ញា ក៏យាត្រាចាកកំផែងជ័យ
កាលទៅនៅពឹងពាក់ ក្នុងដំណាក់ស្នាក់អាស្រ័យ
ពេលនោះស្រស់ស្រីថ្ងៃ មានព្រះទ័យត្រេកផូរផង់ ។

ចំណាយតាយធនធាន ធ្វើជាទានគ្មានបង្អង់
រាល់ថ្ងៃឥតបីបង់ ដោយផ្ទាល់អង្គអនន្តថ្ងៃ
ឲ្យសមអ្នកសូមទាន សឹងអត់ឃ្លានពន់ពេកក្រៃ
មិនដែលបានអាស្រ័យ ផ្អែកមួយថ្ងៃសោះឡើយហោង ។

ជំនុំជុំគ្នា ប្រែនមហិមាជាកន្ទង
ជ្រិតចិត្តគិតប៉ុនប៉ង សូមទានផងបរិភោគ្តា
ហើយពោលថាឥឡូវ រាល់គ្នាត្រូវទៅឆាប់ភ៉
ជ្រិតស្រីថ្ងៃកញ្ញា ជាធីតាមហាច្បាស់ច្បង ។

ដែលស្តេចទ្រង់បណ្តេញ បំបង់ចេញពីកំផែងហោង

សង្ខាថ្វាកន្ទុង ឲ្យទាន់ផងតែសព្វថ្ងៃ
ឈ្មោះក្បួរត្រូវគ្រប់គ្នា ទៅវន្ទាធំតាថ្ងៃ
សុំអស់ភ័ស្តុទៃ គ្រាន់អាស្រ័យគ្រប់អាត្មា" ។
ថ្ងៃងពីព្រះសិរសៅរ៍ ដែលទិត្យនៅស្រុកនោះណា
បានស្ដាប់ស័ព្ទរាថា សម្ពល់គ្នាថាឈ្មោះហើយ
ស្ដេចសោកក៏អត់ឃ្លាន ដើរសូមទានគេជាត្រើយ
លុះដឹងដំណឹងហើយ ពុំអង់ឡើយទៅដែរណា ។
លុះទល់ដល់ដំណាក់ នាងវរលក្ខណ៍អគ្គកញ្ញា
អស់ស្បូមសូមនានា ក្រាបវន្ទាគ្រប់ៗកាយ
រីឯព្រះសិរសៅរ៍ ត្រូវកំដៅក្ដៅក្រហាយ
ឈរជិតស្បូមទាំងឡាយ មិនទុនកាយថ្វាយវន្ទា ។
យកជាយព្រះពស្ដ្រខ្មាង ទទូរក្បាងបាំងសិរសា
ជាយម្ខាងទៀតសោតណា ស្មៀកខៅនាទីងចង្កេះ
ហេតុបុណ្យស្ដេចទឹងនាង បានសូមសាងពីមុនម៉្លេះ
ពុំឃ្លាតពាក់តរបេះ ជាដូចេះច្រើនហើយនៃ ។
ភូឈរគេក មិនវន្ទាធំតាថ្ងៃ
ទ្រង់ទតវត្ថុបរណៃ មានព្រះទ័យក្រស្នេហា
ក្សត្រស្រីធោមយន់ ល្អអស់អង្គវង្សធោយា
ជាហេតុឲ្យក្សត្រា ទតពីតាមិនរាក្អក ។
ស្ដេចទឹកកុងចិន្ដា គន់គិតថា "អា! ល្អឯក

មើលទៅមិនសៅភ្នែក　　ប្លែកចំឡែកស្រីនានា
នាងនេះសមតែបាន　　ទៅអ្នកមានបារមី
ឯអញនេះវិញណា　　សូមអាហារគេសព្វថ្ងៃ ។
បើប្អូនខ្លួនពីមុន　　នៅមានបុណ្យលើសលន់ក្រៃ
ទើបស្រីថ្ងៃនេះនៃ　　គាប់ព្រះទ័យទឹងអញណា
រីឯនាងសុទត្ត　　ទេវីក្រតែរភ្នែកញ្ញា
យល់យង់អន្តក្រោ　　ឈរឯកាធ្វើរហ៊ី ។
ទើបនាងធ្វៀងនេត្រា　　ទតកិរិយាមហាចក្រី
កាលនេត្រព្រះនឹងស្រី　　ចួបគ្នាខ្ចីស្នេហា
កកើតឡើងយ៉ាងខ្លាំង　　ឲ្យភាន់ភាំងទាំងកាយា
ព្រោះនាងទឹងក្រោ　　ភ្ជាប់រួមគ្នាព្រីនជាតិ ។
ទើបនាងបន្ទូលស្នង　　ថា “អើហងមេទាសី
មើលចុះសម្ទុះរុី　　តើហេតុអីក៏ខុសគេ
ឈរធ្មឹងទឹងដូចភ្នំ　　មិនបង្គិសុំទានទេ
ទទូរឈររិះរេ　　ម្ដេចខុសគេណាមេណ៎ា ។
ចូរឯងទៅថ្លែងប្រាប់　　ឲ្យគាត់ឆាប់យកចេញ៉ា
សំពត់ពីសិរសា　　ឃើញមុខាយើងឲ្យទាន” ។
កាលនោះអស់ទាសី　　ស្ដាប់សវនីយ៍ស្រីកល្យាណ
ក៏ចូលទូលក្សត្រក្សាន្ត　　តាមលំអាននាងក្សត្រី ។
ថា “នៃ! អ្នកកំសត់　　យកសំពត់ពីសិរសី

ទទូរឈរធ្វើអី ចូរស្រដីប្រាប់ខ្ញុំា"
ទើបស្តេចគេចស្រដី ប្រាប់តាសីតាមន័យថា
"យើងរងសែនសុរិយា ក្តៅអាត្មាខ្លាំងក្លាក្រៃ ។
ទើបយើងយកពស្ត្រា បាំងសិរសាការសែនថ្ងៃ
បើនាងឲ្យអាស្រ័យ យើងអរក្រៃកត់តបថ្លែង
តែបើមិនឲ្យទេ យើងនឹងរេរកកន្លែង
ទៅសុំអស់គេឯង គ្រាន់ចាត់ថែងចំអែតប្រាណ ។
ដូច្នេះនាងពល់គ្នា ចូរលីលាម្នីម្នាបាន
ទៅទូលដល់កល្យាណ ឲ្យនាងបានជាបសេចក្តី"
ពេលនោះអស់ពួកស្នំ ចូលបង្គំទូលក្សត្រី
តាមពាក្យព្រះចក្រី ទើបក្សត្រីថ្លៃគិតថា ។
"អ្នកនេះមិនអ្នកខ្សត់ មិនទូគិតអត់ឡើយណា
ត្រកូលពូជពង្សា មិនមែនជាពស្ត្រសោះឡើយ"
គិតភ្ញាំងនាងស្រដី សួរតាសីថា "អ៊ុំអើយ !
នាងស្និទ្ធជិតគាត់ហើយ ឃើញមុខមាត់គាត់យ៉ាងណា ។
ជាមនុស្សខ្ពស់យសសក្តិ ឬជាអ្នកធ្លាក់សក្តា
លេងស្រីលេងសុរា លេងបក្សាកីឡាភ្នាល់
ធ្វើម្តេចនឹងដឹងអេះ ថាអ្នកនេះខ្ពស់ឬទាល់
នឹកឡើងនឹងចង់ស្គាល់ តែរាំទាល់មិនយល់មុខ" ។
ពេលនោះអស់តាសី យល់ក្សត្រីថ្លៃជាទុក្ខ

កល្យាណពុំបានសុខ ចង់យល់មុខសូមនោះណា
ទាសីមួយសោតសល់ ដែលបេះកល់យល់តម្រា
ចរចូលទៀនទូលថា "សូមកញ្ញាត្រាប្រណី ៗ
ធម្មតាជាតិបុរស គ្រប់ទាំងអស់ក្នុងលោកិយ
ទោះទុក្ខជ្រប់មុខក្ដី កាលឃើញស្រីតែងគយគន់
សូមម្ចាស់ផ្ចាស់តែងកាយ ឲ្យឆើតឆាយក្រៃពេកពន់
យាងយាសវិលាសលន់ ឲ្យគាត់គន់មើលកញ្ញា ៗ
កាលគាត់ឃើញក្សត្រី គង់ឃ្លាតខ្លីទាញពស្ដ្រា
ចេញពីទីសិរសា មើលធីតាជាពុំខាន
ពេលនោះស្រស់វរមិត្ត អាចពិនិត្យឃើញពិតបាន
ទាំងមុខទាំងខ្លួនប្រាណ អាចដឹងឋានបានហ្មត់ហ្មង" ៗ
កាលរ័ត្នវរក្សត្រី ស្ដាប់ទាសីស្ដីទូលស្នង
ប្រញាប់ឆាប់កន្ទង តែងអង្គផងយ៉ាងប្រិមប្រិយ
ហើយចេញមកលីលា យាងបាទាទៅមកខ្លី
បង្អួតព្រះបក្រិ ឲ្យនរបតីឃើញកាយា ៗ
ចមពលយល់ស្រីថ្ងៃ កើតព្រះទ័យក្រៃស្នេហា
ទើបទាញពរពស្ដ្រា ពីសិរសាទតវរល័ក្ខណ៍
ក្សត្រាទ្រឹងពន្ទូក ទតទៅមកទាំងពីរនាក់
សំឡឹងនឹងមិនដាក់ សំឡក់កក្ដ្រទាំង២ប្រាណ ៗ
ពេលនោះស្រស់សុទត្ត ទេវីរ័ត្នក្សត្រកល្យាណ

យល់យន់អង្គក្សត្រក្សាន្ត
ល្អត្យប្រាណពុំមានខ្ចោះ
ទតក្មានទាន់គិតថា
អ្នកនេះណាល្អឥតមោះ
មិនសមមិនរម្យសោះ
ដើរសូមអស់ក៏ស្តុកោក្តា” ៗ
គិតហ្គោះស្រស់ក្សត្រិ
ប្រើទាសីទាំងពីរថា
“ចូរនាំសម្បនេះណា
ឆាប់ ៗ ក៏ណាទាសី
ចូរនាំគាត់ចូលទៅ
ឲ្យគាត់នៅកេនគ្រ្យខ្ចី”
បានស្ដាប់សវនីយ៍
ទើបទាសីទាំងពីរប្រាណ ៗ
ចូលទូលដល់ទសពល
“ផ្សិតនិមិលស្រស់កល្យាណ
ឲ្យនាំចមក្សត្រក្សាន្ត
ទៅស្នាក់ប្រាណហានឯណោះ”
ស្ដាប់ស្រេចស្ដេចគេបស្ដ័
ប្រាប់ទាសីដោយចំពោះ
“ថាបើនាងមិនស្មោះ
ឲ្យយើងសោះក៏មិនថី ៗ
តែម្ដេចក៏គេចមក
នាំយើងយកទៅធ្វើអី
នឹងនាំទៅធ្វើអ្វី
យើងឥតបំនឹងដឹងបាន”
គ្រាស់ច្នេះអស់ ៣ គ្រា
ហើយរាជាលីលាថ្កាន
យាន់តាមស្នំពីរប្រាណ
ទៅក្នុងឋានកេនគ្រ្យណា ៗ
លុះចូលដល់យល់ខ្ចិ
ព្រះចក្រីទ្រង់ចិន្តា
ថា “តទៅនេះណា
យើងឃើញជាបាទសុខី”
ដែលទ្រង់គិតដូច្នេះ
ព្រោះទ្រង់បេះមាយាស្រី
ពេលនោះស្រស់ក្សត្រិ
ចាត់ចំណីដ៏ថ្លៃថ្លា ៗ
កោដទ់ផលផងទាំងអស់
សឹងមានរសឆ្ងាញ់ពីសា

ហើយប្រាប់តាសីថា    " នាងពល់គ្នាលីលាឆាប់
ចូរនាំយកអាហារ    គ្រប់ប្រការនេះប្រញាប់
ទៅឲ្យគាត់នោះឆាប់    ហើយចាំចាប់មើលកិរិយា ។
បើឃើញហេតុភេទម្ដេច    ចូរវិលគេចប្រាប់យើងក៏
ទាំងសំណល់ភោក្ដា    នាងពល់គ្នាកុំតែពាល់
យកមកតាមភាពពិត    យើងពិនិត្យយើងគង់ស្គាល់
ថាគាត់ខ្ពស់ឬទាល់    សោះពិកាល់ច្រល់តទៅ " ។
ស្ដាប់ក្លាងនាងទាសី    នាំចំណីថ្វាយសិសៅរ៍
ពេលនោះព្រះចមចៅ    ក្រោកត្រាស់ទៅទាសីថា
" ខ្ញុំយើងកំពុងហ្មង    ញើសក្អែលល្អងពេញកាយា
ស្រមេះដូច្នេះណា    ទឹងភោក្ដាម្ដេចកំបាន " ។
ព្ទុច្នោះអស់មេទំ    វិលបង្គិចមកល្បាណ
សុទត្តរ័តន៍ក្សត្រក្សាន្ត    កាលនាងបានជ្រាបសេចក្ដី
ទើបរៀបគ្រឿងលាបកាយ    ផងទាំងឡាយថ្វាយចក្រី
ទឹកអប់សព្វអ៊ីៗ    សំពត់ថ្មីក៏ស្រីចាត់ ។
ហើយប្រើអស់ទាសី    ឲ្យនាំខ្ទីថ្វាយមហាក្សត្រ
ជៀសដ្ឋ័យថ្ងៃអរក្ដាត់    ទើបចមក្សត្ររៀបចាត់ចែង
ស្រង់ទឹកដំរះអង្គ    ហើយស្ដេចទ្រង់ផ្ចិតផ្ចង់តែង
អង្គស្រេចក៏ស្ដេចស្ដែង    វិលកន្លែងសោយក្រយា ។

(មានត)

## កណ្ឌទី ២១

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាជការផ្ទាល់បើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្ដានស្នេហាជាតិ ។

តាំងស៊ុនសួរថា អ្នកនឹងគិតធ្វើយ៉ាងណា ? ។ កៀតប៊ុនឆ្លើយថា ចុង នោះរមែងមានភាគឈឺក្បាល ហើយខ្ញុំបានទៅមើលជានិច្ច បើចុងឈឺទៀត វេលាណា ខ្ញុំបាននឹងទៅព្យាបាល ប្រកបថ្នាំឲ្យផឹកដាក់ថ្នាំបំពុលបញ្ចូល ផង បើចុងផឹកហើយគង់នឹងស្លាប់ ការណ៍ដែលខ្ញុំបានគិតនេះឃើញថា មិនលំបាកដល់សេនាទាហាន ។ តាំងស៊ុនបានឮដូច្នោះក៏សោមនស្ស ក្នុងចិត្តទើបឆ្លើយថា អ្នកមានសេចក្ដីសត្យកតញ្ញូនឹងម្ចាស់ផែនដីប្រាកដ, រាជសម្បត្តិនេះនឹងមិនអន្តរាយឡើយ គុណគាប់ដ៏ប្រសើរនឹងមានដល់ខ្លួន អ្នកទៅឯមុខ ។ លុះវេលាព្រឹក កៀតប៊ុនក៏លាតាំងស៊ុនទៅផ្ទះវិញ ។

ខណៈនោះតាំងស៊ិនមានសេចក្ដីសប្បាយរីករាយចិត្តណាស់ ជម្ងឺឈឺថ្កាត់ទាំងប៉ុន្មានក៏រលាយបាត់សូន្យអស់ទៅ ទើបដើរចុះទៅមើលសួនផ្កាក្រៅទៀតឃើញខេងតងជាប់ស្ទិទ្ធ អង្គុយនិយាយគ្នានឹងនាងគុន-អេងដែលជាភរិយាបន្ទាប់ក្នុងទីស្ងាត់ តាំងស៊ិនខឹងណាស់ហៅមនុស្សបំរើឲ្យចាប់ខ្លួនខេងតងបាន ហើយហូតក្រប៊ីគិតនឹងកាប់ខេងតងឲ្យស្លាប់ ៗ ភរិ-យាធំតាំងស៊ិនឃើញកើតរឿង ក៏ចុះទៅឃាត់សុំជីវិតខេងតង • តាំងស៊ិនក៏ឲ្យវាយខេងតងយ៉ាងធម្ងន់ហើយដាក់ច្រវាក់ទុក លុះវេលាពាក់កណ្ដាលអធ្រាត្រ ខេងតងក៏កាប់សោរត់រួចទៅនៅទីងចូច យកសេចក្ដីអាថ៌កំបាំងដែលតាំងស៊ិនគប់គិតគ្នានឹងអ្នក៥នាក់នោះប្រាប់ចូចគ្រប់ប្រការ ៗ ចូចបានស្ដាប់ច្បាស់ក៏ឲ្យយកខ្លួនខេងតងទៅលាក់បំពួនទុកក្នុងផ្ទះ ៗ ឯតាំងស៊ិននោះលុះព្រឹកឡើងដឹងថា ខេងតងរត់បាត់គិតថា ប្រហែលរត់ទៅនៅខែត្រក្រៅ មិនបានទឹងគិតឲ្យស៊ើបសួរតាមរក ៗ លុះថ្ងៃមួយចូចក៏គិតកលឧបាយធ្វើជាឈឺក្បាល ទើបប្រើបំរើឲ្យទៅហៅគៀតប៉ឹងពេទ្យហ្លួងមករក្សាពេត បំរើក៏ទៅហៅគៀតប៉ឹង ៗ ក៏គិតថា. " អា-សត្រូវពជសម្បត្តិវានឹងស្លាប់ក្នុងគ្រានេះហើយ " គៀតប៉ឹងចូលទៅក្នុងផ្ទះយកថ្នាំពិសពុលលាក់ទៅជាមួយ ៗ ចូចឃើញគៀតប៉ឹងទៅដល់ ក៏គន់មើលម្រាមដៃឃើញកំបុត ១ សមដូចពាក្យខេងតងប្រាប់ ក៏មិនបានសាកសួរថាម្ដេច ៗ

ចូចនិយាយនឹងគៀតប៉ឹងថា ឥឡូវយើងឈឺក្បាលខ្លាំងណាស់ ចូរ

អ្នកប្រកបថ្នាំតែឲ្យរសាយពេកយើងចុះ យើងនឹងឲ្យបំណាច់រង្វាន់ ។ កៀតប៊ុនថា ‹‹លោកឈឺគ្រានេះខ្ញុំបាទនឹងប្រកបថ្នាំតែ ១ យ៉ាងជូនលោកពិសា ពេកលោកក៏នឹងរសាយស្រឡះ›› ហើយកៀតប៊ុនក៏យកថ្នាំដាក់ក្នុងតែងដាំឲ្យរឹងបន្តិច លុះឃើញបុប្ផាងាកមុខចេញ ក៏យកថ្នាំពិសពុលនោះដាក់បញ្ចូល ហើយចាក់ចេញល្មមបានកន្លះតែងទើបលើកហុចទៅឲ្យបុប្ផាផឹក ។ បុប្ផាដឹងកលកៀតប៊ុនក៏ធ្វើជាព្រងើយមិនបានទទួលថ្នាំនោះ ។ កៀតប៊ុនថា មហាឧបរាជពិសាថ្នាំនេះទៅចុះទាន់នៅក្ដៅ ដើម្បីឲ្យបែកញើសខ្លះ ពេកលោកក៏នឹងស្រះជា ។ បុប្ផាតបថា ខ្លួនអ្នកជាពេទ្យហ្លួងរមែងដឹងទម្លាប់ទំនៀមគ្រប់សព្វហើយ បើព្រះមហាក្សត្រទ្រង់ព្រះឈួន ពេទ្យថ្វាយឱសថវេលាណាត្រូវឲ្យពេទ្យនោះប្ដូនា-ហ៊ឺនក្សាព្រះអង្គជៀបថ្នាំជាមុន, បើមាតាបិតាឈឺ ពេទ្យប្រកបថ្នាំឲ្យផឹកត្រូវឲ្យកូនភក្សល្បងថ្នាំជាមុន ឥឡូវខ្លួនយើងជាមហាឧបរាជ ខ្លួនអ្នកជាពេទ្យធ្លាប់រាប់អានស្និទ្ធស្នាលនឹងយើង អ្នកប្រកបថ្នាំឲ្យយើងផឹក អ្នកត្រូវផឹកល្បងឲ្យយើងឃើញជាមុនសិន ទើបយើងផឹកជាក្រោយ ។

កៀតប៊ុនតបថា ប្រសាសន៍លោកថាដូច្នេះក៏គួរណាស់ហើយ តែខ្ញុំបាទយល់ថាលោកក៏ធ្លាប់ទុកចិត្តខ្ញុំបាទមកពីដើម ឥឡូវលោកឈឺ ខ្ញុំបាទប្រកបថ្នាំជូនលោកពិសា លោកនឹងឲ្យខ្ញុំបាទដែលមិនឈឺទទួលទានជាមុននោះថ្នាំនេះតិចណាស់ នឹងអស់ទៅ ពេកលោកក៏មិនស្រះជា ។ បុប្ផាក៏ធ្វើព្រងើយកន្តើយមិនព្រមទទួលផឹក ។ កៀតប៊ុនឃើញបុប្ផារង្កៀស

សង្ស័យមិនទទួលផឹកថ្នាំដូចកាលផង  ក៏សំគាល់ក្នុងចិត្តថា  ប្អូនដឹងដល់គំនិតដែលខ្លួនគិតទុក ទើបចាប់ស្លឹកត្រចៀកប្អូនជាប់ហើយយកដៃទាញលើកឡើងប្រកឲ្យប្អូនផឹក ៗ ប្អូនយកដៃទាត់ពែងធ្លាក់ពីដៃទៅបែក កំពប់ថ្នាំទៅលើឥដ្ឋដោយអំណាចថ្នាំពិសនោះឥដ្ឋក៏បែកខ្ទេច ៗ មនុស្សបំរើទាំងពួងឃើញដូច្នោះ ក៏ប្រមូលគ្នាចូលរោមចាប់ខ្លួនកៀតប៊ុនចងជាប់ ៗ ប្អូនបានចំណាប់ឃើញច្បាស់ជាកៀតប៊ុនដាក់ថ្នាំពិស ក៏និយាយថា "អញមិនមែនឈឺអ្វីទេ  អញពិសោធឯងថងដឹងទេតើ  ឥឡូវអញឃើញថាឯងប្រទូសរ៉ាយអញជាប្រាកដ" ទើបបង្គាប់ទាហាន ២០ នាក់ឲ្យនាំខ្លួនកៀតប៊ុនទៅឯសួនច្បារ  ហើយចងស្ទឹងវ៉ាយកៀតប៊ុនយ៉ាំងសហ័សសួរពិចារណាថា  ខ្លួនឯងជាពេទ្យដែលគិតការទាំងនេះ  អញក៏ឃើញថាលើសគំនិតប្រាជ្ញាឯង  តើនរណាប្រើឯងឲ្យធ្វើដូច្នេះ  ចូរឯងឆ្លើយប្រាប់ឈ្មោះឲ្យច្បាស់តាមត្រង់  អញនឹងលើកទោសឯង ៗ

កៀតប៊ុនត្រូវវ៉ាយឈឺចាប់ជាទម្ងន់ណាស់  ក៏មិនបានខ្លាចសេចក្តីស្លាប់ស្រែកតំហកតបថា  ខ្លួនឯងធ្វើល្មើសជាខ្លាំងសត្រូវនឹងរាជសម្បត្តិបានជាអញគិតធ្វើការដូច្នេះ  មិនមែននរណាមកបង្គាប់ប្រាប់ឲ្យអញធ្វើទេព្រោះហេតុថាផែនដីសព្វថ្ងៃក្តៅគ្រប់ដើមស្មៅវល្លិ៍ឈើព្រៃទាំងពួង  បានជាអញគិតសម្លាប់ឯងចេញ  ទោះនរណា ៗ គេក៏ប្រែងតែនឹងប្រហារជីវិតឯងដូចអញដែរ  តែមិនទាន់បានឱកាសនឹងធ្វើបាន  ជីវិតអញនឹងស្លាប់ហើយឯងមិនត្រូវមកសួរធ្វើអ្វីឡើយ ៗ  ប្អូនបានឮដូច្នោះក៏ខឹងណាស់

ឲ្យវាយកៀតប៊ុនតាំងពីព្រឹកដល់ថ្ងៃត្រង់ ទាល់តែខ្លួននោះបែករលួយហូរឈាមស្រោចអស់ទាំងខ្លួន កៀតប៊ុនក៏មិនឆ្លើយដាក់គូកន ។ ចូឆូបារម្ភក្រែងកៀតប៊ុននឹងស្លាប់សាបសូន្យរឿងរ៉ាវ ក៏ឲ្យយកខ្លួនកៀតប៊ុនទៅឃុំទុកជាមាំមួន លុះវេលាព្រឹកឡើងចូឆូក៏បង្គាប់ឲ្យរៀបតុលៀងអាហារឲ្យអញ្ជើញនាហ្មឺនសព្វមុខមន្ត្រីតូចធំទៅជួបជុំបរិភោគ ។ ឯជូហុក, ជូឡាន, តាន់ស៊ុប, ង៉ោហ្វួន ៤ នាក់នេះ ក៏គិតព្រមគ្នាថា បើយើងមិនទៅចូឆូនឹងសង្ស័យ នាហ្មឺនទាំង ៤ នាក់ក៏ទៅព្រមគ្នានឹងនាហ្មឺនទាំងពួង តែតាំងស៊ុននោះឲ្យដំណឹងថាឈឺទៅមិនរួច ។

ខណៈកាលនាហ្មឺនមុខមន្ត្រីទាំងពួងកំពុងបរិភោគអាហារ ចូឆូក៏និយាយថា "អស់លោកផឹកស្រាមិនសូវសប្បាយ យើងមានមនុស្សម្នាក់ថ្ងៃកនឹងឲ្យយកមកឲ្យអស់លោកមើលលេង" ថាហើយក៏ប្រើទាហានឲ្យឃុំនាំយកខ្លួនកៀតប៊ុនចេញមក ចូឆូក៏និយាយនឹងនាហ្មឺនទាំងពួងថា "មានពួកក្បត់គប់គិតគ្នានឹងអាកំណាចម្នាក់នេះ នឹងធ្វើអន្តរាយដល់ព្រះចៅហៀនតេ ហើយធ្វើប្រទូសរ៉ាយដល់យើងផង ឥឡូវទេពតាមិនបានចូលទៅខាងមនុស្សអាក្រក់ បណ្ដាលឲ្យយើងចាប់ខ្លួនបាន យើងនឹងសួរពិចារណាវា ឲ្យអស់លោកចាំស្ដាប់ចុះ" ចូឆូក៏ឲ្យវាយកៀតប៊ុនទៀតទាល់តែសន្លប់ ហើយឲ្យរឹតរួតទាល់តែដឹងខ្លួនឡើងវិញ ។ កៀតប៊ុននៅមិនបានញញើតខាំធ្មេញញញមុខសំឡក់ ហើយជេរចូឆូជាពាក្យអាស្រូវភាសផ្សេងៗ ហើយថា "ហេតុម្ដេចឯងមិនសម្លាប់អញទៅ ទុក

អញ្ជើញអ្វីទៀត ៗ ចួចថា ពីដើមរាប់គិតគ្នាទាំងពួក ៦ នាក់ ឯក្រោយ ឯងទៅចូលរួមគំនិតទៀតទើបត្រូវជា ៧ នាក់ ដើមគំនិតនោះគឺឈ្មោះអ្វី? បានជាឯងមិនបង្អួលឲ្យច្បាស់ ៗ កៀតប៊ុងក៏មិនឆ្លើយតបសោះ ចួចខឹង ណាស់ឲ្យវាយទៀតហើយពិចារណាសួរ កៀតប៊ុងរឹងតែមិនឆ្លើយដាក់ ដល់មាក់ណា ៗ

ឯដូហ៊ុក, ដូឡាន់, តាំងអ៊ុប, ង៉ោហួន, អង្គុយបរិភោគអាហារ ឃើញចួចឲ្យវាយពិចារណាកៀតប៊ុងដូច្នោះ អ្នកទាំង ៤ ក៏មិនបានជាសុខ ឧបមាដូចជាគេអង្គុយលើចង្រ្កានបន្ទាប់លើភ្លើងគុក ទាំងទឹកមុខក៏ស្លេកស្លាំង គ្មានឈាមសោះ បេះតែសំឡឹងមើលមុខគ្នាទៅវិញទៅមក ៗ ចួចឃើញ កៀតប៊ុងមិនឆ្លើយដាក់ដល់គូកនដូច្នោះ ក៏បង្គាប់ឲ្យយកខ្លួនទៅដាក់គុក ដូចដើម ៗ

នាហ៊ឺនមុខមន្ត្រីទាំងឡាយនោះ លុះបរិភោគរួចហើយទាំងអស់គ្នាក៏ លាចួចចុះទៅ ៗ ចួចទើបថា អ្នកទាំងពួងទឹងទៅក៏ទៅចុះ តែដូហ៊ុក, ដូឡាន់, តាំងអ៊ុប, ង៉ោហួន ៤ នាក់នេះត្រូវឲ្យបង្អង់នៅសិន យើងនឹង ប្រឹក្សាការរាជការផង ៗ នាហ៊ឺនទាំង ៤ បានឮដូច្នោះ ក៏ស្លុតរន្ធត់ចិត្ត បាត់ព្រលឹងពីក្នុងខ្លួន ចាំចិត្តនៅអង្គុយដោយខ្លាចអាជ្ញា ចួចៗក៏សួរនាហ៊ឺន ទាំង ៤ នាក់ថា អ្នកប្រឹក្សាការអ្វីខ្លះនៅផ្ទះតាំងស៊ុន ៗ នាហ៊ឺនទាំង ៤ ឆ្លើយថា ខ្ញុំបាទនឹងបានទៅប្រឹក្សាការអ្វីនៅផ្ទះតាំងស៊ុនក៏ទេ ៗ

(មានត)

# ដំណើរតាមខ្យល់ក្នុងកាផ្ការៈ

## លោក ផេង-ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

### ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

គេឲ្យនាងពាក់កង ការ ចិញ្ចៀនប្រដាប់ដោយត្បូងពេជ្រផ្សេងៗ ។ នាងឡូឡាមិនចង់លះបង់ប្រដាប់ពីកន់ដែលម្ដាយចែកមកឲ្យសោះ ។ ការផ្លាស់ប្ដូរជីវភាពមួយពេបនេះ មិនទាន់កំចាត់ចិត្តនាងចេញពីការស្នេហាចំពោះបុគ្គលជាទីស្រឡាញ់នៃនាងឡើយ ។

ប្រាកដមែន នាងឡូឡានៅជាប់ចិត្តនឹងអនុស្សាវរីយ៍ បងស្រីដែលជាស្ត្រីអនុបត្ថកំសត់ បាត់បង់ទៅទាំងបង្ខំ ក្នុងវ័យពេញជំទង់ដូចផ្កាកំពុងរីក ។ នាងតែងនឹកជាញឹកញយដល់ម្ដាយជាទីស្រឡាញ់ គឺវាសនាអកុសលឆក់បំបែកនាងចេញពីអ្នកមានគុណ ប៉ុន្តែ នាងនៅមានក្ដីសង្ឃឹមថា ថ្ងៃណាមួយ នាងនឹងបានជួបម្ដាយជាមិនខាន កាលណាគេឈប់ច្បាំងគ្នា កាលណាសន្តិសុខត្រឡប់មកកាន់ផែនដី មកតាំងសណ្ឋិតក្នុងខន្ធសន្តាននៃមនុស្សទាំងឡាយវិញ ។

ជីវភាពនៃនារីទាំងឡាយតែងប្រព្រឹត្តទៅដោយមិនស្រួលស្អាតបាត ក៏មែនហើយ តែប្រកបដោយនិរភ័យ ។

ជួនកាល សម័យថ្ងៃរសៀល នាងឡូឡាបានប្រទះអ៊ុស្មាអ៊ីល, គេញញឹមដាក់គ្នា ។ លោកអ៊ៃយ៉ាដដឹងថាកូនច្បងលោក ក្នុងពេលដែលបានធ្វើដំណើរទៅប្រទេសអឺរ៉ុប បាននាំយកទំលាប់ប៉ែកខាង

សេចក្ដីគួរសមចំពោះស្រីៗ ។ ហេតុនេះ ទើបលោកអនុញ្ញាតកូនលោកឲ្យទៅជួបនាងឡូឡា នៅក្រោមបង្អួចត្រជាក់ទៅមុខផ្ទះ ។

សេចក្ដីរីករាយថ្មីៗ តែងកើតមានជានិច្ចដល់អ្នកកំលោះនឹងនាងក្រមុំ កាលណាគេបានប្រទះមុខគ្នាម្ដងៗ ។ មុទុតាដែលកើតក្នុងដួងចិត្តរបស់គេក្នុងពេលប្រទះគ្នាលើកដំបូង ក៏ក្លាយកន្លងបន្តិចម្ដងៗ ទៅជាចំណង់យ៉ាងមាំហើយយ៉ាងសុចរិត ។

* * *

សម័យនោះ សង្គ្រាមកាន់តែកើតខ្លាំងឡើងៗ ។ កងទ័ពតួរគីដែលពួកអ៊ីតាលីប្រមាថមើលងាយ ត្រឡប់ជាមានកំឡាំង ។ ការណ៍ដែលបច្ចាមិត្រនឹកស្មានថា គ្រាន់តែពួកទាហានល្បាតបន្តិចបន្តួច ក៏ក្លាយទៅជាចម្បាំងមែនទែន ។

កងទាហាននៃព្រះចៅស៊ុលតង់ដែលធ្វើចម្បាំង នៅសមរភូមិទ្រីប៉ូលីតែន គឺជាទាហានឥតវិន័យ គ្មានគ្រឿងអាវុធដោយត្រឹមត្រូវ ។ គ្រឿងស្លៀកពាក់ឯកសណ្ឋានសុទ្ធតែបំណះ កាំភ្លើងផ្សេងផ្ដាស ចំណេះវិជ្ជាមិនគ្រប់គ្រាន់ មិនបាច់និយាយពីរបៀបរៀបតម្រៀបមិនត្រឹមត្រូវតាមពេលវេលាផង ម្ល៉ោះហើយការណ៍នេះ បណ្ដាលឲ្យពួកទាហានធ្វើការមិនយកចិត្តទុកដាក់ ឬដោយធ្វេសប្រហែស ។ ម្យ៉ាងទៀត មានទាហានដោយច្រើន សុទ្ធតែអ្នកធ្លាក់សក្តិ ដូចយើងបាននិយាយពីខាងលើមកស្រាប់ ប៉ុន្តែទោះបីជាល្អឬអាក្រក់ ក៏ទាហានទាំងនោះមិនមែនឥតក្ដីក្លាហានឡើយ គឺជាកងទ័ពមានលក្ខណៈដ៏ពេញក្នុងការសង្គ្រាម ។ ដៀជាក់ក្នុងសាស្នា

ៗ បានគួរតែស៊ូស្លាប់ទឹងកន្ទេង មិនថយក្រោយមួយជំហានឡើយ កាលណា មានបទបញ្ជាចាត់ឲ្យធ្វើប្រតិបត្តិការ ៗ ស្លាប់ដោយការវាយប្រឡូកទល់នឹងពួកម្ចិល គឺជាការស្លាប់យ៉ាងប្រពៃ ៗ

គេដឹងថា ក្នុងសង្គ្រាម រុស្ស៊ី-តួរគី មានមនុស្សស្លាប់យ៉ាងច្រើនអនេក ជាកិត្តិយស ដើម្បីការពារប្រទេសជាតិ ហើយនៅមានការស្លាប់មនុស្សដែលណា ហូបេដរើសហៅមកឲ្យជួយទៀត ៗ

*

*   *

រាល់ល្ងាច ពួកចាស់ទុំក្នុងក្រុង តែងតែមកប្រជុំគ្នានៅផ្ទះលោកអៃយ៉ាដជាអាពុកអ៊ីស្មាអ៊ីល ៗ ប៉ុន្តែ តាំងពីប៉ុន្មានពេលមកហើយ រស្យីមបេនអាប់ជាឡុះ ដែលទុកជាមិត្តយ៉ាងជាប់ចិត្តមួយនៃលោកអៃ-យ៉ាដ រឿះមិនមកក្នុងពេលប្រជុំ តើរស្យីមមានបើថ្នាំងថ្នាក់ចិត្តដូចម្តេច?

ពេលរសៀល កាលដែលមុក្តារនឹងអ៊ីស្មាអ៊ីលអង្គុយដក់ថ្នាំលេងក្នុងបណ្ណាល័យអាពុកគេ រង់ចាំឲ្យថ្ងៃត្រជាក់ មុក្តារហៅបងហើយនិយាយថា:

— “អ៊ីស្មាអ៊ីល !

— “មានការណ៍អ្វី មុក្តារ?

— “ត្រូវខ្ញុំប្រាប់បងឲ្យដឹង អំពីគំនិតរស្យីមក្នុងរឿងនាងឡីឡា ៗ

និយាយចេញឈ្មោះនាងនារីឡីឡា អ៊ីស្មាអ៊ីលក្រោកឡើងភ្លាម ៗ គេហាក់ដូចជាខឹងញ័រមួយរំពេច ៗ

មុក្តារសួរថា:

— “អីបងឯងស្រឡាញ់នាងហ្នឹង?

– "ប្រាកដមែន! អញស្រឡាញ់នាងហ្នឹង មុក្តារ?

មុក្តារប្រាប់ថា:

– "ត្រូវប្រយ័ត្ន សៀមជាសំឡាញ់ផងបង ចង់ដណ្តើមនាងឡីឡាយកពីយើងហើយ ៗ គេសន្យានឹងឲ្យរង្វាន់ជាប្រាក់យ៉ាងច្រើនដល់តាឡិប បើគាត់នេះគិតគូរបែបណា អាចនាំនាងក្រមុំទៅប្រគល់ឲ្យគេបាន ៗ កូនឈ្នួលរបស់បងនឹងនិយាយប្រាប់រឿងអស់នេះដោយសព្វគ្រប់ ក្នុងវេលាព្រឹកស្អែក បើប្រសិនគាត់មិនត្រូវទៅត្រួតមើលចំការកាហ្វេ" ៗ

អ៊ីស្មាអ៊ីលសួរថា:

– "តាឡិបទៀងជាដឹងច្បាស់នូវកិច្ចការដែលឯងនិយាយឬ?" ៗ

មុក្តារគ្រាន់តែឆ្លើយថា:

– "តាឡិបគាត់បានស្បថចំពោះព្រះនាមព្រះហើយជាស្រេចអំពីរឿងនោះ" ៗ

អ៊ីស្មាអ៊ីលសម្រេចសេចក្តីថា:

– "បើដូចសំដីអូនឯងនិយាយ ការណ៍ហ្នឹងពិតមែន សៀមបង, ដណ្តើមឡីឡាយកជាប្រាកដ ៗ គឺជាសេចក្តីប្រមាថ មើលងាយមួយយ៉ាងធ្ងន់របស់សៀមមកលើផ្ទះយើង" ៗ

មុក្តារឈាមពាវ ស្រែកឡើងដោយសេចក្តីតូចចិត្តថា:

– "ខ្ញុំទៀងជាផ្តាច់ស្ពានមេត្រីចេញពីវាជាមិនខាន" ៗ

អ៊ីស្មាអ៊ីលជញ្ជឹងមួយសន្ទុះ ទើបនិយាយយ៉ាងស្រួលថា:

— "នែមុក្តារអូន! កុំអាលប្រឡាត នៅស្ងៀមសិន ចាំស្ដាប់បង ។ បងមានគល់ល្បិចមួយ... ។ រស្មី វាមិនទាន់សង្ស័យអ្វីនៅឡើយទេ ។ ចូរស្ដាប់បង ហើយបិទការណ៍សំងាត់នៃសេចក្ដីព្រៀងនេះទុកក្នុងចិត្តឲ្យស្ងៀម" ។

ឱកាសនោះ អ៊ីស្មាអ៊ីលថយមកអង្គុយជិតមុក្តារ ហើយពន្យល់សព្វគ្រប់ នូវមធ្យោបាយដែលគេគិតទុក ដើម្បីបំរុងធ្វើទោសដល់រស្មីជាអាក្សត់ ។

* * *

ឱកាសនោះជាថ្ងៃបុណ្យនៅក្រុងកាសិ-កាភប៊ូលី ព្រោះមានមនុស្សចំនួនច្រើនទើបនឹងមកពីលាបំណន់ឯវិហារព្រះជេតពន (១) តាមទំនៀម-ទំលាប់ប្រពៃណី ។ អំពីការធ្វើដំណើរលាបំណន់នេះ អាព៉ប់អ្នកកាន់សាសនាម្នាក់ៗ ត្រូវធ្វើយ៉ាងតិចក៏ម្ដងក្នុងមួយជីវិតខ្លួន ។ អ្នកណាដែលគេបានធ្វើដំណើរលាបំណន់រៀងរាល់ឆ្នាំ អ្នកនោះជាមនុស្សសុខសប្បាយទាំងកាយនឹងចិត្ត ។

ពួកអ្នកដែលអាស្រ័យនៅក្បែរមាត់សមុទ្រ នឹងពួកចរាចរក៍នា-បណ្ដាដំរំព្រឹក្សយ៉ាងឆ្ងាយ កណ្ដាល សាហារ៉ (២) តែងធ្វើដំណើរតាមនាវាទៅកាន់វិហារព្រះជេតពន ដោយចំណាយមាសប្រាក់បន្តិចបន្តួច

១ ជេតពនជាឈ្មោះព្រះវិហារមួយនាក្រុងសាវត្ថីប្រទេសឥណ្ឌា គេកសាងឡើងថ្វាយព្រះសម្មាសម្ពុទ្ធ ដោយឮខ្មែរនិយមរាប់អានព្រះវិហារនេះ ពួកចាមយកកន្លែងមហាម៉េតះហៅថាព្រះជេតពនដែរ តែតាមការពិត កន្លែងមហាម៉េតហៅថា: ម៉េត ។

២ ឈ្មោះវាលខ្សាច់ក្នុងប្រទេសអារ៉ាប់ ។

ដែលខ្លួនបានសន្សំទុកមកជាយូរឆ្នាំ ៗ បណ្ដាអ្នកដំណើរទាំងនោះ មានមនុស្សចំនួនច្រើន ដែលស្លាប់ចោលខ្មោចហូរហែតាមសមុទ្រក្រហម នឹងលើវាលខ្សាច់ប្រទេសអារ៉ាប់ ៗ ទោះបីយ៉ាងដូច្នេះក៏ដោយចុះ ពួកជនទាំងនោះក៏ឥតរួញរាឡើយ ៗ

តាំងពីចំនួនដប់សតវត្សមកហើយ ការទុរ្ភិក្ស នឹងជម្ងឺប៉េស្តបានបំផ្លាញក្នុងមួយឆ្នាំៗអស់មនុស្សច្រើនណាស់ ព្រមទាំងបញ្ចូលមេរោគមកក្នុងបណ្ដាអ្នកនៅរស់ដែលត្រូវត្រឡប់មកវិញផង ម្ល៉ោះហើយរោគរាតត្បាតនេះ ចួនកាលចាប់ផ្ដើមធ្វើការតាំងពីពេលមុនធ្វើដំណើរទៅទៀតក៏មាន ៗ

ហេតុដូច្នេះ កាលពីគ្រិស្តសករាជ ១៩០៤ នាក្រុងមេក្កាស៊ី រោគរាតត្បាតបានសំដែងឫទ្ធិខ្លាំងអស្ចារ្យ ក្នុងរវាងប៉ុន្មានថ្ងៃសោះ រាប់សំឡាប់មនុស្សអស់ចំនួនប្រាំបីពាន់នាក់ ៗ អ្នកជម្ងឺដួលដេកវណ្ដាលតាមផ្លូវចោលខ្មោចរលួយស្អុយនៅទីនោះ ៗ មានអ្នកខ្លះញាក់ទទ្រើក ដួលលើគំនរសម្រាម ក៏ពុំងរកសត្វស្លាប់ដែលគេចោលយកមកស៊ី ចួនកាលដាច់ខ្យល់ក៏ពុំងបរិភោគអាហារដ៏រអើមនេះ ៗ

ប៉ុន្ដែ ក្នុងប្រទេសនោះ ជម្ងឺផង ការនឿយហត់ផង ការស្លាប់ផង ទាំងនេះគួរណាស់តែបន្ថយអធិមុត្តិ (ការចុះចិត្តស៊ប់) ខាងសាសនានោះចេញខ្លះ នេះមិនដូច្នោះ ហាក់ដូចជារឹតតែរុញអធិមុត្តិ នៃមនុស្សគ្រប់កៀនកោះក្នុងប្រទេសឥស្លាមឲ្យឡើងដល់ទីបំផុតរាល់ឆ្នាំ ៗ

(មានត)

រឿងបល្ល័ង្កទិព្យ សាមសិបពីររឿង

រឿងព្រេងតំណាល

លោកសមិន ម្បត្យ៍នជមៈ តែង

លោក រ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទីបួន

ព្រះមហារាជភោជ: ទ្រង់មានព្រះរាជបំណងចង់ឲ្យគេអភិសេក ទ្រង់ឲ្យសោយរាជ្យជាស្ដេចពេញលក្ខណ:, ទ្រង់ក៏យាងមកជិតព្រះបល្ល័ង្កទិព្យ ។ ក្នុងពេលនោះ រូបទេពនិម្មិតទីបួនក្រាបទូលថា: “ សូមមហារាជភោជ:ទ្រង់ជ្រាប; បល្ល័ង្កទិព្យនេះ ជារបស់ព្រះបាទវិក្រមទិត្យ, បើព្រះមហាក្សត្រិយ៍អង្គណា មានព្រះគុណសម្បត្តិដ៏ឧត្តម ដូចព្រះបាទវិក្រមទិត្យ ទើបអាចគង់នៅលើបល្ល័ង្កនេះបាន” ។ .

ព្រះអភិរាជភោជ: ទ្រង់មានបន្ទូលទៅកាន់រូបទេពនិម្មិតទីបួនថា: “តើគុណសម្បត្តិដ៏ឧត្តមនៃព្រះបាទវិក្រមទិត្យនោះយ៉ាងណាខ្លះ?” ។ រូបទេពនិម្មិតនោះ ក៏ក្រាបទូលថា : “សូមទ្រង់ព្រះសណ្ដាប់;

ព្រះបាទវិក្រមទិត្យ ទ្រង់សោយរាជសម្បត្តិនៅទីក្រុងអវន្តី ។ នៅក្នុងទីក្រុងនោះ មានព្រាហ្មណ៍ម្នាក់គ្មានកូន ជាវិញ្ញូជន ចេះដឹងជ្រៅជ្រះក្នុងវិជ្ជា ១៤ ប្រការ គឺ: វេទ, ឫគ, យជុ, សាម, អថវ៌ ព្រម

ទាំងអនុវិទ្យាទាំងប្រាំមួយ គឺ[1]គម្ពីរសិក្សា (Ciksa) កល្ប; វេយ្យាករណៈ, និរុត្តៈ (Nirukta); ជោតិស (Yotisha), ឆន្ទ, សាស្ត្រ, បូរ្វ-ឧត្តរ-រូបមីមំសា (Pûrva-Uttara-Rûpa-Mimamsà) វៃសេសិកសាស្ត្រ (Vaiceshika-Castra) ន្យាយៈ (Nyàya) សំខ្យា? បតនជលិ, រូបន្យាយៈ (Rûpanyâya) វិស្តរ-ស្មឫតិសាស្ត្រ (Vistara-Smrti-Castara) បុរាណ-សាស្ត្រ និង សាស្ត្រៈខាងវិធីបតិបត្តិ គឺ: វេទៈនៃវេជ្ជសាស្ត្រ, វេទខាងធ្នូសីលជ័យ, សាស្ត្រខាងភ្លេង, សាស្ត្រខាងសិល្បៈ ហត្ថកម្ម[2] វិទ្យាចំពោះវត្ថុដែលចក្ខុមើលឃើញ, ឯចំណែកវិទ្យាទាំងដប់បួនយ៉ាងដែលបានពណ៌នាខាងលើ ជាវិទ្យាសម្រាប់វត្ថុដែលមើលមិនឃើញ, ទាំងអស់រួមជាដប់ប្រាំបីវិទ្យា ។

កិរិយានៃបណ្ឌិតគ្មានកូននេះ ពោលថា: " ឱស្វាមីអើយ, សូមលោកថ្វាយបង្គំអាទិទេពសូមឲ្យខ្ញុំមានកូនមួយនៅក្នុងផ្ទៃ " ។ ព្រាហ្មណ៍តបទៅនាងព្រាហ្មណីថា " នាងពោលនេះល្អ ។ បើគ្មានការប្រតិបត្តិតាមគ្រូទេ គ្មានវិទ្យា; បើគ្មានគុណសម្បត្តិខាងសាសនា គ្មានបុត្រ " ។ ព្រាហ្មណ៍ លុះពោលពាក្យដូចនេះ, ក៏បានបន់ស្រន់ចំពោះអាទិទេពក្នុងគ្រួសារដើម្បីនឹងផ្គាប់ចិត្តកិរិយា ។ ផលដែលបានមកពីករណីយកិច្ចនេះ គឺព្រាហ្មណ៍មានបុត្រម្នាក់ពីនាងព្រាហ្មណី បុត្រនោះគេឲ្យនាមថា

---

១ គឺជាគម្ពីរទាំងប្រាំមួយឈ្មោះតែមួយថា វេទង្គ (Vetsnaga) ។ ២ ពាក្យឥណ្ឌា គឺ: អយុវេទ (Ayur-Veda) ធនុវេទ (Dhanur-Veda) គន្ធវិសាស្ត្រ (Ganaharva) សិល្បសាស្ត្រ: ។

ទេវទត្ត ។ ព្រាហ្មណ៍ជាបិតាបានឲ្យទេវទត្តរៀនសូត្រនូវសាស្ត្រៈទាំងឡាយ ហើយក៏រៀបវិវាហមង្គលការទឹងស្ត្រីម្នាក់ ។ ព្រាហ្មណ៍នោះកាលពិចារណានូវវដ្តសង្សារ ក៏បានទៅកាន់ស្រះបោក្ខរណី, ចំណែកទេវទត្ត ស្ថិតនៅក្នុងគេហដ្ឋានក្នុងឋានៈជាគ្រហាវាស ។

មានមួយថ្ងៃទេវទត្តបានទៅព្រៃ ដើម្បីទឹងទៅរកឧសមកដុតបូជាយ័ញ្ញ ។ ក្នុងពេលនោះ, មហារាជវិក្រមទិត្យទ្រង់គង់លើអស្វ យាងទៅបរបាញ់ក្នុងព្រៃនោះដែរ, ទ្រង់ក៏យាងទៅពាសពេញព្រៃជាមួយទឹងក្នុងទ័ពជាព្រះរាជបរិវារ ដើម្បីទឹងតាមម្រឹគ ។ មហារាជវិក្រមទិត្យទ្រង់ស្រេកព្រះឧទកៈពន់ពេក ដោយទ្រង់វង្វេងនៅក្នុងព្រៃ, ទ្រង់ជួបប្រទះនឹងព្រាហ្មណ៍ទេវទត្ត ។ ព្រះមហាក្សត្រទ្រង់បានទតទៅឃើញព្រាហ្មណ៍, ទ្រង់សំដែងនូវគារវភាពចំពោះព្រាហ្មណ៍ ហើយមានព្រះបន្ទូលថា " ឱព្រាហ្មណ៍ យើងស្រេកទឹកពន់ពេក បូរអ្នករកទឹកឲ្យយើងផឹកផង " ។

ព្រាហ្មណ៍បានស្ដាប់នូវព្រះរាជឱង្ការព្រះបាទវិក្រមទិត្យ ក៏ថ្វាយនូវផ្លែឈើមួយ មានឱជារសឆ្ងាញ់ពិសា ហើយក៏ថ្វាយទាំងទឹកត្រជាក់ទៅទ្រង់ ។ ទ្រង់សោយផ្លែឈើនោះរួចសោយព្រះឧទកៈ ហើយទ្រង់ក៏មានព្រះកាយពលឡើងវិញ ។ ចំណែកព្រាហ្មណ៍ ក៏ទៅបង្ហាញផ្លូវថ្វាយព្រះមហាក្សត្រ ជាផ្លូវដែលទៅកាន់ព្រះរាជនិវេសនដ្ឋាន ហើយវិលត្រឡប់ទៅផ្ទះវិញ ។

មានថ្ងៃមួយ ព្រះមហាក្សត្រទ្រង់បានធ្វើព្រះរាជសន្ទនាការជាមួយ

ព្រះរាជទីប្រឹក្សា, ទ្រង់មានបន្ទូលប្រាប់មន្ត្រីធំ-តូច ដែលចូលទៅសន្និបាតក្នុងពេលនោះ អំពីព្រាហ្មណ៍ទេវទត្ត បានសង្គ្រោះដល់ព្រះអង្គ ហើយក៏ទ្រង់បានសរសើរព្រាហ្មណ៍នេះចំពោះមហាជន ។ ព្រាហ្មណ៍នេះ បានដឹងដំណឹងសព្វគ្រប់ក៏គិតក្នុងចិត្តថា "អញបានសង្គ្រោះចំពោះឧត្តមបុគ្គល, សេចក្ដីសង្គ្រោះនេះ ធ្វើឲ្យឧត្តមបុគ្គលនេះ មានហេតុទាក់ទងនឹងអញអស់មួយជីវិត ។ អញចង់ដឹងតើកតញ្ញូរបស់មហារាជមានសភាពត្រឹមណាទៅ?" ។ ព្រាហ្មណ៍គិតដូចនោះហើយ, បានរកឃើញមធ្យោបាយមួយ បន្ទាប់មកគាត់លួចព្រះរាជបុត្រព្រះមហាក្សត្រនាំយកទៅលាក់បំពួនទុកក្នុងគេហដ្ឋាន ។ ព្រះរាជាទ្រង់ជ្រាបថា ព្រះរាជបុត្រទ្រង់បាត់ពីព្រះដំណាក់ ទ្រង់បានចាត់អាមាត្យសេនាទៅគ្រប់ទីកន្លែងដើម្បីនឹងស្វែងរកព្រះរាជបុត្រ ។ រាជអាមាត្យព្យាយាមរកយ៉ាងណាក៏រកព្រះរាជបុត្រមិនឃើញ ។ ព្រះមហាក្សត្រទ្រង់ព្រួយព្រះរាជហឫទ័យពន់ពេក ព្រមទាំងនាហ្មឺនសព្វមុខមន្ត្រីក៏ព្រួយចិត្តដែរ ។

ក្នុងពេលនោះ ទេវទត្តព្រាហ្មណ៍ បានយករតនវត្ថុដែលព្រះរាជបុត្រទ្រង់ ប្រគល់ឲ្យទាសាយកទៅលក់ឯផ្សារ. ទាសានោះបានទៅដល់ពាណិជស្ថានមួយ បានយកគ្រឿងអលង្ការនោះទៅបង្ហាញនាយពាណិជ ។

ក្នុងមួយរំពេចនោះ, រាជអាមាត្យបានឃើញនូវទាសានៃព្រាហ្មណ៍កាន់គ្រឿងប្រដាប់របស់ព្រះរាជបុត្រ, បានចាប់ទាសានោះ នាំយកទៅ

ថ្វាយព្រះមហាក្សត្រ ។ ទ្រង់ឈ្វៀងព្រះនេត្រទៅកាន់ទាសា មានព្រះបន្ទូលសួរថា "គ្រឿងអលង្ការនេះជារបស់កូនយើង តើអ្នកឯងយកពីណាមក? ឯណាកូនយើង? ។

ទាសានោះក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស, ព្រាហ្មណ៍នាមទេវទត្តបានប្រគល់ឲ្យទូលព្រះបង្គំយកគ្រឿងអលង្ការនេះទៅលក់" ។

ព្រះមហាក្សត្រទ្រង់ជ្រាបនូវដំណឹងនេះ ទ្រង់បានចាត់រាជអាមាត្យឲ្យទៅហៅទេវទត្តព្រាហ្មណ៍មក, ទ្រង់មានបន្ទូលសួរថា: "អ្នកឯងបានប្រគល់គ្រឿងអលង្ការនេះឲ្យគេយកទៅលក់មែនឬ?" ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា: "ទូលព្រះបង្គំបានឲ្យទាសាទូលបង្គំយកគ្រឿងអលង្ការនេះទៅលក់មែន សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ" ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលសួរតទៅទៀតថា "តើអ្នកឯងយកគ្រឿងអលង្ការនេះពីណាមក" ។ ព្រាហ្មណ៍ទូលថា "ទូលបង្គំបានយកពីព្រះរាជបុត្រ" ។ ព្រះមហាក្សត្រទ្រង់សួរថា "កូនយើងនៅឯណា? ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា "ព្រះរាជបុត្រទិវង្គតហើយ" ។ ព្រះមហាក្សត្រមានបន្ទូលសួរថា "ម្តេចក៏កូនយើងស្លាប់" ។ ព្រាហ្មណ៍ក្រាបទូលថា "ទូលព្រះបង្គំបានធ្វើឃាតកម្ម" ។ មហារាជទ្រង់មានបន្ទូលថា "អ្នកឯងជាព្រាហ្មណ៍, ជាបណ្ឌិត ជាវិញ្ញូជន សុចរិតពិតត្រង់ តើហេតុអ្វី បើគ្មានរឿងសោះ ក៏អ្នកឯងហ៊ានសម្លាប់កូនយើង" ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា "មកអំពីលោភចិត្តនៃទូលបង្គំបានជាទូលបង្គំហ៊ានពិឃាតព្រះរាជបុត្រ" ។

ក្នុងខណៈនោះ ព្រះមហាក្សត្រទ្រង់បានចៀងព្រះនេត្រទៅព្រះរាជទីប្រឹក្សា ។ ក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស មនុស្សណាដែលពិឃាតព្រះរាជវង្សានុវង្ស មនុស្សនោះត្រូវព្រះមហាក្សត្រដាក់ទណ្ឌកម្មប្រហារជីវិតបង់ ឯអ្នកនេះបានពិឃាតព្រះរាជបុត្រ, បើតាមយុត្តិធម៌ អ្នកនេះត្រូវតែគេប្រហារជីវិតបង់ដែរ ។ តែអ្នកនេះជាព្រាហ្មណ៍ត្រូវហូតយាននូវសក្តិនេះចេញ ហើយនិរទេសចេញពីព្រះរាជអាណាចក្រព្រមទាំងអ្នកជិតខាងគាត់" ។ ព្រះមហាក្សត្រទ្រង់ព្រះតម្រិះ ដល់គុណូបការៈដែលព្រាហ្មណ៍បានបំពេញចំពោះព្រះអង្គ មិនបានយល់តាមសេចក្តីវិនិច្ឆ័យនៃព្រះរាជទីប្រឹក្សា, ទ្រង់អនុញ្ញាតទោសព្រាហ្មណ៍នោះ ហើយទ្រង់ត្រាស់បង្គាប់ឲ្យគេដោះលែងគាត់ដោយសេរី ។

ព្រាហ្មណ៍នោះ កាលឃើញព្រះទ័យសប្បុរសនៃមហារាជ ក៏មានចិត្តត្រេកអរពន់ពេក បានវិលត្រឡប់ទៅគេហដ្ឋានខ្លួនវិញ ហើយក៏ឲ្យព្រះរាជបុត្រព្រះបាទវិក្រមាទិត្យស្រង់ព្រះឧទក: សោយនូវព្រះស្ងោយ ហើយ បំពាក់នូវគ្រឿងអលង្ការសព្វយ៉ាង ហើយក៏នាំព្រះរាជបុត្រយកទៅឯព្រះរាជក្រុមប្រឹក្សា ។ មហារាជទ្រង់ទតឃើញព្រះរាជបុត្រវិលមកវិញ ទ្រង់មានព្រះទ័យសោមនស្សពន់ពេក, ទ្រង់ឱបព្រះរាជបុត្រដាក់ផ្ទាប់ទៅនឹងព្រះឧរៈ (ទ្រូង) ហើយមានព្រះបន្ទូលទៅកាន់ព្រាហ្មណ៍ថា "ម្នាលព្រាហ្មណ៍! ហេតុម្ដេចក៏អ្នកឯងធ្វើយ៉ាងដូច្នេះ យើងមិនយល់នូវគំនិតអ្នកឯងសោះឡើយ" ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា "ទូលព្រះបង្គំចង់ដឹង គុណូបការៈដែលទូលបង្គំបានបំពេញចំពោះព្រះអង្គ តើព្រះ

អង្គទ្រង់ទឹងតបបែបណាទៅ? គឺមកពីទូលបង្គំចង់ដឹងនូវផលនៃកតញ្ញូ បានជាទូលបង្គំដើរឧបាយបែបនេះ” ។

ក្នុងមួយរំពេច, ព្រះមហាក្សត្រទ្រង់បានព្រះរាជទាននូវព្រះរាជទ្រព្យជាច្រើនអនេកប្បការដល់ព្រាហ្មណ៍ ហើយទ្រង់សព្វព្រះរាជហឫទ័យពន់ពេកនឹងព្រាហ្មណ៍នោះ ។ រួចមក, ព្រាហ្មណ៍ក៏វិលមកកាន់គេហដ្ឋានវិញ ។

រូបទេពនិម្មិតទីបួន, ក្រោយដែលបាននិទាននូវរឿងរ៉ាវខាងលើនេះ បានក្រាបទូលព្រះបាទភោជៈថា “បពិត្រព្រះមហារាជភោជៈ បើទ្រង់អាចប្រព្រឹត្តកតញ្ញូឲ្យដូចជាព្រះមហាក្សត្រវិក្រមទិត្យ ដូចទូលបង្គំបានក្រាបទូលអំបាញ់មញនេះ ទើបទ្រង់អាចគង់លើបល្ល័ង្កទិព្យនេះបាន” ។ ព្រះមហាក្សត្រទ្រង់ព្រះតម្រិះថា គ្មានអ្នកណាធ្វើកតញ្ញូឲ្យបានដូចព្រះបាទវិក្រមទិត្យទេ, ទ្រង់ក៏បង្អង់ព្រះរាជាភិសេកក្នុងពេលនោះ ។

* * *

(មានត)

## ក្រោធដោយឥតហេតុមិនងាយនឹងបន្សាប

មែនពិត, នរជនណាក្រេវក្រោធដោយប្រកាន់យកហេតុណាមួយជានិមិត្ត, នរជននោះ កាលបើហេតុនោះរលត់ហើយ នឹងជ្រះថ្លាវិញ (គឺបាត់ខឹង) មួយរំពេច; ចុះបើនរជនណា ក្រេវក្រោធស្អប់ខ្ពើមដោយមិនមានហេតុ តើនរណាហ្ន៎នឹងអាចបេះមន្តអាគមបន្សាបឲ្យនរជននោះសាបក្រោធបាន?

បញ្ចតន្ត្រ:

## កាំណត់ដំណើរប្រវត្តិការណ៍

# គមនប្បវត្តិ ដំណើរនៃការប្រឡងចេញពីសាលាបាលីរងវត្តឃ្លាំង

ខែត្រឃ្លាំងប្រទេសយៀកណាមខាងត្បូង (កម្ពុជាក្រោម)

## ព្រះមហា ទូត - ទឹម

អាចារ្យសាលាបាលីរងវត្តលង្កា រៀបរៀង

---

ដោយមានដីកាពីក្រសួងធម្មការលេខ ៤០១ ចុះថ្ងៃទី ២៤ កុម្ភៈ ឆ្នាំ ១៩៥៥ ដែលប្រគល់ភារៈឲ្យសាលាបាលីជាន់ខ្ពស់ ចាត់ចែងវិធានការប្រឡងចេញនៃសិស្សសាលាបាលីរង ព្រមទាំងសំបុត្រលេខ ៥៥ ចុះថ្ងៃទី ៤ កុម្ភៈ ឆ្នាំ ១៩៥៥ របស់លោកឡឹម-ឯម អធិបតីនៃពុទ្ធសាសនបណ្ឌិត្យរង សុំអនុញ្ញាតបើកឲ្យសិស្សសាលាបាលីរងនៅខែត្រឃ្លាំង និងព្រះត្រពាំង ប្រឡងចេញនៅថ្ងៃទី ១៤ មីនា ឆ្នាំ ១៩៥៥, នោះក្រសួងធម្មការបានចាត់តាំងភិក្ខុ ៤ រូបគឺៈ ព្រះញាណកោសល ញាណ-ឈឹន គ្រូដំនុំព្រះត្រៃបិដក, ព្រះមហាទូត-ទឹម អាចារ្យសាលាបាលីរងវត្តលង្កា, ព្រះវិន័យធម្មថោង-យុ និងព្រះមហាថាច់-ឯក វត្តសាកវ័ន ឲ្យទៅធ្វើជាគណកម្មការកងការប្រឡងនេះ ។ ព្រះញាណកោសល ញាណ-ឈឹន និងព្រះមហាទូត-ទឹម ត្រូវនិមន្តទៅខាងខែត្រឃ្លាំង; ព្រះវិន័យធម្មថោង-យុ និងព្រះមហាថាច់-ឯក ត្រូវនិមន្តទៅខាងខែត្រព្រះត្រពាំង ។

នៅថ្ងៃព្រហស្បតិ៍ទី ១០ មីនា ឆ្នាំ ១៩៥៥ ព្រះថេរៈទាំង ៤ រូប បានធ្វើដំណើរចេញពីភ្នំពេញទៅសំណាក់នៅវត្តចន្ទរង្សី (ព្រៃនគរ) មួយរាត្រី ព្រឹកឡើងថ្ងៃសុក្រទី ១១ ព្រះញាណកោសល និងព្រះមហាទួត-ទឹម និមន្តទៅខេត្តឃ្លាំង ។

២ ព្រះថេរៈពីរអង្គទៀតក៏ចេញដំណើរនិមន្តទៅខេត្តព្រះត្រពាំង ទីទៃអំពីគ្នា ។

*

* *

## របៀបវារៈនៃការប្រឡង

នៅថ្ងៃចន្ទទី ១៤ មីនា ឆ្នាំ ១៩៥៥ ជាអភិលក្ខិតសម័យ បានបើកឱកាសឲ្យសិស្សប្រឡងនៅវត្តឃ្លាំង ។ ក្រុមសិស្សនិងគណកម្មការមេប្រយោគ ដែលមានព្រះគ្រូបញ្ញាវង្សាថាច់-លន ចៅអធិការវត្តឃ្លាំងជាអធិបតី, ព្រះញាណកោសល ញាណ-ឈឹន អធិបតីរង ព្រមទាំងលោកថាច់-ប៉ាង តំណាងអធិបតីនៃពុទ្ធសាសនបណ្ឌិត្យរង, លោកឱញ-ប្រាជ្ញ លេខាធិការ បាននិមន្តនិងអញ្ជើញទៅជួបជុំនៅក្នុងមន្ទីរប្រឡង ដើម្បីចាំទទួលលោកចៅហ្វាយខេត្តឃ្លាំង ជាតិយៀកណាម លោកនាំយកវិញ្ញាសាមកប្រគល់ឲ្យ ។

នៅឱកាសមុនបន្តិច ព្រះញាណកោសល លោកបានថ្លែងសេចក្តីក្នុងនាមនៃពុទ្ធសាសនបណ្ឌិត្យ, សាលាបាលីជាន់ខ្ពស់ ជាសក់តៀនក្រុមបេក្ខសមណៈ ដើម្បីទុកជាឧត្តមគតិដល់សិស្សទាំងឡាយដូចមានតទៅៈ

បេក្ខសមណៈទាំងឡាយ! ខ្ញុំមានចិត្តត្រេកអរណាស់ ដោយខ្ញុំបាន ទទួលអនុញ្ញាតអំពីរាជការក្រសួងធម្មការ ចាត់ឲ្យមកបំពេញបេសកកម្ម ខាងព្រះពុទ្ធសាសនានៅទីនេះ, មួយទៀត ដោយទឹកឃើញដល់កិច្ចព្រះ ពុទ្ធសាសនា ទីងដោយសេចក្ដីរឭកចំពោះបងប្អូនរួមជាតិខ្មែរដែលនៅក្នុង ដែនកូសាំងស៊ីននេះ ទើបខ្ញុំត្រូវតែស៊ូប្ដូរព្យាយាមមកដោយមិនគិតដល់ការ នឿយហត់ឡើយ ។

ហេតុនេះ ខ្ញុំសូមជាស់តឿនដល់លោកជាបេក្ខសមណៈគ្រប់រូបថា ការប្រឡងនេះ ជាកិច្ចពិសោធចំណេះវិជ្ជានៃការសិក្សា ដែលលោក គ្រប់អង្គបានសិក្សាមកគ្រប់កាលយ៉ាងតិចត្រឹម ៣ ឆ្នាំ ក៏ត្រូវតែប្រឡង ចេញពីសាលាបាលីរង បើលោកអង្គណាបានប្រឡងជាប់ថ្នាក់នេះ ហើយ លោកអង្គនោះឈ្មោះថា បានសិក្សាចប់កិច្ចសិក្សាថ្នាក់ដំបូង, តែ លោកគ្រប់អង្គកុំភ័ន្តច្រឡំ កុំសំគាល់ថា កិច្ចសិក្សាចប់ត្រឹមនេះហើយឲ្យ សោះ ព្រោះកិច្ចសិក្សានៅមានច្រើនទៅមុខទៀត ការប្រឡងជាប់បាន វិញ្ញាបនបត្រសាលាបាលីរងនេះ គ្រាន់តែមានអំណាចនឹងចូលប្រឡងជា សិស្សសាលាបាលីជាន់ខ្ពស់ឯក្នុំពេញប្រាជ្ញាឋានន្តរដទៃ ដែលមានដំឡៃ ស្មើនឹងវិញ្ញាបនប័ត្រសាលាបាលីរងប៉ុណ្ណោះ, ហេតុនេះលោកត្រូវតែតាំង ចិត្តបណ្ដុះឆន្ទៈបំពេញកិច្ចសិក្សាតទៅមុខទៀត កុំគាលលះបង់ឡើយ ។

នៅទីបំផុត ខ្ញុំសូមផ្ដាំអស់លោកដែលបានសិក្សាចេះដឹងត្រឹមសាលា បាលីរងក្ដី សាលាបាលីជាន់ខ្ពស់ក្នុងខាងមុខនេះក្ដី សូមលោកតាំងចិត្ត

ប្រកបដោយកតញ្ញូកតវេទី  ចំពោះអ្នកឧបត្ថម្ភក៏ឲ្យជាប់នៅក្នុងចិត្តជានិច្ច កុំធ្វើចិត្តឲ្យក្លាយទៅជាមក្ខៈគឺការលុបគុណរមិលគុណលោកឲ្យសោះ  ខ្ញុំសុំឲ្យលោកដឹងថាការបានចេះដឹងអំពីទីកន្លែងណា បុគ្គលណា ឬសមាគមណា  បានទំនុកបំរុងឲ្យលោកបានចេះដឹងដល់ថ្នាក់នេះ  លុះលោកបានសម្រេចវិជ្ជាហើយ  លោកត្រូវតែធ្វើអនុវត្តតបគុណចំពោះបុគ្គលនោះ សមាគមនោះឲ្យបានជាក់ស្តែង  ទើបឈ្មោះថាលោកជាអ្នកប្រតិបត្តិខ្លួនឲ្យសមដល់ឋានៈជាពលសាសនា និងជាពលរដ្ឋដែលមានព្រះពុទ្ធសាសនា; ប្រសិនបើលោកសិក្សារៀនសូត្រ  បានចេះដឹងហើយ ៗ លោកគិតតែត្រឹមយកចំណេះមកបំពេញប្រយោជន៍ផ្ទាល់ខ្លួនតែម្យ៉ាង  មិនគិតដល់ប្រយោជន៍សាធារណៈ  គឺប្រយោជន៍របស់សាសនានិងប្រយោជន៍របស់ជាតិផងទេ  នោះសាសនាឬជាតិនឹងឲ្យឈ្មោះលោកថាជាមនុស្សអកតញ្ញូបាន  ព្រោះថាខ្លួនបានចេះដឹងទៅជាមនុស្សមានឧត្តមគតិខ្ពង់ខ្ពស់ប៉ុណ្ណេះ ក៏ដោយសារជាតិនិងសាសនាជួយឧបត្ថម្ភឲ្យ  បើយើងមិនបានយកចំណេះវិជ្ជានេះទៅបំរើជាតិ  បំរើសាសនាទេ  ក៏ឈ្មោះថាយើងមិនដឹងគុណហើយ ។

មុននឹងបញ្ចប់ហោកបានថ្លៀតឧកាសឲ្យស័ព្ទសាធុការពរដល់ភិក្ខុ-សមណៈទាំងឡាយថា សុំឲ្យបានប្រឡងជាប់ពិន្ទុគ្រប់ៗគ្នា;ភិក្ខុសមណៈទាំងឡាយក៏បានទទួលសាធុដោយសេចក្តីត្រេកអរគ្រប់ៗរូប ។

លុះដល់ម៉ោង ៨ ខ្ទះ ១៥ នាទី លោកចៅហ្វាយខេត្តឃ្លាំង បាន នាំវិញ្ញាសាប្រឡងមកប្រគល់ឲ្យគណកម្មការតាមលក្ខណៈច្បាប់ ។ ពេល នោះព្រះមហា ថាច់-ពេច អាចារ្យបង្រៀនសាលាបាលីរងវត្តឃ្លាំង បាន ថ្លែងសុន្ទរកថាទទួលសេចក្ដីត្រេកអរចំពោះពួកការយៀកណាមដែលបាន យកចិត្តទុកដាក់ខ្វល់ខ្វាយក្នុងកិច្ចប្រឡងបាលី ដែលជាវិជ្ជាបែកខាងព្រះ ពុទ្ធសាសនា, លោកចៅហ្វាយខេត្តក៏បានថ្លែងសេចក្ដីខ្លី ៗ ទទួលអំណរ គុណចំពោះកិច្ចនេះដោយស្មោះស្ម័គ្រ ។ បន្ទាប់មកព្រះញាណកោសល បានថ្លែងសេចក្ដីខ្លី ៗ ក្នុងនាមនៃរដ្ឋាភិបាលកម្ពុជាថា "អាត្មាភាពគ្រប់រូប មានសេចក្ដីត្រេកអរណាស់ ដោយបានឯកឧត្តមអញ្ជើញមកជាកិត្តិយស ក្នុងឱកាសជាសុភមង្គលនេះ អាត្មាភាពសូមប្រសិទ្ធពរចំពោះរដ្ឋាភិបាល ទាំងពីរ គឺរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលយៀកណាម សូមឲ្យប្រកប ដោយសន្តិភាពទាំងមានជោគជ័យជានិរន្តរកាល ដើម្បីនឹងបានជាមេត្រី ទាក់ទងគ្នារៀងរហូតទៅឯអនាគតជាយូរអង្វែង" ។ លុះដល់ម៉ោង ៨ គណៈកម្មការមេប្រយោគចាប់ផ្ដើមធ្វើការប្រឡងតាមកាលបរិច្ឆេទ ដូច មានក្នុងប្រកាសជាមួយនឹងអ្នកដំណាងលោកអធិបតីរងនៅខេត្តឃ្លាំង ។

របៀបការៈដែលបានធ្វើការប្រឡងអស់កាលកំណត់ ៣ ថ្ងៃដូចតទៅ នេះគឺ:

ថ្ងៃទី ១.— ពេលព្រឹកពីត្រឹមម៉ោង ៨ ទៅដល់ម៉ោង ៩ សរសេរ តាមសូត្រជាភាសាខ្មែរ, ពេលល្ងាចពីម៉ោង ១៥ ទៅដល់ម៉ោង ១៧ ប្រែ បាលី លោកប្រយោគ ។

ថ្ងៃទី ២.— ព្រឹកពីម៉ោង ៨ ដល់ម៉ោង ៩ អធិប្បាយគាថា, វេលារសៀលពីម៉ោង ១៥ ទៅដល់ម៉ោង ១៦ - ៣០ តបប្រស្នាវិន័យ ។

ថ្ងៃទី ៣.— ព្រឹកពីម៉ោង ៨ ដល់ម៉ោង ៩ តបប្រស្នាពុទ្ធប្បវត្តិ ។

គណៈកម្មការបានពិនិត្យកែវិញ្ញាសាហើយជាស្រេចនៅក្នុងរវាងនៃការប្រឡងនោះ ។ បណ្ដាគ្រហស្ថជាតិខ្មែរដែលជាពុទ្ធសាសនិកច្រើនរូប បានចាត់ចែងចង្ហាន់ប្រគេនគណកម្មការ ព្រមទាំងភិក្ខុសមណៈគ្រប់រូបដោយបរិបូណ៌គ្រប់គ្រាន់ ។ នៅថ្ងៃទី ៣ ដែលសម្រេចការប្រឡងហើយ វេលាម៉ោង ១៧ ល្ងាច ក្រុមឧបាសកឧបាសិកាទាំងឡាយ បាននិមន្តព្រះញាណកោសលសំដែងធម៌ទេសនា នាសាលាបុណ្យក្នុងវត្តឃ្លាំងនោះ ។

*

* *

## លទ្ធផលនៃការប្រឡង

ភិក្ខុសមណៈដែលបានចូលប្រឡងចំនួន ៦០ រូប លុះប្រឡងរួចពល់ហើយ គណកម្មការបានពិនិត្យកែហើយស្រេច ឃើញសិស្សដែលបានទទួលលទ្ធផលនៃការប្រឡងជាប់ចំនួន ៥០ រូប ដូចមានក្នុងសេចក្ដីកត់ហេតុស្រាប់ ។

លុះដល់ថ្ងៃពុធទី ១៦ មីនា ឆ្នាំ ១៩៥៥ ក្រោយថ្ងៃប្រឡងនៅវេលាម៉ោង ១៦ ដល់ម៉ោង ១៩ ព្រះញាណកោសលត្រៀតឧកាសធ្វើទស្សន-

កិច្ចដើរមើលសិស្សសាលាជាតិខ្មែរតាំងពីថ្នាក់កុមារដ្ឋាន ដរាបដល់សិស្ស អនុវិទ្យាល័យថ្នាក់ឆ្នាំទី ១-២ ជាមួយនឹងពួកគ្រូសាលាទាំងនោះ ហើយបានធ្វើបាឋកថារំឭកដល់សិស្សប្រមាណ ៥០០ រូប អំពីគោលធំៗគឺ: ជាតិ, សាសនា, និងព្រះមហាក្សត្រ និងអំពីប្រវត្តិដែនកូសាំងស៊ីននា បច្ចុប្បន្ននេះ ដោយសេចក្តីទ្រស់ៗបន្ទាន់ពេល, គ្រូនិងសិស្សទាំងនោះ មានសេចក្តីរីករាយជាតិយោភាពឥតឧបមាបានឡើយ ។

ថ្ងៃព្រហស្បតិ៍ទី ១៧ មីនា ទើបសមណបេសកៈមាននាមដូចខាងលើ បានធ្វើដំណើរចេញពីខេត្តឃ្លាំងមកសំណាក់នៅវត្តមុនីរង្សី ខេត្តព្រែកឫស្សីអស់កាលមួយរាត្រី ។ នៅទីនោះមាននិស្សិតជាតិខ្មែរដែលនៅសំណាក់រៀនក្នុងខេត្តព្រែកឫស្សីចំនួន ២៥ នាក់ និស្សិតទាំងនោះបាននាំគ្នាមកថ្វាយបង្គំព្រះញាណកោសល ធ្វើបដិសណ្ឋារៈដោយសេចក្តីគោរព, លុះដល់ម៉ោង ២១ យប់ព្រះមហាឧត្តមវិជ្ជា ថាច់-ប្រាជ្ញ និមន្តព្រះញាណកោសលឲ្យធ្វើបាឋកថាចំពោះនិស្សិតខ្មែរទាំងនោះ ដើម្បីរំឭកដាស់តឿនដ៏ជ្រាលជ្រៅ ឲ្យធ្វើទុកក្នុងចិត្តដល់ប្រវត្តិសាស្ត្ររបស់ជាតិ ព្រមទាំងឲ្យរក្សាសាមគ្គីរវាងខ្មែរនឹងខ្មែរ ព្រះញាណកោសលលោកក៏លើកយកគោលអារ្យធម៌នៃព្រះពុទ្ធសាសនាមកធ្វើជាបង្គោលជាទីអាងមានសេចក្តីខ្លីៗដូចតទៅ ៖

និស្សិតទាំងឡាយ ! នៅក្នុងបរិយាកាសដ៏ចង្អៀតនេះ អាត្មាធ្វើដំណើរពីភ្នំពេញមកបំពេញបេសកកម្មផ្នែកខាងព្រះពុទ្ធសាសនា បាន

ទៀតថែកកាស ដើម្បីជួបសន្ទនាប្រស្រ័យរវាងប្រជាជនជាតិខ្មែរ អ្នកស្រុកឆ្ងាយ អាត្មាភាពមានសេចក្ដីត្រេកអរណាស់ ៗ និស្សិតទាំងឡាយ! អាត្មាសូមផ្ដាំនឹងអស់អ្នកគ្រប់គ្នាថា: ជាតិខ្មែរយើងរស់នៅក្នុងចំណោមសាកលលោកនឹងគេបាន ដោយអាស្រ័យនឹងព្រះពុទ្ធសាសនា ។ ជាគោលមួយមានដំហររឹងប៉ឹងល្អ សម្រាប់ទប់ទល់ខ្មែរ ទ្រទ្រង់ខ្មែរឲ្យមានកិត្តិយសនៅក្នុងសាកលលោក សម្លាញ់រួមលោកទាំងឡាយគេអាចស្គាល់ខ្មែរប្រាកដណាស់ថា ខ្មែរជាប្រជាជាតិមួយរស់នៅក្នុងចំណោមអាស៊ីបូព៌ា មានព្រះពុទ្ធសាសនា មានព្រះមហាក្សត្រជាប្រមុខ មានរដ្ឋាភិបាលគ្រប់គ្រងរដ្ឋតាមរបបប្រជាធិបតេយ្យ ដូចប្រទេសទាំងឡាយខ្លះក្នុងលោកសព្វថ្ងៃនេះដែរ ឯខ្មែរកម្ពុជាក្រោមបែកខ្ញែកពីកម្ពុជាជាបច្ចុប្បន្ននេះជាយូរអង្វែងហើយ ដោយមានរដ្ឋាភិបាលផ្សេងពីគ្នា គឺ ១ រដ្ឋាភិបាលកម្ពុជា, ១ រដ្ឋាភិបាលវៀតណាមខាងត្បូង ។ សូម្បីបែករដ្ឋាភិបាលដូច្នោះក៏ដោយ . ក៏គង់ខ្មែរកម្ពុជាក្រោមទាំងនោះចេះរក្សាដំណែលរបស់ជាតិដដែល គឺនៅប្រើភាសា, ប្រើអក្សរសាស្ត្រសម្រាប់ជាតិ, រក្សាទំនឹមទំនៀម, សណ្ដាប់ធ្នាប់, របរទទួលទាន, សំលៀកបំពាក់ និងសាងវត្តអារាមតាមបវេណីខ្មែរពេញលេញឥតលះបង់ឡើយ ៗ មិនតែប៉ុណ្ណោះគេស្គាល់ដល់ប្រវត្តិសាស្ត្ររបស់ខ្មែរតាំងពីបុរាណកាលមក គេស្គាល់ថាខ្មែរសម័យបុរាណមានអាណាចក្រធំទូលាយណាស់ គេតែងហៅថា « មហានគរ ». មានទំហំនឹងព្រំប្រទល់ដូចនិស្សិតទាំងឡាយ

បានរៀនបេះដឹងតាមផែនទីភូមិសាស្ត្រសព្វគ្រប់ស្រាប់ ៗ នៅក្នុងសត-វត្សទី ២៥ នៃ ព. ស. ប្រទេសខ្មែរយើងត្រូវអាប់រស្មីបាត់ពន្លឺ លោកទាំងមូលស្ទើរតែភ្លេចឈ្មោះអស់ហើយ គ្មាននរណាមួយនឹកដល់ប្រទេសខ្មែរទេ ព្រោះអំណាចអាណានិគមនិយមមកកាំង បិទសិទ្ធិ សេរីភាពខ្មែរអស់ ខ្មែរគ្រាន់តែរស់នៅដោយការដកដង្ហើមចេញចូលប៉ុណ្ណោះ ត្រូវគ្មានឹងសុភាសិតថា "ស្លាប់ដូចពស់ រស់ដូចកង្កែប" ឥឡូវនេះ ដោយសេចក្ដីព្រមព្រៀងគ្នារបស់ប្រជាជនជាតិខ្មែរ ដែលមានព្រះមហាក្សត្រព្រះបាទសីហនុវរ្ម័នជាប្រមុខ បានទំព្រឹងទាមទារឯករាជ្យបាន ទើបសាកលលោកពោលសរសើរស្ទើរតែគ្រប់ប្រទេស ដោយគេនឹកស្មានខុសថា "ខ្មែរងើបមុខពុំរួចទេ" ស្រាប់តែខ្មែរផុះភ្លឺឡើងវិញបានទើបគេភ្ញាក់ខ្លួនគ្រប់គ្នាថា ឱ! ខ្មែរនៅដឹងខ្លួនដែរទេតើ ស្មានថាខ្មែរស្លាប់បាត់ទៅហើយ ៗ

និស្សិតទាំងឡាយ! ពេលនេះប្រទេសខ្មែរបានឯករាជ្យហើយ ជោគវាសនារបស់ប្រទេសបានផ្ញើសេចក្ដីសង្ឃឹមលើនិស្សិតគ្រប់រូប សូមនិស្សិតគ្រប់រូបតាំងស្មារតីឲ្យមាំកុំប្រមាទឲ្យសោះ ខំរៀនសូត្រឲ្យបានបេះដូងគ្រប់ៗប្រាណ ហើយត្រូវអធិដ្ឋានក្នុងចិត្តថា នឹងធ្វើការបំរើជាតិ, សាសនា, នឹងព្រះមហាក្សត្រតទៅ ៗ

ថ្ងៃសុក្រទី ១៨ មីនា ឆ្នាំ ១៩៥៥ ព្រះញាណកោសលនឹងសហការីរបស់លោក បានធ្វើដំណើរចេញពីវត្តមុនីវង្សសំដៅទៅកំពង់ស្ពឺនជា

អាណាខេត្តព្រៃកប្ស៊ី សំណាក់នៅក្នុងទីនោះអស់ ២ រាត្រី, ឱកាសនោះប្រជាជនជាតិខ្មែរទាំងឡាយ បានឃើញលោកនិមន្តទៅដល់ ក៏មានសេចក្ដីត្រេកអរ បាននិមន្តសំដែងធម៌ទេសនាក្នុងយប់ទី ២, លុះព្រឹកឡើងថ្ងៃ ២០ មីនា ឆ្នាំដដែល ទើបធ្វើដំណើរចេញពីទីនោះឆ្ពោះទៅកាន់ខែត្រព្រះត្រពាំង ហើយសំណាក់នៅក្នុងខែត្រនោះអស់ថិរវេលា ៣ រាត្រីទៀត ដោយរង់ចាំពិនិត្យបញ្ជីនឹងសេចក្ដីកត់ហេតុ នៃការប្រឡងនៅខែត្រព្រះត្រពាំង លុះរួចរាល់ហើយ ក៏ត្រឡប់មកកាន់រាជធានីវិញនៅថ្ងៃទី ២៣ មីនា ឆ្នាំ ១៩៥៥ ដោយសេរីឥតមានមោះមៃអ្វីឡើយ ។

---

## លក្ខណៈមនុស្សអន់

១ – ដំបូលផ្ទះធ្លាយជាងដំបូលផ្សារ,

២ – គូថភរិយាជិតជាងម្ដាយឪពុក ។

ត្រង់ទី ១ សំដៅយកអ្នកដែលធ្វើដំណើរចេញពីផ្ទះ ទៅកាន់ទីដទៃដោយកិច្ចការណាមួយ, លុះដល់ត្រឡប់មកផ្ទះវិញ មិនត្រង់មករកផ្ទះទេ ត្រឡប់ជាចូលទៅស៊ីផឹកចាយវាយហ៊ឺហាងផ្សារសិន រួចទើបមកផ្ទះ ។

ត្រង់ទី ២ សំដៅយកអ្នកដែលស្វះស្វែងរកទ្រព្យធនបានមកហើយ មិនគិតរំលែកទ្រព្យធននោះបូជាតបគុណមាតាបិតាឡើយ ដោយមិនធ្ងន់ចិត្ត, ធ្ងន់ចិត្តគិតខ្លាំងតែប្រពន្ធនឹងកូន ម្ល៉ោះហើយក៏យកទ្រព្យធននោះទៅសង្គ្រោះចំពោះប្រពន្ធនឹងកូនតែប៉ុណ្ណោះ ។

យូរ - អ៊ុន

## បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

### របស់ក្រសួងធម្មការ

(តមក)

---

សញ្ញាប័ត្រលេខ ៩៧៦ ចុះថ្ងៃសុក្រ ៣ រោចខែបុស្ស ឆ្នាំច្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូម៉ុក-កុយ នាមឆាយា ព្រហ្មគេរ កើតឆ្នាំ-ថោះ អាយុ ២៤ វស្សា ៣ ជាចៅអធិការវត្តពោធិព្រឹក្ស ឃុំស្វាយជ្រះ ស្រុកសូល ខែត្រក្រចេះ ។

សញ្ញាប័ត្រលេខ ៩៧៨ ចុះថ្ងៃសុក្រ ៤ កើតខែបុស្ស ឆ្នាំច្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ សុខ-ទី នាមឆាយា ឧត្តរគេរ កើតឆ្នាំមមី អាយុ ៥៧ វស្សា ៣៧ ជាចៅអធិការវត្តជួនកែវមណី ឃុំត្រពាំងសាប ស្រុកបាទី ខែត្រតាកែវ ។

សញ្ញាប័ត្រលេខ ៩៧៩ ចុះថ្ងៃព្រហស្បតិ៍ ១ កើតខែមាឃ ឆ្នាំច្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ អ៊ុច-អ៊ុយ នាមឆាយា ឥន្ទគេរបញ្ញា កើតឆ្នាំថោះ អាយុ ៣៦ វស្សា ១៥ ជាចៅអធិការ វត្តបន្ទាយក្រាំង ឃុំកណ្ដឹង-ស្រុក-ខែត្រដវែល ។

សញ្ញាប័ត្រលេខ ៩៨០ ចុះថ្ងៃចន្ទ ១១ រោចខែមាឃ ឆ្នាំច្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ រស់-ម៉ែន នាមឆាយា សុវណ្ណបញ្ញា កើតឆ្នាំកុរ អាយុ ៦៤ វស្សា ៨ ជាចៅអធិការ វត្តទ្រព្យគរ ឃុំត្រពាំងសាប ស្រុក-ខែត្រដវែល ។

សញ្ញាប័ត្រលេខ ៩៨១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃួន-ប្រាជ្ញ នាមឆាយា មង្គលត្តេ កើតឆ្នាំរកា អាយុ ៣០ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៨៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មៅ-មាំ នាមឆាយាវិន័យធម្មបញ្ញាកេសរ កើតឆ្នាំខាល អាយុ ៦៣ វស្សា ៤១ ជាគ្រូសូត្រស្តាំ វត្តស្វែង ឃុំដើររៀន ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៨៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង-ឡេង នាមឆាយាឥន្ទកេសរបញ្ញា កើតឆ្នាំរកា អាយុ ៤១ វស្សា ២០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៨៩ ចុះថ្ងៃសុក្រ ៧ កើតខែចេត្រ ឆ្នាំជូតឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ សៅ-ស៊ុន នាមឆាយា សុវណ្ណត្តេ កើតឆ្នាំម្សាញ់ អាយុ ៤៦ វស្សា ២៣ ជាចៅអធិការ វត្តប្រាសាទ ឃុំចំនួស ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៩៩០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពុត-អ៊ុយ នាមឆាយា ពុទ្ធសរេ កើតឆ្នាំខាល អាយុ ៦១ វស្សា ៣៩ ជាចៅអធិការ វត្តគគីរ ឃុំកន្ទ្រាំង ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៩១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ដួង-ប៉ាត នាមឆាយា បុណ្ណសិរី កើតឆ្នាំជូត អាយុ ៣៨ វស្សា ១២ ជាគ្រូសូត្រស្តាំ វត្ត ឃុំ ស្រុក ខេត្តដដែល ។

(មានត)